**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ៣៧៧ ក្រ.ស.ក.ប.ស្ថ

# ប្រកាស
# ស្តីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់ ប្រភេទតំបន់ការពារធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់ប្រភេទតំបន់ការពារធម្មជាតិ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។



អាគារមរតកតេជោ ជីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

**ប្រការ២ .-**

ទម្រង់នៃរូបសញ្ញាសម្គាល់ប្រភេទតំបន់ការពារធម្មជាតិ ត្រូវបានកំណត់យកទម្រង់ផ្នែកខាងក្រៅដូចគ្នានឹងទម្រង់រូបសញ្ញាសម្គាល់អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ប៉ុន្តែផ្នែកខាងក្នុងត្រូវបានកំណត់សម្គាល់ទៅតាមប្រភេទនិងលក្ខណៈវិនិច្ឆ័យនៃតំបន់ការពារធម្មជាតិនីមួយៗ ដែលបានបរិយាយនិងមានខ្លឹមសារ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

**ប្រការ៣.-**

រូបសញ្ញាសម្គាល់ប្រភេទតំបន់ការពារធម្មជាតិត្រូវប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅតាមស្នាក់ការ ស្នាក់ការរង និងតាមតំបន់ការពារធម្មជាតិ
- ដាក់នៅលើឯកសណ្ឋានរបស់មន្ត្រីឧទ្យានុរក្ស
- ប្រើប្រាស់ក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ៤ .-**

រាល់រូបភាពផ្នែកខាងក្នុងដែលមាននៅក្នុងទម្រង់នៃរូបសញ្ញាសម្គាល់ប្រភេទតំបន់ការពារធម្មជាតិនីមួយៗ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ អាចស្នើសុំធ្វើការផ្លាស់ប្តូរ ទៅតាមតម្រូវការចាំបាច់។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ សុក្រ ៥ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១ នៃប្រកាស លេខ ...៣៧៧ ប្រ.ក.ប.ស្ថ...**
**ចុះថ្ងៃ...សុក្រ ៥រោច...ខែ...មិគសិរ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**
**ត្រូវនឹងថ្ងៃទី...២៤...ខែ...ធ្នូ...ឆ្នាំ២០២១**

# ស្ដីពី
# ការបង្កើត និងការដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់ ប្រភេទតំបន់ការពារធម្មជាតិ

## ក. ឧទ្យានជាតិ

១.រូបសញ្ញាសម្គាល់ឧទ្យានជាតិកែប
មន្ទីរបរិស្ថាន ខេត្តកែប




២.រូបសញ្ញាសម្គាល់ឧទ្យានជាតិវីរៈជ័យ-សៀមប៉ាង
មន្ទីរបរិស្ថាន ខេត្តរតនគិរី




២.រូបសញ្ញាសម្គាល់ឧទ្យានជាតិវីរៈជ័យ-សៀមប៉ាង
មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង




៣.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល
មន្ទីរបរិស្ថាន ខេត្តកោះកុង



៣.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល
មន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់

៣.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល
មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ

៤.រូបសញ្ញាសម្គាល់ឧទ្យានជាតិព្រះសុរាម្រឹត-កុសុមៈ«គិរីរម្យ»
មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ

៤.រូបសញ្ញាឧទ្យានជាតិព្រះសុរាម្រឹត-កុសុមៈ«គិរីរម្យ»
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

៥.រូបសញ្ញាសម្គាល់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»
មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ

៥.រូបសញ្ញាឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»
មន្ទីរបរិស្ថាន ខេត្តកំពត

៥.រូបសញ្ញាឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

៦.រូបសញ្ញាសម្គាល់ឧទ្យានជាតិអូរយ៉ាដាវ
មន្ទីរបរិស្ថាន ខេត្តរតនគិរី

៧.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង
ខេត្តកោះកុង

៧.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង
ខេត្តពោធិ៍សាត់

៧.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង
ខេត្តកំពង់ស្ពឺ

៧.រូបសញ្ញាសម្គាល់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង
ខេត្តព្រះសីហនុ

៨.រូបសញ្ញាសម្គាល់ឧទ្យានជាតិព្រះសីហនុ«រាម»
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

៩.រូបសញ្ញាសម្គាល់ឧទ្យានជាតិបទុមសាគរ
មន្ទីរបរិស្ថាន ខេត្តកោះកុង

១០.រូបសញ្ញាសម្គាល់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម
«ភ្នំគូលែន»
មន្ទីរបរិស្ថាន ខេត្តសៀមរាប

១១.រូបសញ្ញាសម្គាល់ឧទ្យានជាតិវីរៈជ័យ
មន្ទីរបរិស្ថាន ខេត្តរតនគិរី

១១.រូបសញ្ញាសម្គាល់ឧទ្យានជាតិវីរៈជ័យ
មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង

១២.រូបសញ្ញាសម្គាល់ឧទ្យានជាតិសមុទ្រកោះរ៉ុង
មន្ទីរបរិស្ថាន ខេត្តកោះកុង

១២.រូបសញ្ញាសម្គាល់ឧទ្យានជាតិសមុទ្រកោះរ៉ុង
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

## ខ.ដែនជម្រកសត្វព្រៃ

១. រូបសញ្ញាដែនជម្រកសត្វព្រៃលំផាត់
មន្ទីរបរិស្ថាន ខេត្តរតនគិរី

១.រូបសញ្ញាដែនជម្រកសត្វព្រៃលំផាត់
មន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី

២.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំព្រេច
មន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី

៣.រូបសញ្ញាដែនជម្រកសត្វព្រៃ «ព្រៃឡង់»
មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង

៣.រូបសញ្ញាដែនជម្រកសត្វព្រៃ «ព្រៃឡង់»
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ




៣.រូបសញ្ញាដែនជម្រកសត្វព្រៃ «ព្រៃឡង់»
មន្ទីរបរិស្ថាន ខេត្តក្រចេះ




៣.រូបសញ្ញាដែនជម្រកសត្វព្រៃ «ព្រៃឡង់»
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ




៤. រូបសញ្ញាដែនជម្រកសត្វព្រៃព្រះរការ
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ



៥.រូបសញ្ញាដែនជម្រកសត្វព្រៃឆែប
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ




៥.រូបសញ្ញាដែនជម្រកសត្វព្រៃឆែប
មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង




៦.រូបសញ្ញាដែនជម្រកសត្វព្រៃតាតៃ
មន្ទីរបរិស្ថាន ខេត្តកោះកុង




៧.រូបសញ្ញាដែនជម្រកសត្វព្រៃកែវសីមា
មន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី



៧.រូបសញ្ញាដែនជម្រកសត្វព្រៃកែវសីមា
មន្ទីរបរិស្ថាន ខេត្តក្រចេះ




៨.រូបសញ្ញាដែនជម្រកសត្វព្រៃស្រែពក
មន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី




៩.រូបសញ្ញាដែនជម្រកសត្វព្រៃសៀមប៉ាង
មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង




១០.រូបសញ្ញាដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក»
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ



១០.រូបសញ្ញាដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក»
មន្ទីរបរិស្ថាន ខេត្តសៀមរាប



១១.រូបសញ្ញាដែនជម្រកសត្វព្រៃ «សឡ្យរុក្ខាវ័ន»
មន្ទីរបរិស្ថាន ខេត្តឧត្តរមានជ័យ



១២.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
មន្ទីរបរិស្ថាន ខេត្តកំពង់ឆ្នាំង



១២.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់
មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ



**១២.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់**
**មន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់**

**១៣.រូបសញ្ញាដែនជម្រកសត្វព្រៃពាមក្រសោប**
**មន្ទីរបរិស្ថាន ខេត្តកោះកុង**

**១៤.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំសំកុស**
**មន្ទីរបរិស្ថាន ខេត្តកោះកុង**

**១៤.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំសំកុស**
**មន្ទីរបរិស្ថាន ខេត្តបាត់ដំបង**

១៤.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំសំកុស
មន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់

១៥.រូបសញ្ញាដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព
មន្ទីរបរិស្ថាន ខេត្តសៀមរាប

១៥.រូបសញ្ញាដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

១៥.រូបសញ្ញាដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព
មន្ទីរបរិស្ថាន ខេត្តឧត្តរមានជ័យ

១៦.រូបសញ្ញាដែនជម្រកសត្វព្រៃបឹងពែរ
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

១៦.រូបសញ្ញាដែនជម្រកសត្វព្រៃបឹងពែរ
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

១៦.រូបសញ្ញាដែនជម្រកសត្វព្រៃបឹងពែរ
មន្ទីរបរិស្ថាន ខេត្តសៀមរាប

១៧.រូបសញ្ញាដែនជម្រកសត្វព្រៃភ្នំណាមលៀរ
មន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី

១៨.រូបសញ្ញាដែនជម្រកសត្វព្រៃ«ព្រៃក្របសព្វ»
មន្ទីរបរិស្ថាន ខេត្តក្រចេះ

១៩.រូបសញ្ញាដែនជម្រកសត្វព្រៃ«សំបូរ»
មន្ទីរបរិស្ថាន ខេត្តក្រចេះ

## គ.តំបន់ការពារទេសភាព

១.និមិត្តសញ្ញាតំបន់ការពារទេសភាពអន្លង់ព្រីង
មន្ទីរបរិស្ថាន ខេត្តកំពត

២.និមិត្តសញ្ញាតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តសៀមរាប

២.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពតំនាបខាងជើងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

៣.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពបឹងព្រែកល្ពៅ
មន្ទីរបរិស្ថាន ខេត្តតាកែវ

៤.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពអាងត្រពាំងថ្ម
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

៥.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពទឹកសាបបឹងព្រែកទប់
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

៦.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព
«ប្រាសាទបាកាន(ព្រះខ័នកំពង់ស្វាយ)»
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

៧.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព«រនាមដូនសំ»
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

៨.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព«សំបូរព្រៃគុក»
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

៩.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពអង្គរ
មន្ទីរបរិស្ថាន ខេត្តសៀមរាប

១០.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពបន្ទាយឆ្មារ
មន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ

១០.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពបន្ទាយឆ្មារ
មន្ទីរបរិស្ថាន ខេត្តឧត្តរមានជ័យ

១១.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាពព្រះវិហារ
មន្ទីរបរិស្ថាន ខេត្តព្រះវិហារ

១២.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព
បឹងយ៉ាកអោមយ៉ាកកាវ៉ា
មន្ទីរបរិស្ថាន ខេត្តរតនគិរី

១៣.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព«ភ្នំក្រាំងដីមាស»
មន្ទីរបរិស្ថាន ខេត្តកំពង់ឆ្នាំង

១៤.រូបសញ្ញាសម្គាល់តំបន់ការពារទេសភាព«បឹងលំពុង»
មន្ទីរបរិស្ថាន ខេត្តរតនគិរី

## ឃ.តំបន់ប្រើប្រាស់ច្រើនយ៉ាង

១.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងពញាព្រែក
មន្ទីរបរិស្ថាន ខេត្តត្បូងឃ្មុំ

២.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង
ព្រែកទឹកសាបក្បាលឆាយ
មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ

### ៣.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង
### «ភ្នំនាងកង្រី-ភ្នំទូកមាស»
### មន្ទីរបរិស្ថាន ខេត្តកំពង់ឆ្នាំង

### ៤.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង
### «សសរស្ដម្ភសត្វតោ»
### មន្ទីរបរិស្ថាន ខេត្តក្រចេះ

### ៥.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង
### «បឹងយក្សឡោម»
### មន្ទីរបរិស្ថាន ខេត្តរតនគិរី

### ៦.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង
### មន្ទីរបរិស្ថាន ខេត្តកោះកុង

៧.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត
មន្ទីរបរិស្ថាន ខេត្តប៉ៃលិន

៧.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៨.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តកំពង់ឆ្នាំង

៨.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

៨.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់

៨.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៨.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប
មន្ទីរបរិស្ថាន ខេត្តសៀមរាប

៩.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង
ទួលព័ន្ធតាឡី បឹងស្នេហ៍
មន្ទីរបរិស្ថាន ខេត្តព្រៃវែង

**១០.រូបសញ្ញាសម្គាល់តំបន់ប្រើប្រាស់ច្រើនយ៉ាង**
**បឹងកាដេរ ខេត្តត្បូងឃ្មុំ**

## ខ.តំបន់រ៉ាមសារស្ទឹងត្រែង

**១.រូបសញ្ញាសម្គាល់តំបន់រ៉ាមសារស្ទឹងត្រែង**
**មន្ទីរបរិស្ថាន ខេត្តស្ទឹងត្រែង**

**២.រូបសញ្ញាសម្គាល់តំបន់រ៉ាមសារកោះកាពិ**
**មន្ទីរបរិស្ថាន ខេត្តកោះកុង**

៣.រូបសញ្ញាសម្គាល់តំបន់រ៉ាមសារបឹងទន្លេឆ្មារ
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

៤. សញ្ញាតំបន់រ៉ាមសារព្រែកទាល់
មន្ទីរបរិស្ថាន ខេត្តបាត់ដំបង

៥.រូបសញ្ញាសម្គាល់តំបន់រ៉ាមសារស្ទឹងសែន
មន្ទីរបរិស្ថាន ខេត្តកំពង់ធំ

**ឧបសម្ព័ន្ធ២ នៃប្រកាសលេខ** ៣៧៧ ប្រក.បស្ថ

**ចុះថ្ងៃ** សុក្រ ៥រោច **ខែ** មិគសិរ **ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**

**ត្រូវនឹងថ្ងៃទី** ២៤ **ខែ** ធ្នូ **ឆ្នាំ២០២១**

**ស្តីពី**

# ការបរិយាយ និងខ្លឹមសារ រូបសញ្ញាសម្គាល់ប្រភេទតំបន់ការពារធម្មជាតិនីមួយៗ

| **ល.រ** | **តំបន់ការពារធម្មជាតិ** | **បរិយាយ និងខ្លឹមសាររូបសញ្ញាសម្គាល់** |
|---|---|---|
| **ក.ឧទ្យានជាតិ** | | |
| ១. | កែប<br>ភូមិសាស្ត្រ<br>ខេត្តកែប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិកែប និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកែប<br>**១.រូបសត្វអកសមុទ្រ** (White-bellied Sea Eagle: *Haliaeetus leucogaster*) ជាតំណាងឧទ្យានជាតិកែប និងជាប្រភេទសត្វស្លាបមានដោយកម្រ និងមានវត្តមានពេញមួយឆ្នាំ និងត្រូវបានចំណាត់ថ្នាក់ទី II នៃអនុសញ្ញាសាយតេស។<br>សត្វអកសមុទ្រ មានប្រវែង ៧០-៨៥ សង់ទីម៉ែត្រ ដែលពេលទំលើមែកឈើខ្លួនឈរត្រង់ ក្បាល ទ្រូង និងពោះសប្បុរសព្រលែត ស្លាបសប្បុរព្រលែត តែស្លាបទី១ និងទី២សប្បុរខ្មៅ ចំពុះធំខុប ផ្នែកលើកន្ទុយសប្បុរខ្មៅដែលមានវត្តមានតែឆ្នេរសមុទ្រ កោះ និងនៅតំបន់ដីសើមទឹកសាបម្តងម្កាល។ ការបន្តពូជរបស់វា ចាប់ពីខែកញ្ញា ដល់ខែមិថុនា ដែលមានពងចំនួន២គ្រាប់។<br>២.ឧទ្យានជាតិកែប ស្ថិតនៅក្នុងរដ្ឋបាលខេត្តកែប សប្បុរស និងសប្បុរលឿង បង្ហាញថាឧទ្យានជាតិជាប់នឹងតំបន់ឆ្នេរដែលសម្បូរបែបទៅដោយធនធានព្រៃឈើ និងជីវៈចម្រុះ និងធនធានសមុទ្រដ៏ច្រើន ដែលផ្តល់ប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ ដូចជា ត្រី ក្តាម បង្គា មឹក លៀស ខ្យង ងាវ ។ល។<br>៣.រូបភ្នំមានសប្បុរបៃតងជាំ ជាទីជម្រាល និងផ្ទៃរងអាងទឹកភ្លៀងសម្រាប់ប្រើប្រាស់នៅក្នុងក្រុងកែប និងនៅតាមបណ្តាស្រុក និងជាតំបន់ទាក់ទាញទេសចរជាតិ និងអន្តរជាតិលេងកម្សាន្ត និងស្នាក់នៅដែលចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងបរិស្ថាន និងលើកស្ទួយសុខុមាលភាពសាធារណៈ។<br>៤.ជាមួយគ្នានេះដែរ ផ្នែកមួយចំនួននៃមាត់សមុទ្រនៅភាគខាងកើត និងខាងលិចនៃឧទ្យានជាតិកែប មានព្រៃកោងកាងលាតសន្ធឹងពីទំនាបទឹកប្រៃរហូតដល់មាត់ សមុទ្រ ហើយព្រៃកោងកាងទាំងនេះផ្តល់ជាថ្នាល បណ្តុះពូជ និងជាទីជម្រកពង កូនដល់ពពួកត្រី ក្តាម ខ្យង លៀស និងគ្រប់ប្រភេទសត្វសមុទ្រ និងជាជម្រកធម្មជាតិសម្បូរបែបប្រកបដោយជីវសាស្ត្រចម្រុះនិងសោភ័ណភាពទេសភាពស្រស់បំព្រងដ៏សំខាន់សម្រាប់សត្វស្លាប។ |

| | | |
|---|---|---|
| | | ៥.ឧទ្យានជាតិកែប ជាតំបន់ការពារធម្មជាតិ មានតួនាទី និងមុខងារបម្រើឱ្យការទស្សនានូវធម្មជាតិប្រណិតទាំងធនធាន ធម្មជាតិតំបន់ការពារធម្មជាតិដីគោក និងតំបន់ការពារធម្មជាតិធនធានសមុទ្រ ការសិក្សាស្រាវជ្រាវ និងអប់រំ វិទ្យាសាស្ត្រ និងជំនឿ សាសនា រក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ សម្រាប់ជាប្រយោជន៍ឧដុង្គឧត្តមដល់មនុស្សគ្រប់ៗជំនាន់។ |
| ២. | **វីរៈនសៃ-សៀមប៉ាង** ភូមិសាស្ត្រខេត្តរតនគិរី និងខេត្តស្ទឹងត្រែង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិវីរៈនសៃ-សៀមប៉ាង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី និងមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង<br>១.រូបសត្វទោចឈ្មោលថ្ពាល់លឿង ( Yellow-cheeked Crested Gibbon: *Nomascus gabriellae*) ជាតំណាងឧទ្យានជាតិវីរៈនសៃ-សៀមប៉ាង និងជាថនិកសត្វក្រុមប្រភេទមានដោយកម្រ។ ប្រភេទនេះត្រូវចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទងាយរងគ្រោះនៅលើពិភពលោក និងត្រូវបានចាត់ថ្នាក់ក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វទោចថ្ពាល់លឿងមានសម្បុរប្រហាក់ប្រហែលគ្នាទៅនឹងទោចម្កុដដែរ។ សត្វទោចថ្ពាល់លឿង គ្មានកន្ទុយ។ ចំពោះ ទោចឈ្មោល មានសម្បុរខ្មៅ លើកលែងថ្ពាល់មានរោមសម្បុរលឿង។ ចំណែកសត្វទោចញីពេលពេញវ័យមានសម្បុរលឿងស្លាទុំ ដោយមានកញ្ចុំរោមខ្មៅនៅលើក្បាល និងថ្ពាល់មានរោមលឿងរាងដូចផ្លិត។ សត្វទោចថ្ពាល់លឿងរស់នៅក្នុងព្រៃស្រោង និងពាក់កណ្ដាលស្រោង ដែលជាក្រុមតូចៗ មានចំនួន២-៥ក្បាល។ អាហាររបស់វា មានផ្លែផ្កា និងត្រួយឈើ ហើយនិងសត្វល្អិត។ សត្វទោចញីថ្ពាល់លឿង បង្កើតកូនម្ដងតែមួយក្បាលគត់ បន្ទាប់ពីពពោះរយៈពេល២១០ថ្ងៃ ហើយចន្លោះពេលដែលមានកូនពីចំនួនមួយទៅមួយ គឺ២-៣ឆ្នាំ។<br>២.រូបភាពរំលេចភ្នំមានសម្បុរខៀវ និងវាលស្មៅសម្បុរលឿងទុំ ដែលសម្បូរបែបទៅដោយធនធានធម្មជាតិ និងជីវៈចម្រុះនិងប្រព័ន្ធធនធានទឹកជាច្រើនដែលជាទីជម្រាលផ្ដល់ទឹកហូរចូលទន្លេសេសាន ទន្លេសេកុង និងទន្លេស្រែពក និងទន្លេមេគង្គក្រោម។<br>៣.ឧទ្យានជាតិវីរៈនសៃ-សៀមប៉ាង មានសារៈសំខាន់ក្នុងការអភិវឌ្ឍខេត្ត និងក្នុងតំបន់។<br>៤.ឧទ្យានជាតិវីរៈនសៃ-សៀមប៉ាងក៏មានសារៈសំខាន់ និងតម្លៃជីវៈចម្រុះ និងតម្លៃផ្នែកធនធានព្រៃឈើ ផ្នែកទីជម្រាលសម្រាប់បម្រើដល់វិស័យកសិកម្ម និងវិស័យអភិវឌ្ឍខេត្ត និងក្នុងតំបន់ តម្លៃផ្នែកធនធានវប្បធម៌ដែលមានសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចរស់នៅនិងអាស្រ័យផលយូរឆ្នាំ តម្លៃផ្នែកការសិក្សាស្រាវជ្រាវនិងអប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីឥណទានកាបូន តម្លៃផ្នែកអភិវឌ្ឍទេសចរធម្មជាតិ និងតម្លៃផ្នែកផ្ដល់ការងារដល់ប្រជាជនមូលដ្ឋាននិងជនជាតិដើមភាគតិច និងតម្លៃផ្នែកតភ្ជាប់ធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែបនៃឧទ្យានជាតិវីរៈជ័យ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឦសាន។ |

| | | |
|---|---|---|
| ៣. | **ជួរភ្នំក្រវាញ កណ្តាល** ភូមិសាស្ត្រ ខេត្តកោះកុង ពោធិ៍សាត់ និង ខេត្តកំពង់ស្ពឺ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង ពោធិ៍សាត់ និងមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ<br>១.រូបសត្វដំរីអាស៊ី (Asian Elephant: *Elephas maximus*) ជាតំណាងឧទ្យានជាតិជួរភ្នំក្រវាញ និងជាថនិកសត្វក្រុមប្រភេទជិតផុតពូជ និងចុះបញ្ជីក្រហមរបស់អង្គការIUCN ជាប្រភេទសត្វជិតផុតពូជនៅលើពិភពលោក ហើយត្រូវបានគេចាត់ថ្នាក់នៅក្នុងឧបសម្ព័ន្ធ I និងត្រីតាពត ឬត្រីនាគជាតំណាង និងជាក្រុមប្រភេទត្រីទឹកសាបជិតផុតពូជ។<br>នៅឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល មានដំរីរស់នៅតាមព្រៃល្បោះ វាលស្មៅ ព្រៃឫស្សី ព្រៃជាំទឹក តាមដងអូរ ព្រៃពាក់កណ្តាលស្រោង។ សត្វដំរី អាហាររបស់សត្វមាន មានសំបកឈើ មើមឈើ ឫសឈើខ្ចីៗ ទំពាំង ឫស្សី និងវល្លិ៍ ផ្លែឈើ អំពៅ ចេក ជាដើម។ សត្វដំរី ផឹកទឹកប្រមាណ២០០លីត្រក្នុងមួយថ្ងៃ និងអាចផ្តល់កំណើត កូនម្តង ១ក្បាល។ ដំរីមេអាចបង្កើតកូនចំនួន ៤ ឬ៥ដង ហើយអាចមានអាយុចាប់ពី ៥០-៧០ឆ្នាំ។<br>២.រូបត្រីតាពត ឬត្រីនាគ (Asian bonytongue : *Scleropages formosus*) ជាតំណាងនិងសំបូរបែបដោយធនធានធម្មជាតិ ។ ត្រីនាគ គឺជាត្រីទឹកសាបមួយប្រភេទនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រស់នៅក្នុងទន្លេ និងស្ទឹងដែលមានទឹកហូរមានចរន្តយឺតៗ។<br>ត្រីនាគ បានប្រែក្លាយជានិមិត្តរូបតំណាងឱ្យភាពស្រស់ឆើតឆាយ សម្រាប់លំអ និងភាពរុងរឿងដែលជាជំនឿរបស់ប្រជាជនអាស៊ី ជាពិសេសប្រជាជនចិន។ ត្រីនាគ ត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទត្រីងាយរងគ្រោះ ដែលនឹងឈានទៅដល់ការផុតពូជ។ ត្រីនាគមានប្រវែងដល់៩០សង់ទីម៉ែត្រ ដែលរស់នៅក្នុងតំបន់ទឹកភ្លាវ តាមអូរ ស្ទឹងនៅតំបន់ភ្នំ តាមជួរភ្នំដងរែក ជាពិសេសនៅក្នុងខេត្តកោះកុងដែលនៅតាមដងស្ទឹងអារ៉ែង និងតាមដៃរបស់វា ដូចជាស្ទឹងតាតៃក្រោម កោះប៉ុល ស្ទឹងមេទឹក និងស្ទឹងត្រពាំង ស្រុកថ្មបាំង និងមានអន្លង់ទឹកជួរ ដូចជាអន្លង់ក្បាលទូក (ទំហំ ៣,៨ ហិកតា) អន្លង់ទឹកនឹង (១,១ ហិកតា) និងអន្លង់បែកផ្សែង (ទំហំ ៥៩ហិកតា) និងមានផ្ទាំងថ្មធំៗ។ ក្រៅពីអន្លង់សំខាន់ៗទាំងនេះ នៅមានអន្លង់មួយទៀត ដែលមានជម្រៅរហូតដល់ ៨ម៉ែត្រ មានឈ្មោះថាអន្លង់សពខ្មោច ឬអន្លង់ឆាយបីជាន់ ដែលនៅទីនោះមានមេពូជត្រីនាគប្រមាណ ២ ទៅ៣ក្បាលរស់នៅ។<br>៣.សត្វដំរីអាស៊ី ជាសត្វមានមាឌធំអំណាច និងកម្លាំងខ្លាំងដោយងាយផ្សាំងដែលមានចរឹកស្លូតបូត និងគេប្រើប្រាស់វាសម្រាប់អូសទាញវត្ថុធ្ងន់ៗ ដូចជាទាញឈើសម្រាប់សាងសង់លំនៅដ្ឋានពីអតីតកាល និងថ្មសាងសង់ប្រាសាទអង្គរវត្ត ដែលជាភស្តុតាងស្រាប់នៅលើចម្លាក់ជញ្ជាំងប្រង្គប្រាសាទអង្គរវត្ត។ ជាមួយគ្នានេះដែរសត្វដំរីជាយានជំនិះរបស់ |

| | | |
|---|---|---|
| | | អតីតព្រះមហាក្សត្រ និងមេទ័ពជំនាន់មុនៗ ដែលបញ្ជាក់ពីភាពខ្លាំងអស្ចារ្យ និងការពលីជីវិតរបស់សត្វដំរីអាស៊ី ក្នុងសមរភូមិប្រយុទ្ធតតាំងជាមួយសត្រូវ។<br>៤.ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល មានវត្តមានសត្វដំរី និងសម្បូរបែបទៅដោយធនធានធម្មជាតិ និងជីវៈច ម្រុះ និងប្រព័ន្ធដែលជាទីជម្រកសត្វថនិកសត្វ បក្សី ល្មូន អវង្គសត្វ និងមច្ឆជាតិដែលជាពិសេសត្រីតាពក ឬត្រីនាគ។<br>៥.ឧទ្យានជាតិជួរភ្នំក្រវាញ មានសារៈសំខាន់ និងតួនាទីផ្នែកសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកកម្សាន្ត ការទស្សនា តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ វិទ្យាសាស្ត្រ និងជំនឿ។ ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងតំបន់របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិជួរភ្នំក្រវាញផ្ដល់នូវផលប្រយោជន៍ដ៏ឧត្តុង្គឧត្ដមជាផលិតផល និងសេវាកម្មធម្មជាតិជាឥណទានកាបូនសម្រាប់ប្រតិបត្តិការការពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងស្ដារឡើងវិញនូវធនធានធម្មជាតិ និងជាផលប្រយោជន៍ជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើងតាមរយៈការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ។ |
| ៤. | **ព្រះសុរាម្រឹត-កុសុមៈ «គិរីរម្យ»** ភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិព្រះសុរាម្រឹត-កុសុមៈ «គិរីរម្យ» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពត កំពង់ស្ពឺ និងមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបដើមស្រល់ ៣ដើម [ Pinus ( Pinaceae, Gymnosspermes ): *Penus merkisii* ជាតំណាង និងសំបូរបែបធនធានធម្មជាតិឧទ្យានជាតិ ព្រះសុរាម្រឹត-កុសុមៈ«គិរីរម្យ»។ តំបន់ការពារធម្មជាតិនេះ មានសារៈសំខាន់ និងមានតួនាទីផ្នែកការពារប្រព័ន្ធអេកូឡូស៊ីស្រល់ ដែលជាព្រឹក្សកម្ពស់ពី៣០-៥០ម៉ែត្រ និងដុះនៅលើកំពូលភ្នំដែលមានផ្ទៃដីទំហំប្រមាណ១២០០ ហិកតា។ វត្តមានដើមស្រល់ មានដុះ និងលូតលាស់នៅក្នុងតំបន់ការពារធម្មជាតិមួយចំនួនទៀតដែរ ដូចជានៅដែនជម្រកសត្វព្រៃ«ព្រៃឡង់» ដែនជម្រកសត្វព្រៃកែវសីមា ឧទ្យានជាតិវីរៈជ័យ ដែនជម្រកសត្វព្រៃ«ព្រៃឡង់» និងនៅឧទ្យានជាតិជួរភ្នំក្រវាញ និងអាចមាននៅក្នុងតំបន់ផ្សេងៗទៀតដែលមិនទាន់បានសិក្សានៅឡើយ។<br>២.ប្រភេទឈើនេះមានសារៈសំខាន់ និងតម្លៃសម្រាប់ជាគ្រឿងបង្គុំខាងក្នុងរថអយស្ម័យយាន នាវា ធ្វើតុ ទូ របស់ប្រើប្រាស់ផ្សេងៗ និងគ្រោងទ្វារ បង្អួច។ ជ័រក្រៀមរបស់វាជាឱសថបុរាណសម្រាប់ធ្វើថ្នាំម្វាប់រោគផ្សេងៗ ដូចជាបូសទ្រនិច បូសធម្មតា និងចរន្តឈាមមិនល្អ។<br>៣.ឧទ្យានជាតិព្រះសុរាម្រឹត-កុសុមៈ «គិរីរម្យ» គឺជាតំបន់មានសារៈសំខាន់ និងមានតម្លៃផ្នែកការផ្ដល់នូវអាកាសធាតុត្រជាក់បរិសុទ្ធ ប្រកបដោយសុខុមាលភាព និងផ្នែកអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិពីការទស្សនាទេសភាពធម្មជាតិប្រណិត។ ជាតំបន់ដែលមានតម្លៃផ្នែកទីជម្រាល និងផ្ទៃរងទឹកភ្លៀងសម្រាប់ការផលិតវារីអគ្គិសនី និងមានប្រព័ន្ធផ្លូវទឹក |

| | | |
|---|---|---|
| | | ស្ទឹងព្រែកត្នោតហូរចូលទន្លេបាសាក់ ដែលចូលរួមប្រើប្រាស់ក្នុងការអភិវឌ្ឍន៍គ្រប់វិស័យរបស់ជាតិ។ ជាងនេះទៀត តំបន់នេះ ក៏មានសារៈសំខាន់ និងតម្លៃផ្នែកសម្បូរបែបដោយធនធានធម្មជាតិ និងជីវៈចម្រុះដែល ត្រូវការថែរក្សា ការពារ និងប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាពយូរអង្វែង តាមរយៈការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ និងការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដោយតភ្ជាប់នឹងប្រព័ន្ធអេកូឡូស៊ីនៃឧទ្យានជាតិក្រវាញខាងត្បូង។<br>៤.ជាតំបន់វប្បធម៌ ដែលមានមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនាកម្ពុជា និងវត្តអារាមនានា ដែលប្រជាជនរស់នៅទីនោះទៅប្រតិបត្តិគោរពបូជាក្នុងនាមជាអ្នកកាន់សាសនាព្រះពុទ្ធ និងជាតំបន់ផ្តល់ការងារធ្វើជូនប្រជាជនមូលដ្ឋាន។ |
| ៥. | **ព្រះមុនីវង្ស«បូកគោ»** ភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ កំពត និងខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ កំពត និងមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបសត្វស្លាបកេងកងធំ( Great Hombill: *Buceros bicomis*) ជាតំណាងឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» និងជាក្រុមប្រភេទសត្វស្លាបមានដោយកម្រ។ សត្វស្លាបកេងកងធំមានប្រវែង ១១៩-១២២ សង់ទីម៉ែត្រ។ ចំពោះសត្វឈ្មោល មានបណ្តាយខ្លួនធំ ក្បាល មានសប្បុរខ្មៅលឿង មានចំពុះ និងមួកធំលឿងឆ្នូតកណ្តាល ស្លាបសប្បុរលឿង និងឆ្នូតសតាមគែមស្លាបក្រោម កន្ទុយស និងមានឆ្នូតទទឹងខ្មៅធំមួយ ភ្នែកក្រហម។ ចំពោះសត្វញី ភ្នែកស និងក្បាលពកពុំមានសប្បុរខ្មៅទេ។ សត្វស្លាបកេងកងរស់នៅក្នុងព្រៃស្រោង និងព្រៃល្បោះចម្រុះ ដែលរស់នៅ និងធ្វើសំបុកនៅក្នុងរន្ធឈើធំៗ និងបន្តពូជចាប់ពីខែមករា ដល់ខែសីហា ដែលមានពងចំនួន ១-៣។<br>២.រូបផ្សេងទៀត បញ្ជាក់ពីជួរភ្នំ ជ្រលងភ្នំ ផ្ទាំងថ្ម ទឹកធ្លាក់ គ្របដណ្តប់ដោយធនធានធម្មជាតិ និងធនធានជីវៈចម្រុះ ដែលមានព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃល្បោះ និងជាតំបន់ទីជម្រាល និងជាប្រភពផ្ទៃរងទឹកភ្លៀងស្តុកទឹកសម្រាប់វារីអគ្គិសនី និងទឹកស្អាតសម្រាប់ប្រជាជនប្រើប្រាស់នៅក្រុង និងជុំវិញខេត្តកំពត។<br>៣.ជាតំបន់ជម្រកសត្វព្រៃដោយសម្បូរបែប និងជីវៈចម្រុះ ការការពារទឹកជំនន់ ការការពារហូរច្រោះ រក្សាដីមានជីជាតិ រួមទាំង មានវត្ត រូបសំណាកព្រះពុទ្ធរូប និងសំណាកលោកយាយ ម៉ៅ ដែលមានតម្លៃសម្រាប់សម្បត្តិ វប្បធម៌បម្រើប្រយោជន៍សាធារណៈ និងជាទីសក្ការៈ។<br>៤.ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» ក៏មានសារៈសំខាន់និងតម្លៃផ្នែកជីវៈចម្រុះ និងធនធានព្រៃឈើ តម្លៃផ្នែកសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីការវិនិយោគផ្នែកទេសចរធម្មជាតិ និងតម្លៃផ្នែកការផ្តល់ការងារដល់ប្រជាជន និងជាឧទ្យានជាតិមួយត |

| | | |
|---|---|---|
| | | ភ្ជាប់នឹងប្រព័ន្ធអេកូឡូស៊ី ធនធានធម្មជាតិ និងជីវៈចម្រុះដ៏សម្បូរបែបនៃឧទ្យានជាតិព្រះសុរាម្រឹត-កុសុមៈ«គិរីរម្យ» និងរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ។ |
| ៦. | **អូរយ៉ាដាវ** ភូមិសាស្ត្រ ខេត្តរតនគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិអូរយ៉ាដាវ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី<br>១. រូបសត្វខ្លារខិន (Leopard: *Panthera pardus*) ជាតំណាងឧទ្យានជាតិអូរយ៉ាដាវ និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ និងស្ថិតនៅក្នុងបញ្ជីឧបសម្ព័ន្ធទីI នៃអនុសញ្ញាសាយតេស។ ខ្លារខិនមានកិនភាគងាយចំណាំណាស់ គឺមានសប្បុរលឿង ក្រហមត្នោត និងមានអុចៗ ជាកញ្ចុំនៅពាសពេញខ្លួន ដែលរស់នៅក្នុងព្រៃស្រោង រហូតដល់ដល់ព្រៃគម្លោតដែលមានផ្ទាំងថ្ម។ ចំណីរបស់សត្វខ្លារខិន មានពពួកប្រើស ឈ្លូស ជ្រូកព្រៃ ស្វា សត្វស្លាប សត្វកកេរ និងសត្វល្មិត។<br>២.រូបសប្បុរបៃតងជាតំបន់ព្រៃភ្នំ និងផ្ទាំងថ្ម គ្របដណ្តប់ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលមាន ព្រំប្រទល់ជាប់នឹងខេត្តយាឡាយប្រទេសវៀតណាម។<br>៣.ឧទ្យានជាតិអូរយ៉ាដាវ សម្បូរទៅដោយសត្វស្លាប ល្មូន និងឧរង្គសត្វ និងជាតំបន់អាចការពារទឹកជំនន់ ការហូរច្រោះ រក្សាដីមានជីជាតិ និងជាទីជម្រាល ដែលជាប្រភពទឹកហូរកាត់ទន្លេស្រែពកជាប់នឹងដែនជម្រកសត្វព្រៃភ្នំស្រែពកខេត្តមណ្ឌលគិរី។<br>៣.ឧទ្យានជាតិអូរយ៉ាដាវ ក៏មានសារៈសំខាន់និងតម្លៃផ្នែកទេសចរណ៍ ធម្មជាតិ តម្លៃផ្នែកធនធានវប្បធម៌ និងធនធានធម្មជាតិ និងជីវៈចម្រុះ ដែលមានសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចរស់នៅ និងអាស្រ័យផលយូរអង្វែង តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកស្រាវជ្រាវនិងអប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីឥណទានកាបូន និងតម្លៃផ្នែកការផ្តល់ការងារជូនប្រជាជនមូលដ្ឋាន និងជាតំបន់ការពារធម្មជាតិតភ្ជាប់នឹងប្រព័ន្ធអេកូឡូស៊ី ធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែបនៃឧទ្យានជាតិវីរៈជ័យ និងរបៀងអភិរក្សជីវៈចម្រុះព្រៃឡង់ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែន។ |
| ៧. | **ជួរភ្នំក្រវាញខាងត្បូង** ភូមិសាស្ត្រ ខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និង ខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ផ្នែកខាងលើ មានរំលេចអក្សរឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និងមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបសត្វខ្លាធំ ឬខ្លាដំបង (Tiger: *Panthera tigris*) ជាតំណាងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងជាក្រុមប្រភេទថនិកសត្វជិតផុតពូជ និងមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស ហើយត្រូវបានចុះក្នុងបញ្ជីក្រហម IUCN ថាជាប្រភេទកំពុងរងគ្រោះថ្នាក់ជិតផុតពូជ។ |

| | | |
|---|---|---|
| | | សត្វខ្លាធំជាប្រភេទដែលមានមាឌធំជាងគេបំផុតក្នុងចំណោមអំបូរឆ្មា ដោយមានសម្បុរក្រហម លឿង ឬត្នោតខ្ចី មានឆ្នូតបង្កង់សប្បុរក្រម៉ៅកាត់ទទឹងដងខ្លួន។ នៅក្រោមចង្កា និងបំពង់ក មានព័ណ៌ស ព្រមទាំងមានកន្ទុយខ្មៅជាកង់ៗ និងខ្មៅនៅផ្នែកខាងមុខ។ សត្វខ្លាធំស៊ីសាច់ជាអាហារ ដូចជាសត្វប្រើស ទន្សោង និងខ្ទីង ។ល។ សត្វខ្លាធំអាចបង្កាត់ពូជគ្រប់រដូវ ដែលអាចបង្កាត់កូនបានពីចំនួន ១-៧ ក្បាលបន្ទាប់ពីពពោះរយៈពេលប្រហែល១០០ ថ្ងៃ ហើយអាចមានអាយុដល់២៥ ឆ្នាំក្នុងធម្មជាតិ។<br>២.រូបភាពដើមក្រវាញ និងពណ៌លឿងវាលស្មៅ និងពណ៌ខៀវ ជាសម្បត្តិធម្មជាតិដែលបង្ហាញពីតម្លៃជីវៈចម្រុះ និងធនធានធម្មជាតិ និងតម្លៃផ្នែកសេដ្ឋកិច្ចពីឥណទានកាបូន ដូចជា ភ្នំ ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងជាប្រភពទីជម្រាលនៃផ្ទៃទឹកភ្លៀង ដែលមានប្រព័ន្ធធនធានទឹកជាច្រើន។ ឧទ្យានជាតិក្រវាញខាងត្បូង មានវត្តមានប្រភេទសត្វជិតផុតពូជ និងមានដោយកម្រជាច្រើនដូចជា៖ ដំរីអាស៊ី សត្វខ្លាឃ្មុំធំ សត្វខ្លាឃ្មុំតូច សត្វទោចម្កុដ សត្វញើ ខ្ទីង ឈ្លូស ប្រើស ឆ្កែព្រៃ និងខ្លាពពកជាដើម និងបក្សីច្រើនប្រភេទទៀត។<br>៣.តំបន់ទឹកធ្លាក់ និងទេសភាពប្រណិតផ្សេងៗទៀត មានសារៈសំខាន់ទាក់ទាញទេសចរជាតិ និងអន្តរជាតិទៅទស្សនាដែលអាចឱ្យប្រជាជនរកចំណូល ដើម្បីបង្កើនជីវភាពប្រជាជនកាន់តែប្រសើរឡើង និងរស់នៅសុខដុមរមនា។ |
| ៨. | **ព្រះសីហនុ «រាម»**<br>ភូមិសាស្ត្រខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិព្រះសីហនុ «រាម» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបដើមកោងកាង (Rhizophora: Rhizophora mucronata) ជាតំណាងឧទ្យានជាតិព្រះសីហនុ «រាម» និងរូបតំបន់ឆ្នេរ។<br>ព្រៃកោងកាង ជាព្រឹក្ស ឬចុល្លព្រឹក្សម៉្យាង មានផ្លែរាងវែង ដុះនៅតាមឆ្នេរសមុទ្រ និងវាលភក់នៅតំបន់ឆ្នេរ ដែលមានកម្ពស់ពី ២-៨ ម៉ែត្រ។ នៅវាលភក់នៃអាស៊ី គេប្រើសំបកធ្វើជាថ្នាំជ្រលក់សំពត់ និងសំណាញ់នេសាទ។ ចំពោះកម្ពុជា យកសំបកជាថ្នាំរាគ។<br>២.ឧទ្យានជាតិព្រះសីហនុ «រាម» ជាតំបន់សម្បូរបែបទៅដោយសត្វសមុទ្រ មានទេសភាពប្រណិតនៅតាមកោះ និងមានឆ្នេរសមុទ្រប្រកបដោយខ្សាច់ស និងទឹកសមុទ្រមានគុណភាព។<br>៣.ឧទ្យានជាតិព្រះសីហនុ «រាម» មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ធម្មជាតិ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃកោងកាង តម្លៃផ្នែកស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីការវិនិយោគផ្នែកទេសចរណ៍ធម្មជាតិ និងឥណទានកាបូនស្តុក តម្លៃផ្នែកផ្លូវនាវាចរណ៍សមុទ្រ តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |

| | | |
|---|---|---|
| | | ធម្មជាតិ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងតំបន់ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែន។ |
| ៩. | **បុទុមសាគរ** ភូមិសាស្ត្រ ខេត្តកោះកុង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិបុទុមសាគរ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង<br>១.សត្វដំរីអាស៊ី ជាតំណាង (Asian Elephant: *Elephas maximus*) និងជាក្រុមប្រភេទថនិកសត្វប្រភេទជិតផុតពូជ និងចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទសត្វជិតផុតពូជនៅលើពិភពលោក ហើយត្រូវបានគេចាត់ថ្នាក់នៅក្នុងឧបសម្ព័ន្ធទី I។ នៅឧទ្យានជាតិបុទុមសាគរ មានសត្វដំរីអាស៊ី ដូចនៅ ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល ដែលមានដំរីរស់នៅតាមព្រៃល្បោះ វាលស្មៅ ព្រៃឫស្សី ព្រៃជាំទឹក តាមដងអូរ ព្រៃពាក់កណ្ដាលស្រោង និងស៊ីសំបក មើម ឫសឈើខ្ចីៗ ទំពាំងឫស្សី និងវល្លិ ផ្លែឈើ អំពៅ ចេកជាដើម។ សត្វដំរីផឹកទឹក ២០០លីត្រ ក្នុងមួយថ្ងៃ និងអាចផ្តល់កំណើតកូនម្តង ក្នុង០១ក្បាល។ ដំរីមេ អាចបង្កើតកូន ៤ ឬ៥ដង ហើយអាចមានអាយុ ៥០-៧០ឆ្នាំ។ ចំពោះផលប្រយោជន៍សត្វដំរីអាស៊ី ក៏បង្ហាញដូចនៅក្នុងឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាលដែរ។<br>២.ពណ៌បៃតងគឺដើមអូគីដេយក្ស និងពណ៌ខៀវ ជាតំណាងទឹក<br>៣.រូបសប្បុរខៀវខ្ចី តំណាងនូវតំបន់ការពារធម្មជាតិ ដែលសម្បូរសម្បត្តិធម្មជាតិ និងជីវៈចម្រុះ ដូចជា ភ្នំ និងកោះដែលមានវត្តមានប្រភេទសត្វសមុទ្រ បង្ករឱ្យប្រជាជនចិញ្ចឹមជីវិតដោយប្រកបមុខរបរនេសាទ ប្រកបរបរចិញ្ចឹមជីវិតរៀងរាល់ថ្ងៃ និងជាតំបន់ដែលសម្បូរជម្រកសត្វព្រៃ។<br>៤.ឧទ្យានជាតិបុទុមសាគរ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃកោងកាង តម្លៃផ្នែកស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីការវិនិយោគផ្នែកទេសចរណ៍ធម្មជាតិ និងឥណទានកាបូន តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ពីការទាញយកធនធានសមុទ្រ និងជីវៈចម្រុះ និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែន។ |
| ១០. | **ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»** ភូមិសាស្ត្រ ខេត្តសៀមរាប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តសៀមរាប<br>១.រូបដើមគូលែន ( Litchi chinensis: *Sapindaceae*) ជាតំណាងប្រទេសខ្មែរ ដែលមានដុះតែនៅលើភ្នំគូលែនទេ ដោយមានកម្ពស់ពី៨-១០ម៉ែត្រ។ ដើមគូលែន ក៏មានដុះនៅប្រទេសចិនភាគខាងត្បូង និងនៅប្រទេសវៀតណាម។ ផ្លែវាយកមកធ្វើជាអាហារ ផ្លែស្រស់មានជីវជាតិ អា (A) និងបេ (B) ជាច្រើន តែផ្លែក្រៀមគ្មានជីវជាតិទាំងនេះទេ។ ចំពោះផ្លែខ្ចី គេប្រើធ្វើជាឱសថសម្រាប់ការព្យាបាលជម្ងឺ ឬកធំ ហើយគ្រាប់ធ្វើថ្នាំពោះវៀន។ គ្រូថ្នាំបុរាណ ស្ងោរផ្កា សំបក និងឫសគូលែនព្យាបាលជំងឺបំពង់ក។ |

២.នៅខាងលើរូបដើមគូលែនមានរូបព្រះពុទ្ធព្រះអង្គធំ ជាតំណាង និងមានរូបធនធានធម្មជាតិ និងជីវៈចម្រុះ ដូចជាភ្នំ និងប្រភពទឹកហូរធ្លាក់ពីលើភ្នំ។ រូបចម្លាក់រូបព្រះពុទ្ធចូលបរិនិព្វាន មានបណ្តោយប្រមាណជិត ២០ម៉ែត្រ)។ ចម្លាក់នេះ ត្រូវបានកសាងឡើងនៅសតវត្សរ៍ទី១៥-១៦ ក្នុងពេលដែលព្រះពុទ្ធសាសនានៅស្រុកខ្មែរមានការរីកចម្រើនរុងរឿង។

៣.ភ្នំគូលែនសម្បូរទៅដោយធនធានធម្មជាតិ និងរូបប្រាសាទ ជាតំបន់វប្បធម៌ និងទីតាំងប្រវត្តិសាស្ត្រជាច្រើនកន្លែង ដូចជា តំបន់ទឹកធ្លាក់ វាលស្តេចគម្លង់ វាលព្រះសពព្រះក្រាល សំពៅធ្លាយ ស្ទឹងលិង្គមួយពាន់ និងមានប្រាសាទតូចៗធ្វើអំពីឥដ្ឋជាច្រើនទៀត ដូចជា ប្រាសាទអ្នកតា ប្រាសាទថ្មដាប់ ប្រាសាទរោងចិន ប្រាសាទបល្ល័ង្ក តំបន់ស្រះដំរី ។ល។ ដែលជាកេរដំណែលនៃស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី២បានកសាងឡើង។ ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ នៅពេលទៅដល់លើខ្នងភ្នំគូលែន តែងតែទៅគោរពបូជានៅទីតាំងរូបចម្លាក់ព្រះពុទ្ធរូបអង្គធំចូលព្រះនិព្វាន ដូច្នេះហើយទើបជ្រើសរើសយក ព្រះអង្គធំចូលព្រះនិពាន្ទ និងទឹកធ្លាក់នៅលើភ្នំគូលែន ព្រមទាំង សម្បូរទៅដោយធនធានបេតិកភណ្ឌវប្បធម៌ដែលមានប្រាង្គប្រាសាទបុរាណជាច្រើន និងរូបបដិមាករជាច្រើននៅគ្រប់ទីកន្លែង ដែលត្រូវបានចាត់ទុកថាជាតំបន់ពិសិដ្ឋ និងស័ក្តិសិទ្ធ និងគោរពបូជា។

៤.ក្រៅពីធនធានវប្បធម៌ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ជាតំបន់មួយសម្បូរបែបទៅដោយធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាគម្របផ្តល់ប្រភពទឹកចំបងបំផុត ជាពិសេសនៅទីកន្លែងទំបន់ ថ្នល់ម្រេច ជារបាំងទឹកមួយដែលធំជាងគេដោយមានបណ្តោយរហូតដល់មួយគីឡូម៉ែត្រ ទទឹងប្រវែងហុកសិបម៉ែត្រ និងកម្ពស់ហុកសិបម៉ែត្រ និងមានកម្ពស់ប្រែប្រួលពីប្រាំទៅដប់ពីរម៉ែត្រសម្រាប់ប្រើប្រាស់នៅទីក្រុងសៀមរាប និងតំបន់ជុំវិញដែលអំណោយផលលើវិស័យកសិកម្ម ក្នុងការលើកកម្ពស់មុខរបរចិញ្ចឹមជីវិតសម្រាប់សហគមន៍មូលដ្ឋាន និងអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនា តភ្ជាប់ពីការទស្សនានៅអង្គរវត្ត និងតំបន់ការពារធម្មជាតិនានា និងរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលចូលរួមចំណែកនូវអត្ថប្រយោជន៍របស់ខេត្ត និងប្រទេសជាតិ ទាំងផ្នែកបរិស្ថាន និងសេដ្ឋកិច្ច។

៥.តាមការសិក្សាស្រាវជ្រាវ និងការវាយតម្លៃស្តីពីប្រភេទជីវៈចម្រុះ (Hayes B.*et al.*,2013) បានឱ្យដឹងថាឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន» ជាតំបន់អាទិភាពមួយនៃតំបន់អេកូឡូស៊ីព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោងដែលមានតម្លៃសេដ្ឋកិច្ចពីកាបូនស្តុក ស្ថិតនៅរយៈកម្ពស់មធ្យម និងទទួលរងអាកាសធាតុ មូសុង ដែលផ្តល់លក្ខខណ្ឌដល់ការលូតលាស់ ជីវៈចម្រុះគ្រប់ប្រភេទ និងបានបង្ហាញថា មានរុក្ខជាតិសរុបចំនួន៧៧៥ប្រភេទសត្វស្លាបចំនួន១៥៨ប្រភេទ ថនិកសត្វចំនួន៤៤ប្រភេទ និងឧរង្គសត្វចំនួន៦០ប្រភេទ។ ដោយឡែកតាមការកត់ត្រាបឋម ឧទ្យានជាតិនេះ មាន

| | | |
|---|---|---|
| | | ត្រីចំនួន១២ប្រភេទ និងប្រចៀវ២៥ប្រភេទដែលតំណាងឱ្យ៤០% នៃប្រភេទប្រចៀវទាំងអស់ក្នុងប្រទេសកម្ពុជា (ប្រចៀវ២៥ប្រភេទក្នុងចំណោមសរុបប្រចៀវ៦៨ប្រភេទ)។ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម«ភ្នំគូលែន» មានសត្វព្រៃចំនួន២៨ប្រភេទ ត្រូវបានកត់ត្រាក្នុងបញ្ជីរបស់អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ដែលជាប្រភេទស្ថិតក្នុងការព្រួយបារម្ភលើការអភិរក្ស និងប្រភេទជិតផុតពូជ ដូចជា ញៀប្រផេះ ទោចម្ពុជ ស្វាព្រាម។ ទាក់ទងនឹងរុក្ខជាតិសិក្សាបឋម ឧទ្យានជាតិមានរុក្ខជាតិ១០ប្រភេទក្នុងចំណោមរុក្ខជាតិ៤០ប្រភេទ ដែលស្ថិតក្នុង បញ្ជីរបស់អង្គការ IUCN។ រុក្ខជាតិទាំងនោះរួមមានប្រភេទរុក្ខជាតិ ដែលទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជាប្រភេទឈើបេង ច័ន្ទក្រឹស្នា ធ្នឹក សុក្រម គគីរ។ល។ ដើមឡើយនៅភ្នំនេះ មានដើមគូលែនព្រៃ (*Litchi chinensis*) ដុះជាច្រើន ហេតុនេះហើយ ទើបគេហៅថា «ភ្នំគូលែន» ដូច្នេះហើយទើបជ្រើសរើសយក ដើមគូលែន ដែលជានិមិត្តរូបភ្នំគូលែន។ |
| ១១. | **វីរៈជ័យ**<br>ភូមិសាស្ត្រ<br>ខេត្តរតនគិរី<br>និងខេត្ត<br>ស្ទឹងត្រែង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិវីរៈជ័យ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី និងមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង<br>១.រូបសត្វស្វាក្រវ៉ាត់ ឬស្វាកន្ទុយស (Douc Langur: *Pygathrix nigripes*) ជារូបតំណាងឧទ្យានជាតិវីរៈជ័យ និងសត្វស្វាក្រវ៉ាត់ ស្ថិតនៅក្នុងប្រភេទសត្វមានដោយកម្រ។ ប្រភេទនេះ ត្រូវបានចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទជិតផុតពូជបំផុតនៅលើពិភពលោក និងត្រូវចាត់ថ្នាក់ក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។ សត្វស្វាក្រវ៉ាត់ឈ្មោល ជាទូទៅមានមាឌធំជាងសត្វញី ហើយទាំងញី និងឈ្មោលមានរោមក្រាស់ដុះពេញលើដងខ្លួន។ ផ្នែកក្បាលមានសម្បុរត្នោតខ្ចីកន្ទុយមានសម្បុរសចាប់ពីគល់រហូតដល់ចុងកន្ទុយ។ រីឯដៃ និងជើងវា មានសម្បុរខ្មៅ។ ផ្ទៃមុខមានសម្បុរលឿងស្រាលដោយមានរោមវែងៗសម្បុរសដុះជុំវិញ លើកលែងតែជុំវិញរង្វង់ភ្នែកទាំងពីរ មានសម្បុរពងមាន់។ ដងខ្លួនមានសម្បុរប្រផេះ និងខាងក្រោមនៃដងខ្លួន មានរោមប្រផេះស្រាលហើយនៅលើថ្ពាស និងផ្នែកខាងក្រោមមានរោមសម្បុរខ្មៅ។ ស្វាកន្ទុយសរស់នៅជាក្រុមដែលមានចំនួន រហូតដល់ជាង ១០ក្បាល។ ជួនកាលទាំងបា មេ និងកូន មានច្រើនរហូតដល់៣០ក្បាល ដែលរស់នៅលើដើមឈើខ្ពស់ៗ ក្នុងព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។ ចំណីអាហាររបស់វាមានដូចជា គ្រាប់ធញ្ញជាតិ (កូទីលេដុង) ត្រួយ ផ្កា និងផ្លែឈើ។<br>២.ពណ៌បៃតងរូបដើមឈើ ពណ៌ខៀវជាភ្នំ និងពណ៌លឿងជាវាលស្មៅធំល្វឹងល្វើយបង្ហាញពីភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាជម្រកថនិកសត្វជិតផុតពូជ មានដូចជា ដំរី ខ្លាឃ្មុំធំ ខ្លាដំបងឬ ខ្លាធំ ខ្លាពពក និងប្រភេទសត្វមួយចំនួនរួមមានខ្លារខិន ខ្លាពពក ខ្លាឃ្មុំតូច ខ្ទីង ស្វាអង្កត់ សំពោចភ្នំ ឬឈ្លុសប្រែង ឈ្លូស ជ្រូកព្រៃ ប្រើសទន្សោង ខ្លាលឿងមាស ខ្លាក្ដិថ្មកែវ ជ្រូកពោន បក្សីសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកង |

| | | |
|---|---|---|
| | | ផ្សេងៗទៀតព្រមទាំងកូនរបស់វា។ រូបសញ្ញាសម្គាល់បង្ហាញអំពីភ្នំ ផ្ទាំងថ្ម និងព្រៃឈើ ដែលជាព្រៃស្រោង ពាក់កណ្ដាលស្រោង និងព្រៃល្បោះ វាលស្មៅ រហូតជាប់ព្រំប្រទល់ប្រទេសឡាវ និងប្រទេសវៀតណាម។<br>៣.ពណ៌ប្រផេះរូបផ្ទះរបស់ជនជាតិដើមភាគតិច ដូចជា ព្រៅ គ្រឹង កាវេត ឡាវ ចារាយ ទំពួន និងកាចក់ បានសាងសង់ផ្ទះ ដោយមានរចនាប័ទ្ម ដូចជាជញ្ជាំង ជណ្ដើរ និងដំបូល មានរចនាបខុសៗគ្នា។<br>៣.ឧទ្យានជាតិវីរៈជ័យ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀងហូរចូលទន្លេសេសាន ទន្លេស្រែពក និងទន្លេមេគង្គក្រោម តម្លៃផ្នែកទេសចរណ៍ធម្មជាតិ និងវប្បធម៌ តម្លៃផ្នែកសិក្សាស្រាវជ្រាវនិងអប់រំ តម្លៃសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្នែកផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែន។ |
| ១២. | **សមុទ្រកោះរ៉ុង**<br>ភូមិសាស្ត្រ<br>ខេត្តកោះកុង<br>និងខេត្ត<br>ព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរឧទ្យានជាតិសមុទ្រកោះរ៉ុង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង និងមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបផែនទីឧទ្យានជាតិសមុទ្រកោះរ៉ុង និងព័ទ្ធទៅដោយទឹកសមុទ្រពណ៌ខៀវ ជាតំណាង និងមានប្រជុំកោះ ដូចជា កោះរុង កោះរុងសន្លឹម កោះកូន កោះតូច កោះតាទៀម កោះម្នាស់ក្រៅ កោះម្នាស់ក្នុង។<br>២.ឧទ្យានជាតិកោះរ៉ុង សម្បូរទៅដោយផ្កាថ្ម និងទេសភាពក្រោមបាតសមុទ្រ ដែលត្រូវរួមគ្នាថែរក្សា និងការពារសោភ័ណភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះលើកោះ និងបរិវេណជុំវិញ។<br>៣.ឧទ្យានជាតិកោះរ៉ុង មានសារៈសំខាន់ និងតម្លៃផ្នែករក្សាធនធានធម្មជាតិ និងជីវៈចម្រុះដែលអាចបង្កើនកិច្ចសហការមិនត្រឹមតែពីគ្រប់ភាគីក្នុងប្រទេស គឺអាចធ្វើសហការជាមួយប្រទេសក្នុងតំបន់ផងដែរ។<br>៤.ឧទ្យានជាតិកោះរ៉ុង ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព រក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ ស្រូបយកកាបូន និងចូលរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ រួមទាំងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| **ខ.ដែនជម្រកសត្វព្រៃ** | | |
| ១. | **លំផាត់**<br>ភូមិសាស្ត្រ<br>ខេត្តរតនគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃលំផាត់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី និងខេត្តមណ្ឌលគិរី<br>១.រូបសត្វត្រយង ( យ៉ង ) ចង្កំកស ( White-shouldered Ibis: *Pseudibis davisioni*) ជាតំណាងដែលជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា និងជាក្រុមប្រភេទបក្សី |

| | | |
|---|---|---|
| | និងខេត្ត មណ្ឌលគិរី | មានដោយកម្រ ដែលស្ថិតក្នុងចំណាត់ជាប្រភេទជិតផុតពូជបំផុតទូទាំងសកលលោក ជាតំណាងសត្វព្រៃទាំងអស់ ដែលប្រើប្រាស់ទីជម្រកជាព្រៃល្បោះ ត្រពាំង បឹង អូរ និងប្រព័ន្ធធនធានទឹកនានាទៀតដែលមានភាគច្រើននៅដែនជម្រកសត្វព្រៃលំផាត់ និងជាគោលដៅរបស់អ្នកទេសចរពេលទៅដល់ដែនជម្រកសត្វព្រៃលំផាត់។<br>២.ពណ៌បៃតងគឺជាព្រៃឈើនៅដែនជម្រកសត្វព្រៃលំផាត់គ្របដណ្ដប់ដោយព្រៃល្បោះប្រមាណជា ៨០% នៃទំហំផ្ទៃដីតំបន់ការពារធម្មជាតិសរុប និងភាគច្រើនជាតំបន់ដីរាបស្មើ ដែលសម្បូរទៅដោយដើមត្បែង គ្រាច ខ្លុង ឈើទាល ផ្ចឹក និងប្រភេទដើមឈើជាច្រើនទៀត ដែលមានតួនាទីយ៉ាងសំខាន់ដល់ភេទសត្វប្រសត្វត្រយងចង្កំកស ត្រយងយក្ស និងសត្វដទៃទៀតធ្វើជាសំបុកពងកូន និងជាទ្រនំរបស់វាផងដែរ។<br>៣.ពណ៌ខៀវជាប្រភពប្រព័ន្ធធនធានទឹក ដូចជា ទន្លេស្រែពក ត្រពាំងធម្មជាតិធំ តូច និងប្រព័ន្ធអូរខ្វាត់ខ្វែងដូចសរសៃឈាមក្នុងនោះ រួមមាន អូរវៃ អូរហោរ អូរទាំងរាំង អូរព្រះ អូររវាក់អូរជើប អូរច្បារ និងអូរខាន់លឿងជាដើម ដែលផ្ដល់ជាប្រភពចំណីយ៉ាងសម្បូរបែប និងភាពពឹងអាស្រ័យរបស់សត្វស្លាបកម្រជាច្រើនប្រភេទ ដូចជាប្រភេទសត្វត្រយងយក្ស ត្រដក់តូច អង្កត់ខ្មៅ និងជាពិសេសសត្វត្រយ៉ងចង្កំកស។<br>៤.ក្រៅពីនេះក្នុងដែនជម្រកសត្វលំផាត់ ក៏មានវាលស្រែរបស់សហគមន៍មូលដ្ឋានដែលជាកន្លែងសម្រាប់ស្វែងរកចំណីរបស់សត្វត្រយងនឹងជាទីតាំងដែលទាក់ទាញទេសចរ និងផលិតស្រូវត្រយ៉ង សម្រាប់បង្កើនជីវភាពសហគមន៍ ដែលមានការចូលរួមពីអ្នកវិនិយោគជាតិ ជម្រុញទីផ្សារនូវផលិតផលទាំងនេះនាំចេញទៅក្រៅប្រទេស។<br>៥.ដែនជម្រកសត្វព្រៃលំផាត់ ក៏មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូន និងតម្លៃផ្ដល់ការងារដល់ប្រជាជនមូលដ្ឋាន។ |
| ២. | **ភ្នំព្រេច** ភូមិសាស្ត្រ ខេត្ត មណ្ឌលគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃលំផាត់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី<br>១.រូបសត្វដំរីឈ្មោល១ក្បាល ញី១ក្បាល និងកូន១ក្បាល (Asian Elephant: *Elephas maximus*) ជាតំណាងដែនជម្រកសត្វព្រៃភ្នំព្រេច និងជាក្រុមប្រភេទថនិកសត្វប្រភេទជិតផុតពូជ និងចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទសត្វជិតផុតពូជនៅលើពិភពលោក ហើយត្រូវបានគេចាត់ថ្នាក់នៅក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វដំរីអាស៊ី និងផលប្រយោជន៍សត្វដំរី មានដូចឧទ្យានជាតិជួរភ្នំក្រវាញ និងឧទ្យានជាតិបុទុមសាគរ។<br>២.រូបពណ៌លឿង គឺជាវាលស្មៅ និងរូបសម្បុរបៃតង ជាតំបន់សម្បូរបែបនូវទីជម្រកសត្វដែលមានគុណភាពល្អសម្រាប់ ប្រភេទថនិកសត្វ សត្វស្លាប មំសាសី និងឧរង្គសត្វ និង |

| | | |
|---|---|---|
| | | ថលជលិក ដែលជិតផុតពូជ និងគំរាមកំហែង ដែលជាប្រភពសម្រាប់សត្វទាំងនោះ ធ្វើពនាចរទៅកាន់តំបន់ការពារធម្មជាតិនានា នៅដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃស្រែពក និងឧទ្យានជាតិអូរយ៉ាដាវ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឦសាន។<br>៣.រូបពណ៌ក្រម៉ៅជាតំបន់ភ្នំនៃដែនជម្រកសត្វព្រៃភ្នំព្រេចគ្របដណ្តប់ដោយ ព្រៃស្រោង ព្រៃពាក់កណ្តាល ស្រោង ព្រៃល្បោះ និងប្រភេទព្រៃផ្សេងៗទៀត។<br>៤.ដែនជម្រកសត្វព្រៃភ្នំព្រេច មានជនជាតិដើមភាគតិច រស់នៅក្នុង និងក្បែរ រួមមានជនជាតិដើមភាគតិចចព្នង ស្មៀង ក្រោល ខ្វូន ទំពួន ចារាយ ចិន ចាម និងខ្មែរ។<br>៥.ដែនជម្រកសត្វព្រៃភ្នំព្រេច ផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍទេសចរធម្មជាតិ និងការលំហែកំសាន្ត និងមើលសត្វព្រៃ ដូចជា ប្រភេទសត្វដំរី សត្វទន្សោង ខ្ទីង រមាំង និងសត្វស្លាបធំៗ ដូចជា ក្ងរយក្ស ក្រៀល ត្រដក់តូច សត្វត្រយងកស និងប្រភេទសត្វក្រក្អោកជាដើម។<br>៦.បន្ថែមជាងនេះទៀត ដែនជម្រកសត្វព្រៃភ្នំព្រេច ជាប្រភពកាបូនស្តុកពីព្រៃស្រោងពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលចូលរួមចំណែករក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៣. | «ព្រៃឡង់»<br>ភូមិសាស្ត្រ<br>ខេត្តស្ទឹងត្រែង<br>កំពង់ធំ<br>ក្រចេះ និង<br>ខេត្តព្រះវិហារ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង កំពង់ធំ ក្រចេះ និងមន្ទីរបរិស្ថានខេត្តព្រះវិហារ<br>១.រូបសត្វខ្ទីង (Gaur: *Bos gaurus*) ជាតំណាងដែនជម្រកសត្វព្រៃ «ព្រៃឡង់» និងជាក្រុមប្រភេទមានដោយកម្រ ដែលមានដង់ស៊ីតេរស់នៅកម្រិតទាប។ សត្វខ្ទីង ត្រូវបានចុះក្នុងបញ្ជីក្រហម របស់អង្គការ IUCN ជាប្រភេទងាយរងគ្រោះថ្នាក់ជាសាកល និងស្ថិតនៅក្នុងឧបសម្ព័ន្ធទីI នៃអនុសញ្ញាសាយតេស។<br>សត្វខ្ទីងមានមាឌធំ ខ្លួនខ្មៅ បូកក្រាស់ លាតសន្ធឹងរហូតដល់ស្មើពាក់កណ្តាលខ្នង។ ចំពោះកខ្លីបន្តិច រាងមាំដោយមានបួរនៅផ្នែកខាងក្រោម និងជើងទាំងបួនចាប់ពីជង្គង់ចុះក្រោមសប្បុរប្រផេះ។ នៅលើថ្ងាសមានរោមវែងសប្បុរប្រផេះ ឬសប្បុរលឿងស្រាល។ កូនរបស់វាមានសប្បុរត្នោតរហូតដល់វាមានអាយុពី៤៥ខែ ទើបក្លាយជាសប្បុរខ្មៅ។ ខ្ទីងញីមានមាឌ និងស្នែងតូចជាងឈ្មោល ហើយពុំសូវមានបូក និងបួរដូចខ្ទីងឈ្មោលទេ។ ស្នែងខ្ទីងមានរាងសំប៉ែតជាងស្នែងទន្សោង ហើយដុះមកមានសប្បុរប្រផេះខៀវ នៅផ្នែកគល់ដុះចេញក្រៅរួចកោងឡើងទៅលើ ដូចទន្សោងដែរ។ ខ្ទីងមានទម្ងន់ពី ៥០០-១០០០ គក្រ។ ខ្ទីងឈ្មោលពេញវ័យមានកម្ពស់ ១.៨៥ម៉ែត្រ និងញី ១.៦០ម៉ែត្រ ហើយខ្ទីងឈ្មោលមានកម្ពស់ខ្ពស់បំផុតរហូតដល់ ២ម៉ែត្រ។ សត្វខ្ទីងអាចរស់នៅបានពីតំបន់ទំនាប |

| | | |
|---|---|---|
| | | ហេតដល់រយៈកម្ពស់ ២០០០ម នៅក្នុងព្រៃស្រោង ព្រៃល្បោះ វាលស្មៅ និងអាចរស់នៅរយៈកម្ពស់ខ្ពស់ជាងទន្សោង។ ជាធម្មតាខ្ទីងចេញរកស៊ី នៅពេលព្រលឹមនិងពេលល្ងាច។ វាចូលចិត្តរស់នៅជាហ្វូង អាហាររបស់វាគឺ ល្បះខ្ទី ទំពាំង ស្មៅ និងវល្លិ៍ជាដើម។ ខ្ទីងញីអាចបង្កើតកូនបាន១បន្ទាប់ពីពពោះរយៈពេលពី៩ខែ។<br>២.រូបពណ៌លឿង និងរូបបៃតងខ្ចីជាវាលស្មៅ និងខាងក្រោយសត្វខ្ទីងមានរូបសប្បុរខ្មៅស្រាល ជាភ្នំ និងសប្បុរបៃតង នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» គឺមានប្រភេទព្រៃឈើជាព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ។ សត្វព្រៃជាច្រើនប្រភេទត្រូវបានកត់ត្រា ក្នុងនោះអ្វីដែលមានវត្តមានច្រើនជាងគេគឺ ប្រភេទសត្វទោចម្ពុជ ទន្សោង និងដំរី។<br>៣.ដែនជម្រកសត្វព្រៃ«ព្រៃឡង់» ជាតំបន់ទីជម្រាលរបស់ស្ទឹងស្ទោងដែលមានរូបខៀវប្រលែត និងជាតំបន់ចូលរួមចំណែកនៃសេដ្ឋកិច្ចពីការស្តុកកាបូន ដោយរតំបន់ទាំងនេះមានព្រៃធម្មជាតិក្រាស់ រួមមានព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលបានចូលរួមចំណែករក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ហើយដែនជម្រកសត្វព្រៃ «ព្រៃឡង់» ក៏មានការតភ្ជាប់ប្រព័ន្ធអេកូឡូស៊ីដែនជម្រកសត្វព្រៃឆែបដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃព្រែកប្រសព្វ ដែនជម្រកសត្វព្រៃសម្បូរដោយផ្ទាល់និងតាមរយៈរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឧត្តរ។ |
| ៤. | ព្រះរការ<br>ភូមិសាស្ត្រ<br>ខេត្តព្រះវិហារ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃព្រះរកា និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ<br>១.រូបសត្វរមាំង (Eld's Deer: Cervus eldii) ជាតំណាងដែនជម្រកសត្វព្រៃព្រះរការ និងជាក្រុមប្រភេទថនិកសត្វជិតផុតពូជ និងមានចុះបញ្ជីក្រហម IUCN ថាជាប្រភេទងាយរងគ្រោះថ្នាក់ ហើយមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។ របាយយរស់នៅចំពោះក្រុម ប្រភេទរមាំង បច្ចុប្បន្នក្នុងប្រទេសកម្ពុជាមានចំនួនច្រើនជាងគេបើប្រៀបធៀបទៅនឹងបណ្តាប្រទេសជិតខាង។ វាមាននៅខេត្តស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ក្រចេះ(មានចំនួនតិចតួច) ខេត្តកំពង់ស្ពឺ បន្ទាយមានជ័យ (អាងត្រពាំងថ្ម) ពោធិ៍សាត់ ឧត្តរមានជ័យ និងសៀមរាប នៅខេត្តព្រះវិហារមានសរុបប្រហែល ១០០ក្បាល។ ប្រភេទនេះគេបានរកឃើញផងដែរនៅប្រទេសឡាវ (មានចំនួនតិចបំផុត) និងកោះហៃណាន។ ដោយឡែក នៅប្រទេសថៃត្រូវបានផុតពូជពីធម្មជាតិ ហើយប្រហែលជាផុតពូជនៅប្រទេសវៀតណាម។<br>ភិនភាគ រមាំងជាថនិកសត្វតិណាសីដែលមានមាឧតូចជាងប្រើស និងធំជាងសត្វឈ្លូសបន្តិច។ ស្នែងរបស់វាមានលក្ខណៈខុសពីស្នែងសត្វប្រើស ដោយនៅផ្នែកគល់នៃស្នែងមានបែកខ្នែង២ មួយស្រួចដុះគ្របលើចិញ្ចើមលយទៅមុខ និងមួយទៀតដុះឡើតទៅលើ |

| | | |
|---|---|---|
| | | រួចពេនចេញមកក្រៅ ហើយកោងឧបទៅមុខ ហើយនៅខាងចុងស្នែង របស់វាមានរាងសំប៉ែត។ ជាទូទៅ វាមានសម្បុរឡើងស្រអាប់ ឬលឿងក្រម៉ៅចាស់មានអុចៗនៅផ្នែកចំហៀងខ្លួន ឯផ្នែកក្រោមពោះ និងកមានសប្បុរស ប៉ុន្តែសម្បុរនេះនៅតែប្រែប្រួលទៅតាមរដូវកាល។ នៅរដូវជម្រុះស្នែង វាមានរោម វែងៗរុំជិតចម្រុះសប្បុរប្រផេះក្រហម និងលឿងក្រមៅភ្ជាប់នឹងគល់ក ដែលមានរោមប្រែងមើលទៅគួរឱ្យគយគន់។<br>សត្វរមាំងជាសត្វមិនសូវផ្អើល វារស់នៅជាហ្វូងពី ១០-១៥ក្បាល។ វាចូលចិត្តរស់នៅតាមវាលទំនាបដែលសម្បូរទៅដោយថ្លុក ឬត្រពាំង វាលស្រែ និងព្រៃល្បោះ។ ចំណីរបស់វាមានដូចជា ស្មៅ ស្បូវ ព្រេច ល្បះរុក្ខជាតិ ស្រូវ និងផ្លែឈើ។ វាជម្រុះស្នែងរាល់ឆ្នាំនៅអំឡុងខែមិថុនាដែលជារដូវកាលសម្បូរចំណីសម្រាប់ការលូតលាស់ស្នែងរបស់វា។ រមាំងញីបន្តពូជនៅចន្លោះខែមីនា ឧសភា ហើយកើតកូនម្តងបាន១ក្បាលបន្ទាប់ពីពពោះរយៈពេល ៦-៨ខែ។<br>ដែនជម្រកសត្វព្រៃព្រះរការ គ្របដណ្តប់ដោយតំបន់ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលបានផ្តល់ទីជម្រកដល់សត្វព្រៃជាច្រើនប្រភេទ រួមមាន ថនិកសត្វចំនួន២៨ប្រភេទ ដែលក្នុងនោះមាន១២ប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក រួមទាំង សត្វខ្ទីង ផងដែរ ស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងមានដោយកម្រនៅកម្ពុជា ដូច្នេះហើយទើបជ្រើសរើសយករូបសញ្ញាសម្គាល់សត្វខ្ទីង។<br>២.រូបសប្បុរបៃតងជាភ្នំ លឿងជាវាលស្មៅ ខៀវខ្ចីជាព្រៃឈើ និងភាពសម្បូរបែបធនធានធម្មជាតិ និងពណ៌ខៀវជាប្រព័ន្ធធនធានទឹក។ ប្រភេទថនិកសត្វទទួលរងការគំរាមកំហែងជាសកលចំនួន ១៩ ប្រភេទ៖ ពង្រូល ទោចម្កុដ ស្វាព្រាម ខ្លាត្រី ដំរីអាស៊ី រមាំង ទន្សោង ឆ្កែព្រៃ សំពោចធំ ស្វាគ្រោស ខ្លាឃ្មុំតូច ខ្លាឃ្មុំធំ សំពោចភ្នំ ឬឈ្លូសប្រែង ប្រើស ស្បូវ ខ្ទីង ខ្លារខិន ខ្លាពពក រញ៉ីភ្លើង រញ៉ីប្រផេះ។<br>៣.ដែនជម្រកសត្វព្រៃព្រះរកា មានប្រភេទបក្សីទទួលរងការគំរាមកំហែងជាសកល ចំនួន ១៥ប្រភេទ៖ ត្មាតផេះត្មាតភ្លើងត្មាតត្នោត ត្រយ៉ងយក្ស ត្រយ៉ងចំកំកស ទាព្រៃស្លាបស ពពូលទឹក ត្រដក់ធំ ក្ងោក ត្រដក់តូចក្រៀល សត្វកស ឬកុកពាក់អំបោះ ឬត្រុំអកខ្មៅជីសើមពពូលក្បាលប្រផេះ ត្រសេះដំរី។<br>៤.តំបន់ដែនជម្រកសត្វព្រះរការ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃសេដ្ឋកិច្ចពីកាបូនស្តុក និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងចូលរួមចំណែករក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ហើយដែនជម្រកសត្វព្រៃព្រះរការ ក៏មានការតភ្ជាប់ |

| | | |
|---|---|---|
| | | ប្រព័ន្ធអេកូឡូស៊ី ដែនជម្រកសត្វព្រៃឆែប ដែនជម្រកសត្វព្រៃ«ព្រៃឡង់» ដោយផ្ទាល់ និងតាមរយៈរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឧត្តរ។ |
| ៥. | ឆែប<br>ភូមិសាស្ត្រ<br>ខេត្តព្រះវិហារ<br>និងខេត្ត<br>ស្ទឹងត្រែង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃឆែប និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ និងមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង<br>១.រូបសត្វទាព្រៃស្លាបស ( White-winged Duck: Cairina scutulata ) ជាតំណាងដែនជម្រកសត្វព្រៃឆែប និងជាក្រុមប្រភេទជិតផុតពូជ និងស្ថិតនៅក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វទាព្រៃស្លាបស មានប្រវែង៦៦-៨១ សង់ទីម៉ែត្រ។ ឈ្មោលមានមាឌធំ ដងខ្លួនជាទូទៅសប្បុរត្នោតចាស់ ក្បាល និងកសប្បុរលាយខ្មៅពញាក់ ចំពុះលឿងដាំ។ ចំពោះញីមានមាឌតូចជាងឈ្មោល ដោយមានសប្បុរស្រដៀងឈ្មោលដែរ។ រូបពណ៌ខៀវព្រៃលែតបង្ហាញពីប្រភពទឹកបឹង អូរ ស្ទឹង និងខៀវបៃតងជាធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែបដូចជា ព្រៃស្រោង និងព្រៃលិចទឹក ដែលសត្វទាព្រៃស្លាបសរស់នៅជាជម្រក។<br>២.ពណ៌បៃតង ក៏បង្ហាញពីព្រៃល្បោះ និងរូបពណ៌ក្រម៉ៅជាភ្នំ។ ព្រៃល្បោះនៅដែនជម្រកសត្វព្រៃឆែប ដុះលូតលាស់ជាផ្នែកជាប់គ្នាធំបំផុត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ តំបន់ព្រៃល្បោះដ៏ធំល្វឹងល្វើយនេះ បានផ្តល់ទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វ ដែលមានថនិកសត្វធំៗចំនួន៣០ប្រភេទត្រូវបានកត់ត្រា ដូចជា រមាំង ដំរី ខ្ទីង ទន្សោងខ្លាខិន ដែលជាប្រភេទទទួលរងការគំរាមកំហែងនៅលើពិភពលោក និងពពួកសត្វស្លាបជាច្រើនប្រភេទ រួមទាំងវត្តមានសត្វទាព្រៃស្លាបស ស្ថិតក្នុងស្ថានភាពរងគ្រោះថ្នាក់ នៅលើពិភពលោក និងជាប្រភេទជិតផុតពូជនៅកម្ពុជា ហើយបច្ចុប្បន្នមានវត្តមានតែនៅក្នុងដែនជម្រកសត្វព្រៃឆែប ប៉ុណ្ណោះ ប្រមាណ៣គូ។ ដូច្នេះហើយទើបជ្រើសរើសយករូបសត្វទាព្រៃស្លាបស ( White-winged Duck: *Cairina scutulata*) ជាតំណាង។ |
| ៦. | តាតៃ<br>ភូមិសាស្ត្រ<br>ខេត្តកោះកុង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វ តាតៃ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង<br>១.រូបសត្វខ្លាឃ្មុំតូច ( ខ្លាឃ្មុំតូច Sun Bear *Ursus malayanus* ) ជារូបសញ្ញាសម្គាល់ដែនជម្រកសត្វព្រៃតាតៃ និងជាក្រុមប្រភេទមានដោយកម្រ។ សត្វខ្លាឃ្មុំ បានចាត់ថ្នាក់ក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វខ្លាឃ្មុំតូច ដែលមានមាឌតូចជាងគេនៅលើពិភពលោកគឺមានទំងន់ ២៧-៦៥ គីឡូក្រាម។ ដងខ្លួនគ្របដណ្តប់ទៅដោយរោមខ្លីក្រាសសប្បុរខ្មៅរលោង លើកលែងតែផ្ទៃមុខមានរោមសប្បុរស និងធ្នូតសប្បុរលឿងខ្ចីរាងអក្សរ (U) នៅក្រោមក ត្រចៀក មូលខ្លី និងមានដានជើងប្រហាក់ប្រហែលនឹងមនុស្សដែរ។ ជីវសាស្ត្រ វាអាចរស់នៅតាមព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង វាជាសត្វពូកែឡើងដើមឈើ និងមានលក្ខណៈជីវសាស្ត្រដូចខ្លា |

| | | |
|---|---|---|
| | | ឃ្មុំធំ ទាំងការបន្តពូជ និងការរកចំណី។ ប្រភេទចំណី រួមមាន សត្វល្អិត ផ្លែឈើ រុក្ខជាតិ ឃ្មុំ ព្រូត ម្រោម និងសត្វកកេរ ព្រមទាំងសត្វស្លាបដូចជាមាន់ព្រៃផងដែរ។ ក្រញ៉ាំជើងមុខទាំង២ អាចកាយដីដំបូក កណ្ដៀរហូតដល់ជម្រៅលិចខ្លួនបាត់។ជាទូទៅវាបង្កើតកូនម្ដងបាន១២ក្បាលក្នុង១ឆ្នាំ ហើយកូនរស់នៅជាមួយមេរហូតដល់ពេញវ័យ។ របាយរបស់វាក៏រស់នៅមានវត្តមាននៅតំបន់ការពារធម្មជាតិខាងកើតទន្លេមេគង្គ តំបន់ការពារធម្មជាតិខាងត្បូងបឹងទន្លេសាប និងតំបន់ការពារធម្មជាតិខាងជើងបឹងទន្លេសាបនៃព្រះរាជាណាចក្រកម្ពុជា។ ពួកវាក៏មានវត្តមានផងដែរ នៅភូមិភាគអាស៊ីអាគ្នេយ៍ កោះស៊ូម៉ាត្រា និងកោះបូណេអូ។<br>រូបពណ៌បៃតង បង្ហាញតំណាងពីភាពសម្បូរបែបនៃធនធានធម្មជាតិ និងជីវៈចម្រុះ និងភ្នំ។ ចំពោះពណ៌ខៀវព្រលែត បង្ហាញពីប្រភពធនធានទឹក ជាទីជម្រាល និងផ្ទៃរងទឹកភ្លៀងសម្រាប់ហូរចូលស្ទឹង អូរព្រែក នៃតំបន់ឆ្នេរ និងសមុទ្រ និងហូរចូលបឹងទន្លេសាប។<br>២.ដែនជម្រកសត្វព្រៃតាតៃនេះ មានអត្ថប្រយោជន៍សំខាន់ណាស់ផ្នែកអភិរក្សជីវៈចម្រុះ ដោយសារតែដែនជម្រកនេះ ស្ថិតនៅចំកណ្ដាលតំបន់អភិរក្សសកល ដ៏សំខាន់មួយក្នុងចំណោមតំបន់អភិរក្សសកលសំខាន់ៗទាំង២០០ នៅលើភពផែនដី និងជាតំបន់ទីជម្រាលត្រូពិចមួយក្នុងចំណោមតំបន់ទីជម្រាលត្រូពិចទាំងបីនៅលើភពផែនដី ហើយដែនជម្រកសត្វព្រៃនេះ មានវត្តសត្វជាង ៥០ប្រភេទ ដែលស្ថិតនៅក្នុងបញ្ជីក្រហមនៃអង្គការ IUCN (មានដូចជាសត្វដំរីអាស៊ី សត្វខ្លាឃ្មុំធំ សត្វខ្លាឃ្មុំតូច សត្វ ទោចម្គុជ សត្វញើ សត្វពង្រូល និងក្រពើភ្នំ ឬក្រពើត្រីជាដើម។<br>៣.ពណ៌ខៀវព្រលែត ជាប្រភពធនធានទឹកស្ទឹងតាតៃតភ្ជាប់នឹងរបៀងអភិរក្សជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិជួរភ្នំក្រវាញ ជាប់នឹងប្រព័ន្ធស្ទឹង ដែលមានសារៈសំខាន់បំផុតនៃដែនជម្រកសត្វព្រៃតាតៃ ព្រមទាំងមានទេសភាពស្រស់ត្រកាល ជាទីកន្លែងដែលមានការទាក់ទាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាកម្សាន្ត។<br>៤.សមុទ្រឈើកោះកុង៖ ដែនជម្រកសត្វព្រៃនេះមានទីជម្រកជាង៨៥%ជាប្រភេទព្រៃស្រោង ពាក់កណ្ដាលស្រោង ហើយក្រៅពីនេះជាប្រភេទព្រៃល្បោះ ព្រមទាំងព្រៃឫស្សី ព្រៃស្នាច់និងព្រៃកោងកាង ដែលជាទីជម្រកសមប្រកបសម្រាប់ប្រភេទសត្វព្រៃ និងជាប្រភពកាបូន។ |
| ៧. | **កែវសីមា**<br>ភូមិសាស្ត្រ<br>ខេត្តមណ្ឌលគិរី<br>និងខេត្តក្រចេះ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃកែវសីមា និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី និងមន្ទីរបរិស្ថានខេត្តក្រចេះ<br>១.រូបសត្វស្វាក្រវ៉ាត់ ឬស្វាគន្ធុយស (Douc Langur: *Pygathrix nigripes* ) ជារូបតំណាងដែនជម្រកសត្វព្រៃកែវសីមា និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ និង |

ត្រូវបានចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទជិតផុតពូជបំផុតនៅលើពិភពលោក និងត្រូវចាត់ថ្នាក់នៅក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។

សត្វស្វាក្រវ៉ាត់ឈ្មោល ជាទូទៅមានមាឌធំជាងសត្វញី ហើយទាំងញី និងឈ្មោលមានរោមក្រាស់ដុះពេញលើដងខ្លួន។ ផ្នែកក្បាលមានសប្បុរត្នោតខ្ចី កន្ទុយមានសប្បុរស ចាប់ពីគល់រហូតដល់ចុងកន្ទុយ។ ចំពោះដៃ និងជើងវាមានសប្បុរខ្មៅ។ ផ្ទៃមុខមានសប្បុរលឿងស្រាលដោយមានរោមវែងៗសប្បុរសដុះជុំវិញលើកលែងតែជុំវិញរង្វង់ភ្នែកទាំងពីរមានសប្បុរពងមាន់។ ដងខ្លួនមានសប្បុរប្រផេះ និងខាងក្រោមនៃដងខ្លួន មានរោមប្រផេះស្រាល ហើយនៅលើថ្ងាស និងផ្នែកខាងក្រោមមានរោមសប្បុរខ្មៅ។ ស្វាកន្ទុយស រស់នៅជាក្រុម ដែលមានចំនួនរហូតដល់ជាង១០ក្បាល។ ជួនកាលទាំងបាមេ និងកូន មានច្រើនរហូតដល់៣០ ក្បាល ដែលរស់នៅដើមឈើខ្ពស់ៗ ក្នុងព្រៃស្រោង និងព្រៃពាក់កណ្ដាលស្រោង។ ចំណីអាហាររបស់វាមានដូចជាគ្រាប់ធញ្ញជាតិ (កូទីលេដុង) ត្រួយឈើ ផ្កាឈើ និងផ្លែឈើ។

២.រូបពណ៌ប្រផេះជាដើមឈើ និងរូបពណ៌ក្រម៉ៅជាភ្នំ ធំល្វឹងល្វើយ ដែលបង្ហាញពីភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាជម្រកថនិកសត្វជិតផុតពូជ មានដំរី ខ្លាឃ្មុំធំ ខ្លាដំបងឬ ខ្លាធំ ខ្លាពពក និងប្រភេទសត្វមួយចំនួន រួមមាន ខ្លារខិន ខ្លាពពក ខ្លាឃ្មុំតូច ខ្ទីង ស្វាអង្កត់ សំពោចភ្នំ ឬឈ្លូសប្រេង ឈ្លូស ជ្រូកព្រៃ ប្រើស ទន្សោង ខ្លាលឿងមាស ខ្លាភ្លឺថ្មកែវ ជ្រូកពោន បក្សីសត្វ បាណកសត្វ និងសត្វឥតឆ្អឹងកងផ្សេងៗទៀតព្រមទាំងកូនរបស់វា។ រូបសញ្ញាបង្ហាញអំពីភ្នំ ផ្ទាំងថ្ម និងព្រៃឈើ ដែលជាព្រៃក្រាស់ជាព្រៃស្រោង ពាក់កណ្ដាលស្រោង និងព្រៃល្បោះ វាលស្មៅ រហូតជាប់ព្រំប្រទល់ខេត្តអាតាពើ ប្រទេសឡាវ និងខេត្តកន្ទុំ និងខេត្តយាឡាយ ប្រទេសវៀតណាម។

២.រូបពណ៌បៃតងបង្ហាញពីភាពសម្បូរបែបនូវធនធានធម្មជាតិ និងជីវៈចម្រុះ រួមមាន ថនិកសត្វ ដើមឈើព្រៃស្រោង ពាក់កណ្ដាលស្រោង និងរុក្ខជាតិ បក្សី ល្មូន មច្ឆជាតិ ថលជលិក សត្វល្អិត ផ្សិត ។ល។ និងមានពណ៌ខ្មៅប្រលែត បង្ហាញពីភូមិសាស្ត្រមានភ្នំ ជ្រលងភ្នំ និងជ្រោះ ដែលជាទីជម្រាល និងជាប្រភពទឹក។

៣.រូបពណ៌ដីដាំ ជាតំណាងផ្ទះជនជាតិដើមភាគតិច ដែលមាននៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ប្រមាណ៨០ % ជាជនជាតិដើមភាគតិចព្នង។ ក្រៅពីនេះមានជនជាតិដើមភាគតិចក្រោល ខ្វន ទំពួន និងចារ៉ាយ និងខ្មែរ។ ការប្រើប្រាស់ដីនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា មានចំនួន ៣២ភូមិ (២០ភូមិ ក្នុងគម្រោងរេដបូក) ស្ថិតនៅក្នុង ៦ឃុំ (ឃុំមេម៉ង់ ឃុំស្រែឈូក ឃុំស្រែខ្ទុម ឃុំស្រែព្រះ ឃុំសែន មនោរម្យ និង១ សង្កាត់ (សង្កាត់រម្យនា) និង១ឃុំ (ឃុំឃ្សឹម) ស្រុកស្នួល ខេត្តក្រចេះ។

៥.រូបពណ៌ផ្ទៃមេឃ ជាតំណាងខ្យល់អាកាសបរិសុទ្ធ ប្រកបដោយសុខុមាលភាពរបស់ប្រជាជន និងជាប្រភពកាបូនស្តុកពីព្រៃស្រោង ពាក់កណ្ដាលស្រោង និងព្រៃល្បោះ

| | | |
|---|---|---|
| | | ដែលចូលរួមរក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ដែលដែនជម្រកសត្វព្រៃកែវសីមាតភ្ជាប់នឹងដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃភ្នំព្រេច។ |
| ៨. | ស្រែពក<br>ភូមិសាស្ត្រ<br>ខេត្ត<br>មណ្ឌលគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃស្រែពក និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី<br>១.រូបសត្វទន្សោង ( Banteng *Boskorus Jananicus* ) ជាតំណាងដែនជម្រកសត្វព្រៃស្រែពក និងជាក្រុមប្រភេទមានដោយកម្រ និងចុះក្នុងបញ្ជីក្រហម របស់អង្គការ IUCN ( ថាជាប្រភេទកំពុងរងគ្រោះថ្នាក់ជិតផុតពូជ )។<br>ទន្សោងក្មេងមានសំប្បុរក្រហមត្នោតស្រាល ហើយវាប្រែប្រួលទៅជាសប្បុរក្រហមត្នោតប្រផេះ ឬក្រហមត្នោតចាស់នៅពេលវាចំណាស់បន្តិច។ ជើងទាំង៤ខាងក្រោមជង្គង់មានសប្បុរសដូចខ្ទីងនិងគោព្រៃដែរ ប៉ុន្តែវាមានចំណុចមួយដែលប្លែកពីគេ គឺសប្បុរសនៅផ្នែកខាងក្រោយត្រង់គូទ។ ស្នែងទន្សោងមានរាងមូលជាងស្នែងខ្ទីង មានសប្បុរលឿងស្រគាំនៅផ្នែកពាក់កណ្តាលចុះក្រោម ហើយចុងស្នែងសប្បុរខ្មៅ។ សត្វទន្សោងចូលចិត្តរកស៊ីនៅតាមមាត់អូរ និងមិនសូវរស់នៅតំបន់មានទីជម្រាលទេ។ សត្វទន្សោងចូលចិត្តនៅជាហ្វូងៗ ឬនៅជាមួយប្រើស ខ្ទីងជាដើម។ ទន្សោងចេញរកស៊ីនៅពេលព្រលឹម និងពេលព្រលប់។ ជាធម្មតាទន្សោងមេចាស់ជាងគេតែងតែជាអ្នកដឹកនាំហ្វូង។ ទន្សោងបន្តពូជនៅខែឧសភាដល់ខែមិថុនា និងអាចបង្កើតកូនបាន ១២ក្បាល បន្ទាប់ពីពពោះរយៈពេល១០ខែ ហើយមេអាចដោយឈ្មោលម្តងទៀតក្រោយពេលកើតកូនបាន២ខែ។<br>រូបពណ៌បៃតងខៀវ និងពណ៌លឿង តំណាងភាពសម្បូរបែបធនធានធម្មជាតិ ជីវៈចម្រុះដូចជា ព្រៃល្បោះ និងវាលស្មៅ ព្រមទាំងព្រៃគម្លោតជាដើម ដែលគ្របដណ្តប់លើស្រុកពេជ្រាដា និងស្រុកកោះញែក ដែលជាប្រភពប្រជាជនប្រើប្រាស់ផល-អនុផលព្រៃឈើ ពីដែនជម្រកសត្វព្រៃស្រែពក។<br>៣.រូបពណ៌ខៀវប្រលែត តំណាងជាទន្លេស្រែពកដែលជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង ដែលជាបណ្តាញប្រព័ន្ធផ្លូវទឹក សម្រាប់ហូរចូលទន្លេសេសាន ទន្លេស្រែពក និងហូរចូលអាងទន្លេមេគង្គក្រោម។ អម្បូរព្រៃឫស្សី ព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោងដែលនៅតាមទន្លេស្រែពក និងជងអូរគឺផ្តល់ជាទីជម្រកសត្វ និងរុក្ខជាតិថែមទាំងជាតំបន់ការពារធម្មជាតិស្តុកកាបូន ដែលចូលរួមថែរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ដែលដែនជម្រកសត្វព្រៃស្រែពកតភ្ជាប់នឹងឧទ្យានជាតិអូរយ៉ាដាវ ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃកែវសីមា និងដែនជម្រកសត្វព្រៃលំផាត់ |

| | | |
|---|---|---|
| | | និងចូលរួមចំណែកក្នុងការការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនជាមួយប្រទេសជិតខាង។ |
| ៩. | **សៀមប៉ាង**<br>ភូមិសាស្ត្រ<br>ខេត្តស្ទឹងត្រែង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃសៀមប៉ាង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង<br>១.រូបសត្វត្មាតភ្លើង (Red-headded Vulture: *Sarcogyps calvus*)ជាតំណាងដែនជម្រកសត្វព្រៃសៀមប៉ាង និងជាក្រុមប្រភេទសត្វស្លាបមានដោយកម្រ និងត្រូវចាត់ថ្នាក់នៅក្នុងបញ្ជីឧបសម្ព័ន្ធទី II នៃអនុសញ្ញាសាយតេស។<br>ជាទូទៅដែនជម្រកសត្វព្រៃនៅសៀមប៉ាង ជាជម្រកដែលមានវត្តមានសត្វត្មាតច្រើនជាងគេនៅទូទាំងប្រទេសកម្ពុជា រួមមាន ត្មាតផេះ ត្មាតត្នោត និងត្មាតភ្លើង។ ក្នុងន័យនេះ សត្វត្មាតភ្លើងជាតំណាងសត្វត្មាតទាំងបីប្រភេទ និងតំណាងឱ្យដែនជម្រកសត្វព្រៃសៀមប៉ាង អាស្រ័យដោយវាមានរូបរាងស្អាតជាងគេ និងមូលហេតុបន្ថែម ដូចខាងក្រោមៈ<br>៣. រូបពណ៌បៃតង និងខៀវខ្ចី តំណាងឱ្យតំបន់នោះសម្បូរបែបដោយធនធានធម្មជាតិ និងជីវៈចម្រុះ ដែលជាជម្រកដល់គ្រប់ប្រភេទសត្វព្រៃ និងសត្វស្លាប ជាពិសេសត្វត្មាតរស់នៅ ម្យ៉ាងវិញទៀតសត្វស្លាបនេះ មានកែវភ្នែកមុតស្រួចអាចសម្លឹង មើលចំណីពីលើអាកាសបានយ៉ាងឆ្ងាយ ជាតំណាងឲ្យចក្ខុវិស័យវែងឆ្ងាយគ្មានដែនកំណត់ក្នុងតំបន់នេះ ហើយជាប្រភេទបក្សីដើរតួនាទីក្នុងការសម្អាតបរិស្ថានដោយវាស៊ីសាកសពសត្វដែល ស្លាប់ក្នុងព្រៃកាត់បន្ថយក្លិនស្អុយ ឬឧស្ម័នកខ្វក់ក្នុងខ្យល់ និងបរិយាកាសដែលធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីមានសុខភាពល្អ និងការពារការរីករាលដាលនៃជម្ងឺផ្សេងៗ ដល់មនុស្ស និងសត្វដទៃទៀត។<br>៤.រូបពណ៌លឿង តំណាងឱ្យវាលស្មៅ និងរូបពណ៌ខៀវប្រលែត តំណាងឱ្យទឹក ដែលដែនជម្រកសត្វព្រៃសៀមប៉ាង មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាលទន្លេសេកុង និងទន្លេមេគង្គខាងក្រោម តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកសិក្សាស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូន តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន តភ្ជាប់នឹងឧទ្យានជាតិវីរៈជ័យ និងតម្លៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនប្រទេសជិតខាងដែលមានភ្នំសប្បុរខ្មៅព្រៃលែត។ |
| ១០. | **«ភ្នំត្នោត-ភ្នំពក»**<br>ភូមិសាស្ត្រ<br>ខេត្តព្រះវិហារ<br>និងខេត្ត<br>សៀមរាប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃ«ភ្នំត្នោត-ភ្នំពក» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ និងខេត្តសៀមរាប<br>១.រូបសត្វក្ងោក ( Green Peafowl: *Pavo muticus*) ជាតំណាងដែនជម្រកសត្វព្រៃ«ភ្នំត្នោត-ភ្នំពក» និងជាក្រុមប្រភេទសត្វស្លាបមានដោយកម្រ និងត្រូវចាត់ថ្នាក់ក្នុងបញ្ជីឧបសម្ព័ន្ធទី II នៃអនុសញ្ញាសាយតេស។ |

| | | |
|---|---|---|
| | | ២.រូបពណ៌បៃតង និងខៀវ ជាតំណាងបង្ហាញថា ដែនជម្រកសត្វព្រៃ «ភ្នំត្នោត-ភ្នំពក» គ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វ ដែលគេបានកត់ត្រាចំនួន ២៦ប្រភេទ ក្នុងនោះមានប្រភេទសត្វមួយចំនួនកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដូចជា ទោចម្កុដ ទន្សោង ស្វាព្រាម ឆ្កែព្រៃ ប្រើស និងមានសត្វស្លាបចំនួន១៤៦ប្រភេទ រួមទាំងសត្វក្ងោក ដែលស្ថិតក្នុងស្ថានភាពរងគ្រោះនៅលើពិភពលោក និងមានដោយកម្រនៅកម្ពុជា ដូច្នេះហើយទើបជ្រើសរើសយករូបសញ្ញាសម្គាល់សត្វក្ងោក និងទេសភាពធម្មជាតិប្រណិត ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះសម្បូរបែប។ រូបពណ៌ខៀវព្រលែត ជាតំណាងទឹក។<br>៣.ដែនជម្រកសត្វព្រៃ«ភ្នំត្នោត-ភ្នំពក» មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង តម្លៃជីវៈចម្រុះ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកសិក្សាស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូន តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំងរក្សានូវលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១១. | «សង្ឃរុក្ខាវ៉ន» ភូមិសាស្ត្រខេត្តឧត្តរមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ៉ន» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ<br>១.រូបសត្វប្រើសស្បូវ (Samba: Cervus unicolor) ជាតំណាងដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ៉ន» និងជាក្រុមប្រភេទសត្វមានដោយបង្គួរ និងសត្វប្រើសត្រូវបានចុះបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទអាស្រ័យលើកិច្ចអភិរក្សនៅតាមតំបន់ដែលវារស់នៅ។<br>ប្រើសស្បូវជាថនិកសត្វតិណាសី ស្ថិតក្នុងអំបូរប្រើសដែលមានមាឌធំជាងគេ។ នៅលើដងខ្លួនមានរោមសប្បុរប្រផេះស្ទើរក្រម៉ៅ និងនៅកមានរោមញឹកវែងសណ្ឋានប្រែង។ កន្ទុយរបស់វាខ្លី សំពោងសប្បុរខ្មៅ និងរស់រវើកជានិច្ចនៅពេលរកចំណី ហើយវាមានស្លឹកត្រចៀកធំ។ ស្នែងប្រើសឈ្មោលពេញវ័យមានប្រវែងពី ៥០-១០០ សង់ទីម៉ែត្រ ដែលមានខ្នែងម្ខាងៗ ចំនួនបី ដែល១នៅជាប់នឹងគល់ និង២នៅខាងចុង។ សត្វទន្សាង អាចរស់នៅគ្រប់ជម្រកទាំងអស់ រួមទាំងព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះ។ សត្វប្រើសស្បូវ រកស៊ីនៅពេលព្រលប់ និងពេលព្រលឹម ហើយសម្រាកនៅពេលថ្ងៃនៅតាមព្រៃក្រាស់ៗ។ ចំណីរបស់វាមាន ដូចជា ចុងមែកឈើតូចៗ ស្លឹកឈើ ប្រភេទវល្លិ៍ពន្លក (ត្រួយ) ផ្លែឈើជ្រុះ និងស្មៅ។ ប្រើសចូលចិត្តស៊ីដីប្រាប ពិសេសប្រើសឈ្មោលដែលកំពុងតែលូតលាស់ស្នែង និងមានជារៀងរាល់ឆ្នាំនៃរដូវកាច់ស្នែងប្រព្រឹត្តទៅក្នុងខែកក្កដា និងខែកញ្ញា។ នៅរដូវបន្តពូជ ប្រើសឈ្មោលតែងតែជល់គ្នាយកឈ្នះចាញ់ ដើម្បី |

| | | |
|---|---|---|
| | | គ្រប់គ្រងតំបន់ និងពាក់ញីដែលនៅក្នុងហ្វូងរហូតដល់ ៨ក្បាល។ ប្រើសញីកើតកូនម្តងតែ១ បន្ទាប់ពីពពោះរយៈពេល៨ខែ។<br>របាយរស់នៅប្រភេទនេះ មានវត្តមាននៅតំបន់ការពារធម្មជាតិខាងជើងទន្លេមេគង្គ តំបន់ការពារធម្មជាតិខាងត្បូងបឹងទន្លេសាប និងតំបន់ការពារធម្មជាតិខាងកើតទន្លេមេគង្គ។ គេក៏បានរកឃើញផងដែរនៅប្រទេសឥណ្ឌា ប្រទេសចិន និងតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ រួមទាំង កោះស៊ូម៉ាត្រា និងបូណេអូ។<br>២.រូបពណ៌ខៀវព្រលែត និងស បង្ហាញពីប្រភពទឹកបឹង និងប្រព័ន្ធធារាសាស្ត្រផ្លូវទឹក ដែលជាទីជម្រាល និងផ្ទៃរងទឹកភ្លៀង។ ចំពោះសប្បុរបៃតងបង្ហាញថា នៅក្នុងដែនជម្រកសត្វព្រៃ «សង្ឃរុក្ខាវ័ន» គ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ ដែលជាទីជម្រកយ៉ាងសំខាន់សម្រាប់ពពួកថនិកសត្វជាច្រើនប្រភេទ រួមទាំង សត្វប្រើស ទន្សោង រមាំង ឆ្កែព្រៃ សំពោចធំ ស្វាត្រោស ខ្លាឃ្មុំតូច ខ្លាឃ្មុំធំ សំពោចត្នំ ឬឈ្លូសប្រែង ប្រើសស្បូវ ខ្ទីង ខ្លារខិន ខ្លាពពក ញើភ្លើង ញើប្រផេះ ដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះថ្នាក់នៅលើពិភពលោក និងមានដោយបង្គួរនៅកម្ពុជា។ ក្រៅពីសត្វព្រៃ និងព្រៃឈើ តំបន់នេះមានទីតាំងប្រាសាទ និងរូងភ្នំមួយចំនួន រួមទាំងឡស្លដែកសម័យបុរាណ ត្រូវបានស្រាវជ្រាវរកឃើញ។<br>៣.ដែនជម្រកសត្វព្រៃ«សង្ឃរុក្ខាវ័ន» មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋានព្រមទាំងរក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១២. | **ភ្នំឱរ៉ាល់**<br>ភូមិសាស្ត្រ<br>ខេត្តកំពង់ឆ្នាំង<br>កំពង់ស្ពឺ និង<br>ខេត្ត<br>ពោធិ៍សាត់ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងមន្ទីរបរិស្ថានខេត្តពោធិ៍សាត់<br>១.រូបសត្វខ្លាឃ្មុំធំ (Asian Black Bear Ursus thibetanus) ជាតំណាងដែនជម្រកសត្វព្រៃឱរ៉ាល់ និងក្រុមប្រភេទសត្វជិតផុតពូជ ដែលត្រូវបានការពារដោយច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ និងបានចុះបញ្ជីក្រហម IUCN (VU) ជាប្រភេទរងគ្រោះហើយបានចាត់ថ្នាក់ក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញា សាយតេស។<br>សត្វខ្លាឃ្មុំធំ មានមាឌធំជាងគេនៅក្នុងក្រុមនៃប្រភេទនេះ។ ដងខ្លួនវាគ្របដណ្តប់ដោយរោមក្រាស់វែងៗ សប្បុរខ្មៅ និងមានធ្នូតសប្បុរលឿងខ្ចីរាងអក្សរ (V) នៅក្រោមក។ ស្លឹកត្រចៀកមានទំហំធំជាងខ្លាឃ្មុំតូច និងមានប្រវែងក្បាល-ដងខ្លួន១២០០-១៥០០ មីលីម៉ែត្រ។ ជាមធ្យមសត្វខ្លាឃ្មុំធំឈ្មោលមានទម្ងន់ ១១០-១៥០គីឡូក្រាម ហើយសត្វញី |

| | | |
|---|---|---|
| | | វិញមានទម្ងន់ ៦៥-៩០គីឡូក្រាម។ ប្រអប់ជើងមានទម្រង់ស្រដៀងនឹងប្រអប់ជើងមនុស្ស។<br>សត្វខ្លាឃ្មុំធំ ជាប្រភេទសត្វរស់នៅឯកឯង និងរស់នៅជាគូនៅរដូវបន្តពូជតែប៉ុណ្ណោះ វាចូលចិត្តរស់នៅទីក្នុងជម្រកតំបន់ខ្ពង់រាប ព្រៃពាក់កណ្ដាលស្រោង និងវាលស្មៅក្រាស់ វាដេកនៅពេលថ្ងៃ តាមប្រហោងគល់ឈើធំៗ រូងភ្នំ ក្រហែងថ្ម វាចេញរកស៊ីនៅពេលយប់ ប៉ុន្តែវាចេញរកស៊ីពេលថ្ងៃផងដែរនៅរដូវផ្លែឈើទុំ។ ចំណីរបស់វាមានឃ្មុំ ព្រួត ឫស្សី សត្វល្អិត រុក្ខជាតិ។ វាមានលក្ខណៈបន្សាំផងដែរទៅនឹងចំណីដែលគេចិញ្ចឹមវា ដូចជា បបរ សណ្ដែក បន្លែ ត្រី សាច់ឆៅ ដូង ។ល។ វាបង្កើតកូនម្ដងបាន១-២ក្បាលបន្ទាប់ពីពរពោះរយៈពេល ៧-៨ខែ ជួនកាលមានកូន ៣-៤ក្បាល តែកម្រមាន។ កូនវានៅជាមួយមេរហូតអាយុ ៣ឆ្នាំ ជួនកាលរហូតដល់មេវាមានកូនបន្ទាប់។<br>របាយរស់នៅរបស់សត្វខ្លាឃ្មុំធំ ទីជម្រកសមស្របរបស់វាគឺព្រៃស្រោង និងពាក់កណ្ដាលស្រោង។ វាមានវត្តមាននៅក្នុងប្រទេសប៉ាគីស្ថាន ភូមា ថៃភាគខាងជើង ឡាវ និងប្រទេសវៀតណាម។<br>២.រូបពណ៌បៃតងប្រលែត ជាតំណាងបង្ហាញអំពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់មានប្រភេទទីជម្រកជាប្រភេទព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃល្បោះ លាយឡំដោយព្រៃឫស្សី វាលស្មៅ និងមានស្ទឹង អូរ និងជាប្រភពទឹកផ្សេងៗ ដែលជាទីជម្រកប្រសើរសម្រាប់សត្វព្រៃ ពិសេសពពួកថនិកសត្វដូចជា៖ ដំរីអាស៊ី សត្វខ្លាឃ្មុំធំ សត្វខ្លាឃ្មុំតូច សត្វទោចម្ដុជ សត្វរញ្ជៀ ខ្ទីង ឈ្លូស ប្រើស ឆ្កែព្រៃ ខ្លាពពក និងពពួកសត្វស្លាប និងល្មូនសំខាន់ៗ ផ្សេងៗទៀត។ ខ្លាឃ្មុំធំជាប្រភេទសត្វកម្រនៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះដែរ ដែនជម្រកសត្វព្រៃឱរ៉ាល់ មានវត្តមានសត្វស្លាបជាច្រើនប្រភេទ តែមិនទាន់បានកំណត់ប្រភេទនៅឡើយ។<br>៣.រូបរាងកោងពណ៌ខ្មៅ ជាតំណាងភ្នំឱរ៉ាល់ ដែលជាភ្នំ មានកម្ពស់ខ្ពស់ជាងគេនៅក្នុងប្រទេសកម្ពុជា ដែលមានកម្ពស់រហូតដល់១៨១៣ម ហើយតំបន់នេះក៏ជាតំបន់ដែលមានទេសភាពស្រស់ត្រកាល និងខ្យល់អាកាសត្រជាក់អាចជាកន្លែងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាកម្សាន្ត។<br>៤.តំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាលតម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ និងតម្លៃសេដ្ឋកិច្ចពីឥណទានកាបូន តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្ដល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំងរក្សានូវលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៣. | ពាមក្រសោប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃពាមក្រសោប និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង |

| | | |
|---|---|---|
| | ភូមិសាស្ត្រ ខេត្តកោះកុង | ១.រូបសត្វផ្សោតច្រមុះកខ្លី និងវែង (Indo-Pacific/Common Bottlenose Dolphin: Tursiops aduncus/Tursiops truncatus) ជាតំណាងដែនជម្រកសត្វព្រៃពាមក្រសោប ព្រមទាំងមានស្ពានឆ្លងកាត់។<br>២.រូបពណ៌ខៀវ បង្ហាញអំពីព្រៃកោងកាង បាន និងកំពុងចូលរួមចំណែកយ៉ាងធំធេងនូវមុខងាររក្សាបរិស្ថានឆ្នេរ បង្កើនទិន្នផលត្រី វារីវប្បកម្មប្រកបដោយនិរន្តភាព និងជាប្រភពកាបូនស្តុកផងដែរ ជាពិសេសការពារឆ្នេរ ឬផ្តល់ជម្រកដល់ធនធានជលផល នៅតាមបណ្តាខេត្តកែប កំពត ព្រះសីហនុ និងខេត្តកោះកុង។<br>៣.ថែមពីនេះទៀត តម្លៃនៃធនធានព្រៃកោងកាងបានផ្តល់ឱ្យនូវអាហារ ឱសថ សម្ភារៈសំណង់ និងឧបករណ៍នេសាទ និងឧបករណ៍ប្រើប្រាស់នានា។ ជាមួយគ្នានេះដែរព្រៃកោងកាងជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ ហើយផ្តល់ជាជម្រកសត្វព្រៃ កន្លែងពងកូនរបស់មច្ឆជាតិ និងជីវៈចម្រុះគ្រប់ប្រភេទរួមមាន៖ បង្គា ក្តាម ខ្យង គ្រុំ សត្វស្លាប ថនិកសត្វ និងអណ្តើក និងជាទីកន្លែងលំហែរ កម្សាន្ត របស់ទេសចរជាតិ និងអន្តរជាតិ ការសិក្សាស្រាវជ្រាវ និងជំនឿសាសនាផងដែរ។<br>៤.រូបពណ៌ស និងពណ៌ខៀវ បង្ហាញពីទឹក ជោរ-នាច ដែលមានសារៈសំខាន់ បាននាំល្បាប់កក់ហូរចេញ-ចូលតាមរយៈជំនោរនៃទឹកសមុទ្រហើយប្រព័ន្ធឫសរបស់កោងកាងបានស្ទាក់យកដីល្បាប់កក់ទាំងនោះមិនឱ្យលេកសមុទ្រនាំយកទៅបាន។<br>៥. រូបស្ពានយោល ដែលបំរើដល់វិស័យទេសចរណ៍ធម្មជាតិ។ ដែនជម្រកសត្វព្រៃពាមក្រសោប មានព្រៃកោងកាង ដែលត្រូវបានទទួលស្គាល់ទូលំទូលាយនៅបណ្តាប្រទេសលើពិភពលោក ហើយប្រទេសកម្ពុជា បានចូលរួមចំណែកក្នុងការការពារ និងថែរក្សា និងដាំស្តារព្រៃកោងកាងឡើងវិញ ស្របតាមអនុសញ្ញាស្តីពីជីវៈចម្រុះ អនុសញ្ញា រ៉ាមសារ និងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ |
| ១៤. | ភ្នំសំកុស ភូមិសាស្ត្រ ខេត្តកោះកុង បាត់ដំបង និង ខេត្ត ពោធិ៍សាត់ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃភ្នំសំកុស និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តខេត្តកោះកុង ខេត្តបាត់ដំបង និងមន្ទីរបរិស្ថានខេត្តពោធិ៍សាត់<br>១.រូបសត្វកែះ (Southern Serow *Naemorhedus sumatraensis*) ជាតំណាងដែនជម្រកសត្វព្រៃសំកុស និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ និងជាប្រភេទសត្វដែលមានដង់ស៊ីតេនៅកម្រិតទាបដោយគេកម្រឃើញវាមានរស់នៅតាមតំបន់ទំនាបវាលស្មៅ ដូចសត្វទំពារដទៃទៀតណាស់។ សត្វកែះត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ថាជាប្រភេទងាយរងគ្រោះថ្នាក់ជាសកល និងស្ថិតក្នុងឧបសម្ព័ន្ធទី I របស់អនុសញ្ញាសាយតេស។ |

| | | |
|---|---|---|
| | | សត្វកែះមានសម្បុរខ្មៅប្រផេះ និងរោមវែងៗស្តើង ដែលមានដងខ្លួនខ្លី ហើយមានជើងទាំង៤របស់វាវែង។ ផ្នែកខាងលើដងខ្លួនសម្បុរខ្មៅ និងផ្នែកខាងក្រោមនៃជើងចាប់ពីក្បាលជង្គង់ចុះមានសប្បុរចម្រុះខ្មៅ ប្រផេះ លឿង។ នៅលើពំនូលក្បាលរហូតដល់ ស្មារបស់វាមានរោមរឹងវែងៗសណ្ឋានដុជាប្រែង។ បបូរមាត់សប្បុរស ហើយផ្នែកខាងក្រោមមានសប្បុរលឿងឬសប្បុរស ត្រចៀកវាវែងត្រង់ទៅលើ។ វាមានស្នែងដូចសត្វពពែដុះកោងទៅក្រោយបន្តិច ប្រវែងប្រហែល ២៨០មីលីម៉ែត្រ សប្បុរខ្មៅ និងមានគន្លាក់ៗជារង្វង់នៅផ្នែកគល់។ កន្ទុយខ្លី ហើយមានរោមសំពោងសប្បុរខ្មៅប្រផេះ។<br>សត្វកែះចូលចិត្តរស់នៅតំបន់ព្រៃភ្នំ ជ្រលង ផ្ទាំងថ្មខ្ពស់ៗ ដែលមានគម្របព្រៃ និងមានស្រទាប់រុក្ខជាតិក្រាស់។ កែះមានជើងយ៉ាងចំណាប់ ក្នុងការឡើងតាមផ្ទាំងថ្មចោតៗ។ នៅពេលថ្ងៃវាចូលចិត្តសម្រាកតាមគម្លោតព្រៃក្រាស ហើយចេញរកស៊ីនៅពេលព្រលឹម ឬក្បាលព្រលប់។ វាចូលចិត្តស៊ីស្លឹករុក្ខជាតិ និងល្បះគ្រប់ប្រភេទ។ សត្វកែះចូលចិត្តយករូងភ្នំរាក់ៗធ្វើជាទីជម្រករបស់វា ហើយគេអាចសម្គាល់វត្តមានវាដោយសារគំនរលាមក។ ដោយសារកែះជាសត្វដែលមានភាពរហ័សរហួន និងពូកែស្រង់ក្លិន ភ្នែកពូកែ និងរស់នៅតាមទីជម្រកស្ងាត់ ដូចនេះគេកម្រជួបប្រទះវាណាស់។ រដូវបន្តពូជមាននៅខែតុលា និងខែធ្នូ ហើយកើតកូនបាន១ ជួនកាលភ្លោះមានដោយកម្រ បន្ទាប់ពីពពោះរយៈពេល៧ខែ។ កូនរស់នៅជាមួយមេវាស្ទើរពេញ១ឆ្នាំទើបចាកចេញ។<br>២.រូបពណ៌ខៀវប្រលែត ជាតំណាងធនធានធម្មជាតិ និងរូបខ្សែពណ៌ខ្មៅបង្ហាញពីភ្នំដែលសម្បូរបែបនៃធនធានធម្មជាតិ ជីវៈចម្រុះ និងភ្នំ ជ្រលងភ្នំ ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំសំកុសគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងវាលស្មៅដែលបានផ្តល់ទីជម្រកយ៉ាងសំខាន់ដល់ពពួកថនិកសត្វធំៗ រួមមាន ដំរី ខ្ទីង ទន្សោងរមាំង ខ្លាឃ្មុំ ប្រើស ឈ្លូស កែះ ឆ្កែព្រៃ ខ្លាត្រី ទោចម្កុដ និងខ្លារខិន និងមានសត្វល្មូន និងអវង្គសត្វ។<br>៣.ដែនជម្រកសត្វព្រៃភ្នំសំកុស មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ ជាពិសេសផ្ទាំងថ្មភ្នំ និងធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធានវប្បធម៌ ដូចជា ទីកន្លែងគោរពបូជាដ៏ស័ក្តិសិទ្ធិតាមជំនឿរបស់ជនជាតិដើមភាគតិចពួងជាច្រើនជំនាន់មកហើយ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះតភ្ជាប់តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត ឧទ្យានជាតិក្រវាញកណ្តាល និងដែនជម្រកសត្វព្រៃពាមក្រសោប។ ក្នុងន័យនេះ ក៏បង្ហាញពីសារៈសំខាន់និងតម្លៃរបស់ដែនជម្រកសត្វព្រៃសំកុស គឺក៏ចូលរួមចំណែករក្សាលំនឹងបរិស្ថាន ការការពារ |

| | | |
|---|---|---|
| | | និងអភិរក្សធនធានធម្មជាតិ និងរួមវិណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៥. | **គូលែន-ព្រហ្មទេព** ភូមិសាស្ត្រ ខេត្តសៀមរាប ព្រះវិហារ និង ខេត្ត ឧត្តរមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថាន ខេត្តសៀមរាបព្រះវិហារ និង មន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ<br>១.រូបសត្វត្រយ៉ងយក្ស ឬឪលើក ឬក្ងយក្ស (Giant Ibis: Pseudibis gigantea) ជាតំណាងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព។ សត្វត្រយ៉ងយក្ស ឬឪលើក ឬក្ងយក្ស មានប្រវែងពី១០២-១០៦,៥ សង់ទីម៉ែត្រ ដែលមានមាឌធំ សំបុរក្រម៉ៅប្រផេះ ជើងវែងក្រហម ក្បាល និងកមួយផ្នែកត្រងោលសប្បុរប្រផេះ និងមានឆ្នូតអង្គន់ៗខ្មៅ និងចំពុះវែងកោងឧប។ ទីជម្រករបស់សត្វត្រយ៉ងយក្ស ឬឪលើក ឬក្ងយក្ស គឺនៅព្រៃល្បោះ ព្រៃលិចទឹក និងតំបន់ដីសើម។ ប្រភេទសត្វនេះ ជាសត្វជិតផុតពូជរស់នៅក្នុងទីស្ងាត់កំបាំង ចូលចិត្តយំពេលព្រឹកព្រលឹម ពេលល្ងាច និងព្រលប់។ ការបន្តពូជរបស់ សត្វត្រយ៉ងយក្ស ឬឪលើក ឬក្ងយក្ស ចាប់តាំងពីខែមិថុនា ដល់ខែកញ្ញា ដែលមានពងភាគច្រើនចំនួន ពី១-២គ្រាប់។<br>២.រូបពណ៌បៃតង តំណាងធនធានធម្មជាតិ និងជីវៈចម្រុះ និងពណ៌ក្រម៉ៅ ជាភ្នំដែលគ្របដណ្តប់ដោយព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងវាលស្មៅលិចទឹកតាមរដូវកាល ដែលបានផ្តល់ទីជម្រកយ៉ាងសំខាន់ដល់ពពួកថនិកសត្វធំៗ រួមមាន ដំរី ខ្ទីង ទន្សោង រមាំង ខ្លាឃ្មុំ ប្រើស ឈ្លូស កែះ ឆ្កែព្រៃ ខ្លាត្រី ទោចម្កុដ និងខ្លាដំបង។ល។<br>៣.រូបពណ៌ខៀវប្រលែត តំណាងជាប្រភពទឹក ដែលមានស្ទឹងស្ទោង និងប្រភពប្រព័ន្ធធនធានទឹក។ ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានថនិកសត្វសរុបចំនួន៤០ប្រភេទ ក្នុងនោះមាន២ប្រភេទជាប្រភេទជិតផុតពូជ១៥ប្រភេទ ជាប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក និងមាន១៣ប្រភេទជាប្រភេទដែលមានដោយកម្រនៅក្នុងប្រទេសកម្ពុជា និងមានសត្វស្លាបជាង២៨០ប្រភេទ ដែលមាន១៧ប្រភេទជាប្រភេទកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក រួមទាំងសត្វ ត្រយ៉ងយក្ស ដែលស្ថិតក្នុងស្ថានភាពជិតផុតពូជនៅលើពិភពលោក និងនៅកម្ពុជា ហើយជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដូច្នេះហើយទើបជ្រើសរើសយក រូបសត្វត្រយងយក្សឬឪលើក ឬក្ងយក្ស ជាតំណាងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព។<br>៤. ជាមួយគ្នានេះដែរ ដែនជម្រកសត្វព្រៃលែន-ព្រហ្មទេព មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល និងស្ទឹងស្ទោង ជាអាងផ្ទៃរងទឹកភ្លៀង តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ និងតម្លៃធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធាន វប្បធម៌ ដូចជាទីកន្លែងគោរពបូជាដ៏ស័ក្តិសិទ្ធិតាមជំនឿ របស់ជនជាតិដើមភាគតិចជាច្រើនជំនាន់មកហើយ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជន |

| | | |
|---|---|---|
| | | មូលដ្ឋាន និងកិច្ចសហការជាមួយតំបន់ការពារធម្មជាតិផ្សេងៗទៀត ភ្ជាប់ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម-ភ្នំគូលែន តាមរយៈរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិឧត្តរ និងដែនជម្រកសត្វព្រៃព្រះរការ។ សារៈសំខាន់ និងតម្លៃរបស់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ក៏បានចូលរួមរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៦. | **បឹងពែរ**<br>ភូមិសាស្ត្រ<br>ខេត្តកំពង់ធំ<br>ព្រះវិហារ និង<br>ខេត្តសៀមរាប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃបឹងពែរ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ធំ ព្រះវិហារ និងមន្ទីរបរិស្ថានខេត្តសៀមរាប<br>១.រូបសត្វស្វាព្រាម ( Silver langur: Trachypithecus germaini ) ជាតំណាងដែនជម្រកសត្វព្រៃបឹងពែរ និងជាក្រុមប្រភេទថនិកសត្វមានដោយបង្គួរ និងត្រូវបានចុះបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទកំពុងរងគ្រោះថ្នាក់។<br>ស្វាព្រាមមានសប្បុរខ្មៅប្រផេះពាសពេញលើដងខ្លួន។ ផ្ទៃមុខមានសប្បុរខ្មៅគ្មានរង្វង់កងព័ទ្ធជុំវិញភ្នែកទេ។ ផ្នែកច្រមុះ និងមាត់មានសប្បុរស-ប្រផេះ។ ស្វាព្រាមមានដុះកញ្ចុំពុកមាត់វែងសប្បុរស ដុះជុំវិញផ្ទៃមុខស្ទើរតែ លុបបាត់ត្រចៀក។ រោមក្បាលដុះវែងកញ្ចុំខ្ពស់ ហើយកាន់តែវែងទៅៗចំពោះស្វាចាស់។ កូនស្វានៅតូចមាន សប្បុរទឹកក្រូចខ្ចី មានប្រអប់ដៃមនិងប្រអប់ជើងសប្បុរខ្មៅ និងគ្មានរោមកញ្ចុំនៅលើក្បាលដូចស្វាចាស់ទេ។ នៅពេលពេញវ័យ វាប្រែសប្បុររោមប្រផេះ ដែលដុះលាតសន្ធឹងរាលដល់ប្រអប់ជើង និងកន្ទុយហើយការប្រែ សប្បុរនេះចាប់ផ្តើមក្រោមអាយុ៣ខែ។ វាមានសប្បុរប្លែកគ្នាជាច្រើនអាស្រ័យតាមតំបន់ដូចជា តំបន់ក្បែរមាត់ទន្លេ ស្ទឹង តំបន់វាលកក់ តំបន់ព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង។<br>ស្វាព្រាមត្រូវបានគេប្រទះឃើញនៅព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងតំបន់ឆ្នេរព្រៃកោងកាង។ ពួកវារស់នៅលើដើមឈើ ហើយអាចចុះដីម្តងម្កាលដើម្បីរត់លេងនិងស៊ីដីប្រាបមានសារធាតុខនិជ។ ចំណីអាហាររបស់វាមានត្រួយឈើ មើម ផ្លែឈើខ្ចី (ផ្លែកកោះត្រសេក) ផ្កា និងសត្វល្អិតផងដែរ។។ វារស់នៅជាក្រុមមានចំនួនពី ១០-៤០ក្បាល ឬច្រើនជាងនេះ ហើយជួនកាលពួកនេះក៏រស់នៅក្នុងព្រៃរួមគ្នាជាមួយសត្វទោចដែរ។ វាជាសត្វចូលចិត្តភាពស្ងប់ស្ងាត់បំផុត។ វាកើតកូនក្នុងអំឡុងខែធ្នូ រហូតដល់ខែឧសភា។<br>របាយរស់នៅ ស្វាព្រាមក៏មានវត្តមាននៅតំបន់ជួរភ្នំក្រវាញ តំបន់ជុំវិញបឹងទន្លេសាប ភូមិភាគខាងជើងបឹងទន្លេសាប និងព្រំប្រទល់កម្ពុជា វៀតណាម។ វាក៏មានវត្តមានផងដែរនៅភាគខាងត្បូងប្រទេសចិន ភូមា រហូតទៅដល់ភាគខាងត្បូងឥណ្ឌូចិន និងភាគខាងត្បូងប្រទេសថៃ។ |

| | | |
|---|---|---|
| | | ២.រូបពណ៌ខៀវខ្ចី និងពណ៌បៃតង តំណាងឱ្យភាពសំបូរបែបព្រៃឈើ សត្វព្រៃ ភ្នំ ដែលជាទីជម្រកនូវវត្តមានថនិកសត្វធំៗមួយចំនួន ដូចជា ទន្សោង ខ្លាឃ្មុំ ប្រើស ឈ្លូស ហើយសត្វស្លាបមានដូចជា ត្រដក់ធំ ត្រយ៉ងយក្ស និងត្រយងចង្កំកស។<br>៣.រូបពណ៌ខៀវប្រលែត តំណាងឱ្យទឹក ជាប្រភពទីជម្រាល និងប្រភពស្ទឹងស្ទោង ដែលហូរចូលបឹងទន្លេសាប។<br>៤.សត្វស្វាព្រាម ជាប្រភេទជិតផុតពូជនៅលើពិភពលោក និងត្រូវបានចាត់ថ្នាក់មានដោយបង្គួរនៅកម្ពុជា ប៉ុន្តែបច្ចុប្បន្ន ចំនួនស្វាព្រាម បានថយចុះយ៉ាងខ្លាំងនៅលើពិភពលោក និងនៅកម្ពុជា ដោយកត្តានៃការបាត់បង់ទីជម្រក ដោយសកម្មភាពមនុស្ស ដូច្នេះហើយទើបជ្រើសរើសយករូបសញ្ញាសម្គាល់សត្វស្វាព្រាម។ សារៈសំខាន់ និងតម្លៃរបស់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព បាន និងកំពុងចូលរួមរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៧. | **ភ្នំណាមលៀរ**<br>ភូមិសាស្ត្រ<br>ខេត្ត<br>មណ្ឌលគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរដែនជម្រកសត្វព្រៃភ្នំណាមលៀរ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី<br>១.រូបសត្វខ្លាពពក ( Clouded Leopard*: Neofelis nebulosa*) ជាតំណាងដែនជម្រកសត្វព្រៃណាមលៀរ និងជាក្រុមប្រភេទថនិកសត្វជិតផុតពូជ និងត្រូវបានចុះបញ្ជីក្រហមរបស់អង្គការ IUCN និងមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>ខ្លាពពក មានមាឌធំជាងខ្លាក្តីថ្មកែវ ដែលមានសម្បុរក្រម៉ៅប្រផេះ។ នៅលើដងខ្លួនមានផ្ទាំងដូចពពកធំៗ នៅផ្នែកខាងក្រោយនៃផ្ទាំងនេះ មានសប្បុរខ្មៅខ័ណ្ឌជាកំណាត់ជុំផ្ទាំងនីមួយៗ។ ជុំផ្ទាំងនេះរីកធំនៅផ្នែកខាងក្រោយស្មា ដែលចាប់ផ្តើមពីលើខ្នងរហូតស្ទើរដល់ក្រោមពោះ។ ច្រមុះមានសប្បុរស និងនៅលើថ្ពាសមានស្នាមអុចតូចៗ។ ខ្លាពពក មានកន្ទុយវែង អុចៗនៅផ្នែកខាងគល់ និងបន្ទះៗនៅផ្នែកខាងចុង។ វាមានជើងខ្លី និងប្រអប់ជើងធំងាយស្រួលក្នុងការប្រតោងមែកឈើ។ ខ្លាពពក នៅលើដងខ្លួនវា មានផ្ទាំងជុំសណ្ឋានដូចពពករាយពាសពេញដងខ្លួន។ ខ្លាពពកចូលចិត្តរស់នៅក្នុងព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃចម្រុះ។ខ្លាពពកជាសត្វរាត្រីចរ ច្រើនរស់នៅជាគូលើដើមឈើ។ ជាធម្មតា វាចាប់ចំណីដោយលោតពីលើដើមឈើ សង្គ្រប់ទៅលើសត្វនៅដី ដូចខ្លារខិនដែរ។ អាហាររបស់ខ្លាពពក មានបក្សី ពស់ ជ្រូកព្រៃ ឈ្លូស ប្រើស និងស្វាជាដើម ដោយប្រើក្រញាំជើងមុខមុតស្រួច សម្រាប់សង្កត់ចាប់ចំណី រួចទើបខាំជាក្រោយ។ ខ្លាពពកអាចបង្កើតកូនម្តង បានពី២-៤ក្បាល បន្ទាប់ពីពពោះអស់រយៈពេលប្រហែល ៩០-៩៥ថ្ងៃ។<br>ខ្លាពពក ក៏មានវត្តមាននៅតំបន់ការពារធម្មជាតិខាងកើតទន្លេមេគង្គ តំបន់ការពារធម្មជាតិខាងត្បូងបឹងទន្លេសាប និងតំបន់ការពារធម្មជាតិខាងជើងបឹងទន្លេសាប។ |

| | | |
|---|---|---|
| | | ប្រភេទសត្វខ្លាពពក ត្រូវបានរកឃើញនៅប្រទេសប៊ូតាន ចិន ឥណ្ឌា ឥណ្ឌូនេស៊ី (កោះស៊ូម៉ាត្រា) ឡាវ ម៉ាឡេស៊ី សារ៉ាវ៉ាក់ ភូមា នេប៉ាល់ ថៃ និងប្រទេសវៀតណាម។ ខ្លាពពក បានផុតពូជនៅប្រទេសបង់ក្លាដេស សឹង្ហបូរី និងប្រទេសតៃវ៉ាន់។<br>២.រូបពណ៌ខ្មៅ ជាផ្ទាំងថ្មភ្នំយ៉ាងធំ និងមានភ្នំក្របដណ្តប់ដោយមានព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង និងមានសសរថ្មធម្មជាតិជាច្រើនផ្ទាំងរាប់ពាន់ដើមមានមុខកាត់ចាប់ពី ៤០សង់ទីម៉ែត្រ និងប្រវែងរហូតដល់ ៦០សង់ទីម៉ែត្រ ដូចប្រាសាទបុរាណ និងផ្ទាំងថ្មធំរាងទ្រវែង និងគ្របដណ្តប់ដោយព្រៃឈើ ដូចជាដើមរកា ដើមជ្រៃលាក នាងនួន ធ្នង់ ស្រឡៅ ឈើទាល ដើមឫស្សី និងប្រភេទឈើផ្សេងៗនៅតំបន់នោះដែរ។<br>៣.រូបពណ៌ស ជាប្រភពទឹកជម្រាលដែលផ្តល់ទឹកដល់ទន្លេស្រែពក។ ដែនជម្រកសត្វព្រៃណាមលៀរ មានទីជម្រកសម្រាប់សត្វព្រៃ ដូចជា ក្តាន់ញ៉ែង ឈ្លូស ជ្រូកព្រៃ សំពោចផ្ទារបា និងសត្វកេងកង ព្រមទាំងមានសក្តានុពលទឹកធ្លាក់ដ៏ស្រស់បំព្រង។<br>៤. ដែនជម្រកសត្វព្រៃភ្នំណាមលៀរ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ជាពិសេសផ្ទាំងថ្មភ្នំ និងធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធានវប្បធម៌ ដូចជាទីកន្លែងគោរពបូជាដ៏ស័ក្តិសិទ្ធិតាមជំនឿ របស់ជនជាតិដើមភាគតិចព្នង តម្លៃផ្នែកធនធាន ព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនក្នុងក្របខ័ណ្ឌតំបន់ត្រីកោណអភិវឌ្ឍន៍ (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)។ |
| ១៨. | «ព្រែកប្រសព្វ» ភូមិសាស្ត្រ ខេត្តក្រចេះ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ដែនជម្រកសត្វព្រៃព្រែកប្រសព្វ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តក្រចេះ<br>១.រូបសត្វក្តាន់ (Hog Deer: Axis porcinus) ជាតំណាងដែនជម្រកសត្វព្រៃ«ព្រែកប្រសព្វ» និងជាក្រុមប្រភេទថនិកសត្វជិតផុតពូជ និងត្រូវបានចុះបញ្ជីក្រហមជាប្រភេទថនិកសត្វជិតផុតពូជជាសកលដោយអង្គការសហភាពអន្តរជាតិ (IUCN)។<br>២.រូបពណ៌បៃតងជាតំណាងភាពសម្បូរបែបដោយធម្មជាតិ ភ្នំ និងជីវៈចម្រុះ ដូចជាសត្វក្តាន់ សត្វស្វាព្រាម ស្វាក្តាម ឬស្វាស្រេវ កំប្រុកផ្លុតខ្នង កំប្រុកសប្បុរ កំប្រុកធំ កង្ហិចកម្ពុជា ឆ្កែព្រៃ ស្កាតូច ផ្សោតទន្លេ កន្ទីក ទន្សាយគល់ ជ្រូកព្រៃ ជ្រើង រមាំង សំពោចធំ សំពោចក្រអូប ក្តាន់ញ៉ែងតូច ឬផ្ទងតូច ឈ្លូស ប្រើស ខ្ទីង និងពពួកខ្លាដែលមានមាឌតូច (ឆ្មាដាវ) និងត្រយ៉ងចង្កំកស។ តំបន់នេះ មានក៏មានសត្វស្លាបចាបជូនតា និងចាបស៊ីរុយ។ ចំពោះការសិក្សាស្រាវជ្រាវ ក្នុង ខែមីនាឆ្នាំ ២០១៨ ឃើញមានថលជលិកសត្វ និងឧរង្គសត្វ បានបង្ហាញថាមានប្រភេទលើសពី៥០ ប្រភេទ រួមទាំងប្រភេទកង្កែប និងកន្ទាយ និងមានសត្វឆ្អឹងខ្នង។ |

| | | |
|---|---|---|
| | | ៣.រូបពណ៌ខៀវប្រលែត បង្ហាញអំពីដែនជម្រកសត្វព្រៃ ជាទីជម្រាល និងជាប្រភពទឹក បានចូលរួមចំណែកយ៉ាងសម្បើមហូរចូលក្នុងអាងទន្លេមេគង្គក្រោម។<br>៤.ជាងនេះទៀត ដែនជម្រកសត្វព្រៃព្រែកប្រសព្វ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ ជាពិសេសសត្វក្ដាន់ និងធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំងក៏បានចូលរួមរក្សានូវលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។<br>ដែនជម្រកសត្វព្រៃ«ព្រែកប្រសព្វ» ក៏មានកិច្ចសហការជាមួយដែនជម្រកសត្វព្រៃ «ព្រៃឡង់»និងកិច្ចសហប្រតិបត្តិការឆ្លងដែនក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនក្នុងក្របខ័ណ្ឌអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ។ |
| ១៩. | «សំបូរ»<br>ភូមិសាស្ត្រ<br>ខេត្តក្រចេះ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ដែនជម្រកសត្វព្រៃ «សំបូរ» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តក្រចេះ<br>១.រូបសត្វត្រដក់តូច (Lasser Adjutant: *Leptoptilos javanicus*) ជាតំណាងដែនជម្រកសត្វព្រៃ«សំបូរ» និងជាក្រុមប្រភេទសត្វស្លាបរងគ្រោះជាសកល។<br>សត្វស្លាបត្រដក់តូច ត្រូវបានចុះបញ្ជីក្រហមជាប្រភេទសត្វស្លាបងាយរងគ្រោះ ជាសកល ដោយអង្គការសហភាពអន្តរជាតិ (IUCN) ហើយចំនួនប្រភេទត្រដក់តូចនៅលើពិភពលោកត្រូវបានគេប៉ាន់ប្រមាណថាមានជាង ១០០០០ក្បាល ប៉ុន្តែចំនួននេះ កំពុងតែមានការធ្លាក់ចុះយ៉ាងខ្លាំងនៅតំបន់អាស៊ី។ ហេតុដូច្នេះហើយវាត្រូវបានគេចាត់ទុកថា ជាប្រភេទងាយរងគ្រោះ ជាសកលនៅក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអន្តរជាតិ។<br>ត្រដក់តូច មានប្រវែងពី ១២២-១២៩សង់ទីម៉ែត្រ ដែលមានមាឌតូចជាងត្រដក់ធំ ស្លាបមានសម្បុរខ្មៅទាំងលើទាំងក្រោម និងគ្មានថង់យាម។ ពេលបន្តពូជ ស្បែកក្បាលឡើងក្រហម។ ត្រដក់តូចរស់នៅក្នុងព្រៃរនាម ព្រៃលិចទឹកតាមរដូវ ព្រៃកោងកាង និងវាលភក់។ ត្រដក់តូចមានវត្តមានពេញមួយឆ្នាំ និងមានកូនមួយចំនួននៅដែនជម្រកសត្វព្រៃ «សំបូរ» និងខេត្តព្រះវិហារផងដែរ និងវាបន្តពូជចាប់ពីខែតុលា ដល់ខែមិថុនា ដែលមានពងចំនួនពី ២-៤។<br>២.ដែនជម្រសត្វព្រៃព្រែក«សំបូរ» សម្បូរបែបទៅដោយសត្វព្រៃ និងជីវៈចម្រុះ ដូចដែនជម្រកសត្វព្រៃព្រែកប្រសព្វ ដូចជាសត្វក្ដាន់ សត្វស្វាព្រាម ស្វាក្ដាម ឬស្វាស្រូវ កំប្រុកឆ្នូតខ្នង កំប្រុកសប្បុរ កំប្រុកធំ កន្ធិចកម្ពុជា ផ្អែស្រុក ស្វាតូច ផ្សោតទន្លេ កន្ធីក ទន្សាយគល់ |

| | | |
|---|---|---|
| | | ជ្រូកព្រៃ ជ្រើង រមាំង សំពោចធំ សំពោចក្រអូប ក្តាន់ញ៉ែងតូច ឬ ផ្ទងតូច ឈ្លូស ប្រើស ខ្ទីង និងពពួកខ្លាដែលមានមាឌតូច (ឆ្មាជាវ) និងត្រយ៉ងចង្កឹកស។ តំបន់នេះ ក៏មានសត្វស្លាបចាបដូនតា និងចាបស៊ីរុយ។ ចំពោះការសិក្សាស្រាវជ្រាវ ក្នុងខែមីនាឆ្នាំ ២០១៨ ឃើញមានថលជលិកសត្វ និងឧរង្គសត្វ បានបង្ហាញថាមានប្រភេទលើសពី៥០ ប្រភេទ រួមទាំងប្រភេទកង្កែប និងកន្ធាយ និងមានសត្វផ្អឹងខ្នង។<br>៣.ដែនជម្រកសត្វព្រៃព្រែក «សំបូរ» មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងមានសក្តានុពលប្រកពទំនប់ថាមពលវារីអគ្គិសនី តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ ជាពិសេសប្រភេទសត្វត្រដក់តូច និងធនធានធម្មជាតិ និងជីវៈចម្រុះ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃផ្នែកសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនក្នុងក្របខណ្ឌអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ)។ |
| **គ.តំបន់ការពារទេសភាព** | | |
| ១. | **អន្លង់ព្រីង**<br>ភូមិសាស្ត្រ<br>ខេត្តកំពត | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពអន្លង់ព្រីង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពត<br>១.រូបសត្វក្រៀល២ក្បាល ( Sarus Crane: *Grus antigone* ) ជាតំណាងនៃតំបន់ការពារទេសភាពអន្លង់ព្រីង និងជាប្រភេទសត្វស្លាបមានដោយកម្រ និងសត្វក្រៀលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វក្រៀល មានប្រវែង ១៥២-១៥៦ សង់ទីម៉ែត្រ ហើយខ្លួនវាធំ សម្បុរប្រផេះ ក្បាលត្រងោលក្រហម ដោយមានបន្ទួលក្បាលប្រផេះ និងជើងក្រហមវែង ចំពុះវែងត្រង់ និងស្លាបទី១ សប្បុរខ្មៅ។ សត្វក្រៀល រស់នៅទំនាបលិចទឹក វាលស្រែ និងតំបន់វាលស្មៅក្នុងព្រៃល្បោះ។ ចំពោះជីវសាស្ត្ររបស់វា នៅរដូវប្រាំងរកស៊ីជាហ្វូង និងរដូវវស្សាបន្តពូជឯកងង។ ការបន្តពូជរបស់សត្វក្រៀល ចាប់ពីខែមីនា ដល់ខែតុលា ដែលមានពងចំនួន ១-៣។<br>២. រូបបង្ហាញពីវត្តមានចំនួនមធ្យមបើប្រៀបធៀបជាមួយតំបន់ផ្សេងទៀត។<br>រូបសត្វក្រៀលពីរក្បាល ក៏បង្ហាញផងដែរនូវសក្តានុពលតំបន់ដែលគាំទ្រដល់ការរស់នៅរបស់ប្រភេទសត្វក្រៀល ដែលជាប្រភេទជិតផុតពូជលើពិភពលោក និងមានសារៈសំខាន់ជាអន្តរជាតិ និងជាប្រភេទសត្វស្លាបមានកម្ពស់ខ្ពស់ជាងគេបំផុត ដែលអាចហើរបាន។ រូបសត្វក្រៀល តំណាងឱ្យភាពសម្បូរបែបនៃជីវៈចម្រុះ ជាពិសេសប្រភេទសត្វស្លាបទឹក ដែលប្រើប្រាស់តំបន់នេះជាទីកន្លែងរស់នៅបន្តពូជ និងជាទីសំចតរយៈពេលខ្លីរបស់ប្រភេទសត្វទេសន្តរប្រវេសន៍ ស្នាក់នៅរកចំណីបង្កើនថាមពលសម្រាប់ការ |

| | | |
|---|---|---|
| | | បន្តធ្វើទេសន្តរប្រវេសន៍។ វត្តមានសត្វក្រៀល ជាទិសដៅទេសចរធម្មជាតិដែលជាផ្នែកមួយនៃវិស័យឧស្សាហកម្មគ្មានផ្សែង ដែលទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។ សត្វក្រៀល គឺមានអាយុកាលយូរអង្វែងណាស់មក ហើយត្រូវបានបុព្វបុរសយើងបានឆ្លាក់រូបសត្វក្រៀលនេះលើជញ្ជាំងប្រាសាទបាយ័ន។<br>៣.រូបដើមផ្លុងនិងវាលស្មៅៈ ជាប្រភពអាហារដ៏សំខាន់សម្រាប់ប្រភេទសត្វក្រៀល ដែលជាប្រភេទកម្រ ព្រមទាំងប្រភេទសត្វផ្សេងៗទៀត ហើយវត្តមានប្រភេទរុក្ខជាតិផ្លុងនេះ គឺជាប្រភេទចំណីអាហារដ៏ទាក់ទាញសត្វក្រៀលបំផុត ដែលធ្វើឱ្យតំបន់នេះមានវត្តមានសត្វកៀលមកប្រមូលផ្តុំតាមរដូវកាលជារៀងរាល់ឆ្នាំ។<br>៤.រូបព្រៃគុម្ពោត វាលភក់ និងរូបពណ៌ខៀវប្រលែត តំណាងលំហទឹក ដែលជាប្រភពសម្បូរបែបនៃទីជម្រក សម្រាប់រកចំណីរបស់សត្វស្លាបទឹកសំខាន់ៗ ដែលជាប្រភេទទទួលរងការគំរាមកំហែង និងជិតផុតពូជលើពិភពលោករួមទាំងប្រភេទសត្វស្លាបទេសន្តរប្រវេសន៍រស់នៅ និងបន្តពូជរបស់មច្ឆជាតិ ល្មូន ក៏ដូចជាជីវៈចម្រុះផ្សេងៗទៀតផងដែរ។ សារៈសំខាន់ និងតម្លៃរបស់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព បាន និងកំពុងចូលរួមរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ២. | **តំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប** ភូមិសាស្ត្រខេត្តសៀមរាប និងខេត្តកំពង់ធំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តសៀមរាប និងមន្ទីរបរិស្ថានខេត្តកំពង់ធំ<br>១.រូបសត្វខ្សឹប ឬទ្រមាក់អណ្តើក (Begal Florican: *Eupodotis bengalensis*) ជាតំណាងតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ដែលជាប្រភេទសត្វមានដោយកម្រ និងមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វខ្សឹប ឬត្រមាក់អណ្តើកមានប្រវែង ៦៦-៦៨,៥សង់ទីម៉ែត្រ។ សត្វឈ្មោលៈ ក្បាល និងផ្នែកពោះសប្បុរខ្មៅ ស្លាបស ខ្នងលឿងត្រសក់។ ចំពោះសត្វញីៈសម្បុរលឿងត្រសក់ ក្បាលឆ្នូតខ្មៅ ពោះស ពេលហើរផ្នែកក្រោមស្លាបសប្បុរសប្រផេះ។ ជម្រករបស់សត្វខ្សឹប គឺវាលស្មៅ វាលស្រែ នៃស្រូវឡើងទឹក។ សត្វខ្សឹប មុនហើររត់យ៉ាងលឿន និងចូលចិត្តហើរបោះពួយទៅលើបង្ហាញខ្លួន។ សត្វខ្សឹបមានវត្តមានពេញមួយឆ្នាំ ដែលភាគច្រើនមានរស់នៅជុំវិញបឹងទន្លេសាប ខេត្តកំពង់ធំ បន្ទាយមានជ័យ និងខេត្តតាកែវ។ រដូវបន្តពូជរបស់វា ចាប់ពីខែមីនា ដល់ខែសីហា។<br>ជាប្រភេទសត្វជិតផុតពូជលើពិភពលោក មានវត្តមានរបស់វាតែប្រទេសឥណ្ឌា នេប៉ាល់ និងកម្ពុជា ហើយកម្ពុជា មានប្រភេទនេះច្រើនជាងគេ។<br>២.រូបពណ៌ខៀវវាលស្មៅ និងព្រៃលិចទឹកៈ គ្របដណ្តប់ភាគច្រើនក្នុងតំបន់ការពារធម្មជាតិនេះ និងជាជម្រកដ៏សំខាន់បំផុតសម្រាប់រស់នៅ និងបន្តពូជរបស់សត្វខ្សឹប និង |

| | | |
|---|---|---|
| | | ប្រភេទជីវៈចម្រុះផ្សេងៗទៀត និងបានផ្តល់នូវទេសភាពស្រស់ស្អាតសម្រាប់ទេសចរធម្មជាតិ។<br>៣.រូបពណ៌លឿង និងពណ៌ខៀវខ្ចី បង្ហាញពីតំបន់ទំនាបលិចទឹកនៃតំបន់ការពារធម្មជាតិនេះមានប្រភេទដីល្បាប់ទទួលដោយរបបទឹកជំនន់នៅរដូវវស្សាដែលសម្បូរដោយជីជាតិដែលទ្រទ្រង់ដល់វិស័យកសិកម្ម បង្កឱ្យសត្វខ្សឹបរស់នៅក្រោយពីប្រមូលផលកសិកម្មរួច។ តំបន់ការពារទេសភាពទំនាបខាងជើងបឹងទន្លេសាប មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល និងអាងរងទឹកភ្លៀងរបស់ទន្លេសាប តម្លៃផ្នែកធនធានព្រៃលិចទឹក វាលស្មៅ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ តម្លៃសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន តភ្ជាប់នឹងតំបន់ស្នូលបឹងទន្លេឆ្មា និងតម្លៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ក្នុងការការពារ និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនប្រទេសជិតខាង។ |
| ៣. | **បឹងព្រែកល្ពៅ**<br>ភូមិសាស្ត្រ<br>ខេត្តតាកែវ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពបឹងព្រែកល្ពៅ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តតាកែវ<br>១.រូបសត្វក្រៀល ១ក្បាល (Sarus Crane: *Grus antigone* ) ជាតំណាងនៃតំបន់ការពារទេសភាពបឹងព្រែកល្ពៅ និងជាប្រភេទសត្វស្លាបមានដោយកម្រ ហើយសត្វក្រៀលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទីI នៃអនុសញ្ញាសាយតេស។<br>សត្វក្រៀល មានប្រវែង ១៥២-១៥៦សង់ទីម៉ែត្រ ហើយខ្លួនវាធំ សម្បុរប្រផេះ ក្បាលត្រងោលក្រហម ដោយមានបន្ទួលក្បាលប្រផេះ និងជើងក្រហមវែង ចំពុះវែងត្រង់ និងស្លាបទី១ សប្បុរខ្មៅ។ សត្វក្រៀល រស់នៅទំនាបលិចទឹក វាលស្រែ និងតំបន់វាលស្មៅក្នុងព្រៃល្បោះ។ ចំពោះជីវសាស្ត្ររបស់វា នៅរដូវប្រាំងរកស៊ីជាហ្វូង និងរដូវវស្សាបន្តពូជឯកឯង។ ការបន្តពូជរបស់សត្វក្រៀល ចាប់ពីខែមីនា ដល់ខែតុលា ដែលមានពងចំនួន ១-៣។<br>រូបសត្វក្រៀល ១ក្បាល រូបសប្បុរបៃតង និងខៀវ បង្ហាញពីសក្តានុពលនៃតំបន់ការពារទេសភាពបឹងព្រែកល្ពៅ ដែលគាំទ្រដល់ការរស់នៅរបស់ប្រភេទសត្វក្រៀលដែលជាប្រភេទជិតផុតពូជលើពិភពលោក ដែលមានសារៈសំខាន់ជាអន្តរជាតិ និងជាប្រភេទសត្វស្លាបមានកម្ពស់ខ្ពស់ជាងគេបំផុតដែលអាចហើរបាន។ រូបសត្វក្រៀលតំណាងឱ្យភាពសម្បូរបែបនៃជីវៈចម្រុះពិសេសប្រភេទសត្វស្លាបទឹក ដែលប្រើប្រាស់តំបន់នេះជាទីកន្លែងរស់នៅធំជាត់ និងបន្តពូជ។<br>២.រូបដើមផ្លុងនិងវាលស្មៅ៖ ជាប្រភពអាហារដ៏សំខាន់សម្រាប់ប្រភេទសត្វក្រៀល ដែលជាប្រភេទកម្រ ព្រមទាំងប្រភេទសត្វផ្សេងៗទៀតហើយវត្តមានប្រភេទរុក្ខជាតិផ្លុងនេះគឺជាប្រភេទចំណីអាហារដ៏ទាក់ទាញសត្វក្រៀលបំផុត ដែលធ្វើឱ្យតំបន់នេះមានវត្តមានសត្វក្រៀលមកប្រមូលផ្តុំតាមរដូវកាលជារៀងរាល់ឆ្នាំ។ |

| | | |
|---|---|---|
| | | ៣.រូបពណ៌ខៀវ តំណាងព្រៃលិចទឹក និងពណ៌ខៀវព្រលែត តំណាងលំហទឹក ដែលមានសក្តានុពលធនធានព្រៃលិចទឹក បឹង ស្ទឹង ព្រែក និងអូរ ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅធំធាត់ និងបន្តពូជរបស់ត្រី ក៏ដូចជាប្រភេទសត្វផ្សេងទៀតផងដែរ។ ព្រៃលិចទឹកមានតួនាទីជានិយ័តករ ការរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ដែលកម្ពុជាជាប្រទេសហត្ថលេខីចូលរួមអនុវត្តនូវអនុសញ្ញារ៉ាមសារ អនុសញ្ញាស្តីពីជីវៈចម្រុះ និងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ |
| ៤. | **អាងត្រពាំងថ្ម** ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពអាងត្រពាំងថ្ម និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១. រូបសត្វក្រៀល ៣ក្បាល (Sarus Crane: *Grus antigone*) ជាតំណាងនៃតំបន់ការពារទេសភាពអាងត្រពាំងថ្ម និងជាប្រភេទសត្វស្លាបមានដោយកម្រ និងសត្វក្រៀលមានចុះក្នុងបញ្ជីឧបសម្ព័ន្ធទី I នៃអនុសញ្ញាសាយតេស។<br>សត្វក្រៀល មានប្រវែង ១៥២-១៥៦សង់ទីម៉ែត្រ ហើយខ្លួនវាធំ សម្បុរប្រផេះ ក្បាលត្រងោលក្រហម ដោយមានបន្ទូលក្បាលប្រផេះ និងជើងក្រហមវែង ចំពុះវែងត្រង់ និងស្លាបទី១ សប្បុរខ្មៅ។ សត្វក្រៀល រស់នៅទំនាបលិចទឹក វាលស្រែ និងតំបន់វាលស្មៅក្នុងព្រៃល្បោះ។ ចំពោះជីវសាស្ត្ររបស់វា នៅរដូវប្រាំងរកស៊ីជាហ្វូង និងរដូវវស្សាបន្តពូជឯកឯង។ ការបន្តពូជរបស់សត្វក្រៀល ចាប់ពីខែមីនា ដល់ខែតុលា ដែលមានពងចំនួនពី១-៣។<br>រូបសត្វ៣ក្បាល គឺសម្គាល់ពីវត្តមានចំនួនច្រើនបើប្រៀបធៀបជាមួយតំបន់ផ្សេងទៀត។ ក្រៀលបីក្បាល ក៏បង្ហាញផងដែរនូវសក្តានុពលតំបន់ដែលគាំទ្រដល់ការរស់នៅរបស់ប្រភេទសត្វក្រៀលដែលជាប្រភេទជិតផុតពូជលើពិភពលោក មានសារៈសំខាន់ជាអន្តរជាតិ និងជាប្រភេទសត្វស្លាបមានកំពស់ខ្ពស់ជាងគេបំផុតដែលអាចហើរបាន។ រូបសត្វក្រៀលតំណាងឱ្យភាពសម្បូរបែបនៃជីវៈចម្រុះពិសេសប្រភេទសត្វស្លា ទឹក ដែលប្រើប្រាស់តំបន់នេះជាទីកន្លែងរស់នៅ ធំធាត់ បន្តពូជ។ វត្តមាន សត្វក្រៀល ជាទិសដៅទេសចរធម្មជាតិដែលជាផ្នែកមួយនៃវិស័យឧស្សាហកម្មគ្មានផ្សែងដែលទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន<br>២.រូបដើមផ្លុង និងវាលស្មៅ៖ ជាប្រភពអាហារដ៏សំខាន់សម្រាប់ប្រភេទសត្វក្រៀលដែលជាប្រភេទកម្រ ព្រមទាំងប្រភេទសត្វផ្សេងៗទៀតហើយវត្តមានប្រភេទរុក្ខជាតិក្លុងនេះ គឺជាប្រភេទចំណីអាហារដ៏ទាក់ទាញសត្វក្រៀលបំផុត ដែលធ្វើឱ្យតំបន់នេះមានវត្តមានសត្វកៀលមកប្រមូលផ្តុំតាមរដូវកាលជារៀងរាល់ឆ្នាំ។<br>៣.រូបពណ៌ខៀវតំណាងព្រៃល្បោះ និងពណ៌ខៀវប្រលែត តំណាងលំហទឹក និងភ្នំបង្ហាញពីភាពសម្បូរបែបនៃទីជម្រក និងលក្ខណៈពិសេសដាច់ដោយឡែកនៃទីជម្រកតំបន់នេះ ដែលមានសក្តានុពលខ្ពស់ដល់ការរស់នៅ និងបន្តពូជរបស់សត្វស្លាប ល្មូន ថនិកសត្វ |

| | | |
|---|---|---|
| | | និងជីវៈចម្រុះផ្សេងៗទៀត។ លំហទឹកនេះផងដែរបង្ហាញពីលំហទឹកនៃអាងត្រពាំងថ្មដែលជាតំបន់ដីសើមដែលបង្កើតឡើងដោយមនុស្ស ជាអាងស្តុកទឹកដ៏សំខាន់បំផុតមួយ ស្តុកទឹកបានរាប់លានម៉ែត្រគ្រីគុណ សម្រាប់បម្រើឱ្យវិស័យកសិកម្ម ពិសេសស្រោចស្រពដំណាំស្រូវរាប់ពាន់ហិកតា ដែលជាប្រភពចូលរួមការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍មូលដ្ឋាន និងសេដ្ឋកិច្ចជាតិ។ |
| ៥. | **ទឹកសាបបឹងព្រែកទប់**<br>ភូមិសាស្ត្រខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពទឹកសាបបឹងព្រែកទប់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបពណ៌ខៀវ ជាតំណាងធនធានធម្មជាតិ និងពណ៌ខៀវប្រលែត តំណាងតំបន់ឆ្នេរនិងសមុទ្រ។ តំបន់ការពារទេសភាពទឹកសាបបឹងព្រែកទប់ និងមានរុក្ខជាតិដុះព័ទ្ធជុំវិញ។ តំបន់ការពារទេសភាពទឹកសាបបឹងព្រែកទប់ មានសក្តានុពល សម្រាប់ទេសចរណ៍ធម្មជាតិ ចូលរួមចំណែកជារបាំងខ្យល់ព្យុះ និងការហូរច្រោះដី។<br>២.តំបន់ការពារទេសភាពបឹងព្រែកទប់ មានសារៈសំខាន់ និងមានតម្លៃផ្នែកការកម្សាន្តការទស្សនា តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងជំនឿដែលនៅលើភ្នំមានវត្តអារាមជាទីសក្ការៈ និងតម្លៃផ្នែកសេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ប្រើប្រាស់ប្រកបដោយនិរន្តភាព និងលំនឹងនៃប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ សម្រាប់យូរអង្វែងនិងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៦. | **«ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)»**<br>ភូមិសាស្ត្រខេត្តព្រះវិហារ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាព «ប្រាសាទបាកាន (ព្រះខ័នកំពង់ស្វាយ)» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ<br>១.រូបសំណាកព្រះអង្គចតុមុខ ជាតំណាងដែលសម្បូរបែបទៅដោយធនធានព្រៃឈើ និងជីវៈចម្រុះ<br>២.**ព្រះភ័ក្ត្រព្រះអង្គបែរព្រះភ័ក្ត្រមួនទិស** ជាតំណាងព្រហ្មវិហារធម៌បួន គឺមេត្តា ករុណា មុទិតា ឧបេក្ខា។ យោងតាមឯកសាររបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានឱ្យដឹងថា ប្រាសាទព្រះខ័នកំពង់ស្វាយ កសាងឡើងនៅសម័យអង្គរនៅពាក់កណ្ដាលសតវត្សរ៍ទី១១ និងដើមសតវត្សរ៍ទី១២ ក្នុងរាជព្រះបាទសូរ្យវរ្ម័នទី១ (គ.ស.១០០២-១០៥០)។ ប្រាសាទនេះមានកំផែងពីរជាន់ បើយោងតាមប្រវត្តិវិទូឱ្យដឹងថា ប្រាសាទបាកាន ក៏ជាទីកន្លែងលាក់ខ្លួនរបស់ព្រះបាទជ័យវរ្ម័នទី៧ មុនពេលព្រះអង្គឡើងគ្រងរាជ្យនៅឆ្នាំ១១៨១ នេះបើតាមរចនាប័ទ្មនៃសំណង់ស្ថាបត្យកម្មខ្លះស្រដៀងគ្នា ទៅនឹងរចនាបថប្រាសាទបាយ័ន និងប្រាសាទតាព្រហ្ម។<br>៣.ពីមុនតំបន់នេះមានព្រៃឈើច្រើន ដែលហ៊ុមព័ទ្ធដោយបារាយណ៍ មានស្ទឹង ជងអូរ និងមានប្រភពទឹកធ្លាក់ចុះពីភ្នំដងរែក។ ជាងនេះទៀត ប្រាសាទនេះស្ថិតនៅជាប់តំបន់រ៉ែ |

| | | |
|---|---|---|
| | | ដែក ដែលអាចស្លធ្វើជាឧបករណ៍សឹកសម្រាប់កងទ័ពកាលសម័យអតីតកាល។ ព្រះបាទជ័យវរ្ម័នទី៧ បានជ្រើសយកភូមិសាស្ត្រ តំបន់ប្រាសាទព្រះខ័នកំពង់ស្វាយនេះ ធ្វើជាកន្លែងហ្វឹកហាត់កងទ័ពអស់រយៈពេលជាង ៤ឆ្នាំ គឺចាប់ពីឆ្នាំ ១១៧៧ ដល់ឆ្នាំ១១៨១ មុនពេលព្រះអង្គចេញទ័ពច្បាំងដេញទ័ពចម្ប៉ាចូលឈ្លានពានទីក្រុងអង្គរ ដោយជ័យជម្នះ (លោក ចិន្ត ច័ន្ទវតនា ជាមួយសារព័ត៌មានថ្មីៗ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ ដកស្រង់ពីស្លាកបដាមុខប្រាសាទបាកាន (https://km.wikipedia.org/wiki/ប្រាសាទព្រះខ័ន_(កំពង់ស្វាយ)។ ដូច្នេះហើយទើបជ្រើសរើសយករូបសញ្ញាសម្គាល់ នៃរូបចម្លាក់ព្រះអង្គ និងធម្មជាតិ។ ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ និងតម្លៃសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋានព្រមទាំងរក្សានូវលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៧. | **«រនាមដូនសំ»** ភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាព «រនាមដូនសំ» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ<br>១.រូបសត្វជ្រូកពោន ឬជ្រូកព្រុល (Hog Badger *Arctonyx collaris*) ជាតំណាងតំបន់ការពារទេសភាព «រនាមដូនសំ» និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ និងមានចុះនៅក្នុងបញ្ជីក្រហម របស់អង្គការ IUCN ជាប្រភេទសត្វរងគ្រោះតិចតួច។<br>២.រូបពណ៌ខៀវ ជាតំណាងធនធានធម្មជាតិ និងជីវៈចម្រុះសំបូរបែប និងរូបពណ៌ខៀវប្រលែត ជាតំណាងទីជម្រាល ប្រភពទឹក។ តំបន់ការពារទេសភាព«រនាមដូនសំ» មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃការសិក្សាស្រាវជ្រាវ និងអប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន។<br>៣.តំបន់នេះមានសារៈសំខាន់ និងតម្លៃជាប្រភពផ្តល់នូវប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់ដោយមានការថែទាំទីជម្រក និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិ សម្រាប់យូរអង្វែង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៨. | **«សម្បូរព្រៃគុក»** ភូមិសាស្ត្រ ខេត្តកំពង់ធំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាព «សម្បូរព្រៃគុក» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ធំ<br>១.រូបប្រាសាទសម្បូរព្រៃគុក និងធនធានធម្មជាតិជាតំណាងនៃតំបន់ការពារទេសភាព «សម្បូរព្រៃគុក»។<br>២.ប្រាសាទសម្បូរព្រៃគុក គឺជារាជធានីខ្មែរបុរាណនគរភ្នំ។ ពាក្យ «គុក» សំដៅ «ប្រាសាទ ឬទីធ្ងន់ធ្ងឹត» មានន័យថា ជាទីកន្លែងគោរពបូជាដ៏ស្ងប់ស្ងាត់ដើម្បីអប់រំចិត្ត |

| | | |
|---|---|---|
| | | ព្រោះថាប្រាសាទជាទីកន្លែងសក្ការៈបូជារបស់ព្រះរាជា គឺមិនមែនជាទីកន្លែងសម្រាប់ព្រះអង្គគង់នៅទេ ហើយបច្ចុប្បន្នពាក្យ «គុក» ក៏មានន័យអប់រំចិត្តដែរ គឺមិនមែនជាទីសម្រាប់សប្បាយនោះទេ។ ទីតាំងភូមិសាស្ត្រប្រាសាទសម្បូរព្រៃគុកទៀតសោតបានភ្ជាប់ទៅនឹងទន្លេសាបដោយមានផ្លូវបុរាណចេញពីកំពែងក្រុង (https://pressocm.gov.kh/archives/8294)។ មានក្រុមប្រាសាទសាងជា៤ក្រុមធំៗ ដែលសាងសង់អំពីឥដ្ឋតាន់ និងថ្មបាយក្រៀម ដែលលម្អទៅដោយចម្លាក់ពីលើឥដ្ឋ ចាក់ពុម្ពដោយបាយអជាផ្ទាំងៗអំពីឥដ្ឋ តែបច្ចុប្បន្ន របេះអស់ហើយ។ ប្រាសាទនេះកសាងឡើងនៅរជ្ជកាលស្តេចឥសានវរ្ម័នទី១ នៅក្នុងសតវត្សរ៍ទី៧ (គ.ស.៦១៦-៦៣៥) នាសម័យចេនឡា។ ក្រុមប្រាសាទសម្បូរព្រៃគុកនេះត្រូវបានបោះបង់ចោលតាំងពីឆ្នាំ១៩៧១មកម្ល៉េះ និងត្រូវបានរៀបចំសារជាថ្មីនៅឆ្នាំ១៩៨០ ហើយគេបានរកឃើញមានប្រាសាទទាំងអស់ ចំនួន ១៤០ប្រាសាទ។<br>៣.រូបសត្វតោ៖ បុព្វបុរសខ្មែរបានចាត់ទុករូបចម្លាក់សត្វតោ និងខ្លា ជាសត្វព្រៃមានភាពកាចសាហាវមានកម្លាំងខ្លាំងក្លា មាំមួន និងមានភាពអង់អាចក្លាហាន។ ក្នុងទស្សនៈខ្មែរសត្វតោ និងខ្លា ជាឆ្មាំ ជានិមិត្តរូបនៃអំណាច ដែលជួយបណ្តេញឧបទ្រពចង្រៃ។ សត្វទាំងពីរ ជារូបសញ្ញាសម្គាល់នៃឥទ្ធិពលមានមកពីធម្មជាតិ គួរឱ្យកោតខ្លាចលាយឡំជាមួយការគោរពផងដែរ។<br>៤.តំបន់ការពារទេសភាពសម្បូរព្រៃគុកមានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងតម្លៃផ្នែកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ដែលមានមុខងារផងដែរ តភ្ជាប់ប្រព័ន្ធអេកូឡូស៊ីរបៀងអភិរក្សជីវៈចម្រុះ ប្រព័ន្ធតំបន់ការពារធម្មជាតិឧត្តរ និងដែនជម្រកសត្វព្រៃព្រៃឡង់។ |
| ៩. | **អង្គរ**<br>ភូមិសាស្ត្រ<br>ខេត្តសៀមរាប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពអង្គរ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តសៀមរាប<br>១.រូបសញ្ញាសម្គាល់ប្រាសាទអង្គរវត្ត ជាតំណាងតំបន់ការពារទេសភាពអង្គរ និងមានព្រះអាទិត្យនៅលើកំពូលប្រាសាទ និងមានធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែបហ៊ុមព័ទ្ធជុំវិញ។<br>២.ប្រាសាទអង្គរវត្ត ជានិមិត្តរូបដ៏រុងរឿងនៃព្រលឹងជាតិរបស់ប្រជាជនកម្ពុជា។ ទង់ជាតិនៅក្នុងរបបមុនៗ ក៏ដូចជាទង់ជាតិក្នុងរបបបច្ចុប្បន្នសុទ្ធតែមានរូបប្រាសាទអង្គរវត្តទាំងអស់។ ប្រាសាទអង្គរវត្តគឺជាអច្ឆរិយវត្ថុ ដ៏កម្រមួយរបស់មនុស្សជាតិ ព្រោះជាស្នាដៃកំពូលអស្ចារ្យមួយខាងស្ថាបត្យកម្មរបស់មនុស្ស។ ជនបរទេស ភាគច្រើន ស្គាល់ |

| | | |
|---|---|---|
| | | ព្រះរាជាណាចក្រកម្ពុជា តាមរយៈការមកទស្សនាអង្គរវត្ត ដូច្នេះការស្វែងយល់ដឹងពីប្រាសាទអង្គរវត្ត គឺជាការចាំបាច់ណាស់សម្រាប់យើងជាម្ចាស់ទឹកដីអង្គរនេះ។<br>៣.ព្រះអាទិត្យ ដែលរះចំកណ្តាលកំពូលប្រាសាទអង្គរវត្ត ដោយក្រសួងទេសចរណ៍បញ្ជាក់ថា បាតុភូតព្រះអាទិត្យរះចំកណ្តាលកំពូលប្រាសាទអង្គរវត្តរបស់កម្ពុជា (EQUINOX) កើតឡើងចំនួន២ដងជារៀងរាល់ឆ្នាំ ដោយលើកទី១នៅក្នុងខែមីនា និងលើកទី២នៅក្នុងខែកញ្ញា។ បាតុភូតព្រះអាទិត្យរះចំកណ្តាលកំពូលប្រាសាទអង្គរវត្តនេះ ស្តែងឱ្យឃើញពីអច្ឆរិយភាពនៃប្រាសាទអង្គរ ដែលត្រូវបានបុព្វបុរសខ្មែរយើងកសាងដោយមានការគិតគូរអំពីស្ថាបត្យកម្ម និងការផ្សារភ្ជាប់ជាមួយនឹងធម្មជាតិយ៉ាងច្បាស់លាស់គួរឱ្យស្ញប់ស្ញែង។<br>៤.តំបន់ការពារទេសភាពអង្គរ មានសារៈសំខាន់ និងតម្លៃផ្នែកជាតំបន់ទីជម្រាល តម្លៃផ្នែកជីវៈចម្រុះ តម្លៃផ្នែកទេសចរ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ តម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងតម្លៃផ្នែកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ដែលតភ្ជាប់នឹងប្រព័ន្ធអេកូឡូស៊ីឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»។ |
| ១០. | **បន្ទាយឆ្មារ**<br>ភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពបន្ទាយឆ្មារ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ និងមន្ទីរបរិស្ថានខេត្តឧត្តរមានជ័យ<br>១.មានរូបសញ្ញាសម្គាល់អវលោកិតេស្វរៈព្រះហស្ត ៣២រូប ជាតំណាងតំបន់ការពារទេសភាពបន្ទាយឆ្មារ និងជុំវិញព័ទ្ធដោយធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែប។<br>២.«អវលោកិតេស្វរៈ ព្រះហស្ត៣២» ជារូបសញ្ញាសម្គាល់ខេត្តបន្ទាយមានជ័យ ដែលជាអ្នកដឹកនាំក្នុងការប្រមើលសេចក្តីសុខទុក្ខសត្វលោក។ រូបសញ្ញាសម្គាល់នេះត្រូវបានប្រើជាផ្លូវការរបស់រដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ។ ក្រៅពីនេះអាចប្រើប្រាស់ជាផ្លូវការក្នុងករណីដែលចំបាច់ផ្សេងៗ។<br>៣.ប្រាសាទបន្ទាយឆ្មារៈ ប្រាសាទបន្ទាយឆ្មារ មានតម្លៃជាប្រវត្តិសាស្ត្របង្កប់នូវភាពអាថ៌កំបាំង មានរូបចម្លាក់ដៃ៣២ មានអមដោយប្រាសាទរណបជុំវិញ ដែលបានកសាងឡើងនៅចុងសតវត្សទី១២ ដើមសតវត្សទី១៣ ដោយព្រះមហាក្សត្រព្រះបាទជ័យវរ្ម័នទី៧ ក្នុងគោលបំណងដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធព្រះរាជបុត្រារបស់ព្រះអង្គព្រះនាមសិន្ទ្រៈកុមារ និងឧទ្ទិសវិញ្ញាណក្ខន្ធមេទ័ពទាំង៤ ដែលបានពលីជីវិតក្នុងសមរភូមិសង្គ្រាមនៅគ្រាប្រយុទ្ធជាមួយមេទ័ពចម្ប៉ា។<br>៤.តំបន់ការពារទេសភាពបន្ទាយឆ្មារមានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ និងជីវៈចម្រុះ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ និងអប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំង |

| | | |
|---|---|---|
| | | ចូលរួមនូវរក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ និងចូលរួមចំណែក ក្នុងការការពារ និងអភិរក្សធម្មជាតិឆ្លងដែនជាមួយប្រទេសជិតខាង។ |
| ១១. | **ព្រះវិហារ**<br>ភូមិសាស្ត្រ<br>ខេត្តព្រះវិហារ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពព្រះវិហារ និងខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះវិហារ<br>១.រូបប្រាសាទព្រះវិហារ ជាតំណាងតំបន់ការពារទេសភាពព្រះវិហារ និងនៅជុំវិញមានធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែប។<br>២.រូបប្រាសាទព្រះវិហារ ស្ថិតនៅលើខ្នងភ្នំដងរែកដែលមានរយៈកម្ពស់៦២៥ម៉ែត្រ ធៀបទៅនឹងទឹកសមុទ្រ មានប្រវែង៨០០ម៉ែត្រ និងទទឹង៤០០ម៉ែត្រ ក្នុងភូមិស្វាយជ្រំ ឃុំកន្ទួត ស្រុកជាំក្សាន្ត មានចម្ងាយ៤០៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ តែបើគេធ្វើដំណើរចេញពីទីរួមខេត្តព្រះវិហារវិញ មានចម្ងាយត្រឹមតែ១០៨គីឡូម៉ែត្រប៉ុណ្ណោះ ដោយធ្វើដំណើរតាមផ្លូវលេខ២១១ ទៅកាន់ស្រុកជាំក្សាន្ត។ ភ្នំដងរែកមានជណ្តើរមួយដែលគេអាចឡើងទៅដល់កំពូលភ្នំដែលជាទីតាំងរបស់ប្រាសាទព្រះវិហារ ហើយមានលក្ខណៈចោតខ្លាំង។<br>៤.តំណាងប្រាសាទព្រះវិហារៈ ត្រូវបានឱ្យប្រើប្រាស់ជារូបសញ្ញាសម្គាល់ខេត្តព្រះវិហារ ដែលតំណាងឱ្យភាពត្រដាក់ត្រដុំ និងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈវិស័យទេសចរណ៍ក្នុងខេត្តព្រះវិហារ។ ម៉្យាងទៀត ប្រាសាទព្រះវិហារ ត្រូវបានអង្គការយូណេស្កូ (UNESCO) ដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ និងត្រូវបានក្រុមប្រឹក្សាអន្តរជាតិស្តីពីប្រាង្គប្រាសាទ និងរមណីយដ្ឋាន (ICOMOS) ទទួលស្គាល់ថា «កំពូលស្នាដៃដ៏អស្ចារ្យ នៃស្ថាបត្យកម្មខ្មែរ និងមានតម្លៃសាកលដ៏ចំណាន» (ប្រកាសលេខ៤១៣៣ប្រក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ)។<br>៤.រូបភាពនាគព្រះវិហារៈ នាគជាភាសាសំស្រ្កឹតគឺជាសត្វលូនមួយប្រភេទ ដែលត្រូវបានប្រសូតចេញពីទេវកថាឥណ្ឌូ-ខ្មែរ ហើយពាក់ព័ន្ធទៅនឹងការបង្កើតលោកយើងនេះ។ សត្វនាគនេះ ជានិមិត្តរូបនៃភាពជីវិត អមតៈ ហើយកកើតឡើងដោយការផ្សំជាតុទឹក និងដី។ ក្នុងវិស័យស្ថាបត្យកម្មប្រាង្គប្រាសាទខ្មែរ នាគនេះបានដើរតួនាទីយ៉ាងសំខាន់ជាពិសេសលើក្បាច់ផ្តែរ ឬហោជាង និងបង្កាន់ដៃកណ្តាល នាសម័យបុរេអង្គរ និង អង្គរ។ អតីតព្រះរាជានៅសម័យអង្គរចាប់តាំងពីដើមសម័យអង្គរ ជាពិសេសចាប់តាំងពីរាជរបស់ព្រះបាទយសោវរ្ម័នទី១ ទើបមានស្ពាននាគរាជ ដែលស្តែងពីការបង្កើតថ្មីមួយដែលពុំធ្លាប់មានពីមុន។ នៅប្រាសាទបាគង ប្រាសាទព្រះវិហារ និង កោះកេរ គេឃើញមាននាគរាជញី ឈ្មោល មួយគូរអមផ្លូវទាំងសងខាងទៅកាន់ប្រាសាទជាទីសក្ការៈ។ ក្បាច់ ផ្តែរមុន |

| | | |
|---|---|---|
| | | អង្គរ ជាច្រើន ក្នុងរចនាប័ទ្មសម្បូរ ព្រៃគុក ព្រៃក្មេង ត្រូវបានរកឃើញបញ្ជាក់នូវតួនាទីរបស់នាគអនន្តៈ ក្នុងសង្គមខ្មែរបុរាណនាសម័យចេនឡា។<br>៥.តំបន់ការពារទេសភាពព្រះវិហារ មានសារៈសំខាន់និងតម្លៃផ្នែកទីជម្រាល តម្លៃផ្នែកធនធានព្រៃឈើ តម្លៃ ជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ និងជីវៈចម្រុះ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំងចូលរួមរក្សានូវលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១២. | **បឹងយ៉ាកអោម យ៉ាកកាក៉** ភូមិសាស្ត្រ ខេត្តរតនគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាពបឹងយ៉ាកអោម-យ៉ាកកាក៉ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី<br>១.រូបប្រអប់ផ្ទៃផ្ទៃទឹកបឹងពីរ (០២) ថ្លាខៀវស្រងាត់ និងរូបពណ៌បៃតងតំណាងដោយធនធានធម្មជាតិ និងជីវៈចម្រុះសម្បូរបែបព័ទ្ធជុំវិញនៅក្នុងតំបន់ការពារទេសភាពបឹងយ៉ាកអោម-យ៉ាកកាក៉ និងមានរូបជនជាតិដើមភាគតិចរស់នៅទីនោះ។<br>ឈ្មោះដើមរបស់បឹងយ៉ាកអោម-យ៉ាកកាក៉ គឺមកពីយក្ខអោមកាក៉ ដែលជាពាក្យនិយមហៅដោយបងប្អូនជនជាតិដើមភាគតិចទំពួន។ ពាក្យថាកាក៉មានន័យថាត្រីឡើងលេងតាមវាល នៅពេលដែលទឹកនៅទីនោះពេញហៀរឡើងហើយហូរចេញទៅតំបន់ផ្សេងទៀត។<br>២.បឹងធម្មជាតិនេះ ហ៊ុមព័ទ្ធដោយកូនភ្នំជុំវិញ ដែលមានរយៈកម្ពស់ ២៨០ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ និងផ្ទៃទឹកទាំងពីរមានរយៈកម្ពស់១៨០ ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រនៅតំបន់នោះមាន ដើមឈើខ្ពស់ៗជុំវិញ ដែលផ្ទៃទឹកបឹងពីរថ្លាខៀវស្រងាត់។<br>៣.ព្រៃនៅជុំវិញបឹងបីយ៉ាកអោម-យ៉ាកកាក៉ ជាប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ មានភាពបៃតង និងមានសត្វព្រៃមួយចំនួន ដូចជា ប្រើស ឈ្លូស ស្វា ជ្រូកព្រៃ សំពោច ទន្សាយ កំប្រុក កង្កែន ស្កាំ ត្រកួត ផ្លាបារ កាំប្រម៉ា ពស់ថ្លាន់ ពស់វែក កេងកងតូច កេងកងធំ ប្រវឹក ទទា សារិកាកែវ សេក លលក មាន់ទឹក ក្លំ និងប្រភេទសត្វច្រើនទៀត។ជាមួយគ្នានេះដែរ មានវត្តមានមច្ឆជាតិមួយចំនួន ដូចជា ត្រីកន្ធ្រប់ ត្រីរស់ ត្រីក្រាញ់ ត្រីអណ្តែង ត្រីត្រឌិន ត្រីកន្ទុយក្រហម ត្រីស្លាត ត្រីចង្វា ត្រីឆ្តាំង ត្រីដំរី អន្ទង់ ពស់ព្រលឹត និងប្រភេទមច្ឆជាតិផ្សេងទៀត។<br>៤. តំបន់ការពារទេសភាពលំកុដ មានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៣. | **«ភ្នំក្រាំងដីមាស»** ភូមិសាស្ត្រ ខេត្តកំពង់ឆ្នាំង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាព «ភ្នំក្រាំងដីមាស» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង |

| | | |
|---|---|---|
| | | ១. រូបពណ៌ខៀវក្រម៉ៅ ជាតំណាងភ្នំ និងពណ៌បៃតង ជាតំណាងព្រៃជាតំណាងការពារទេសភាព«ភ្នំក្រាំងដីមាស»។<br>២.តំបន់នេះមានសារៈសំខាន់ផ្តល់ជាទីកន្លែង សម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿដែលនៅលើភ្នំមានវត្តអារាមជាទីសក្ការៈ និងតម្លៃជាប្រភពផ្តល់នូវប្រព័ន្ធអេកូឡូស៊ី សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ១៤. | **«បឹងលំកុង»**<br>ភូមិសាស្ត្រ<br>ខេត្តរតនគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ការពារទេសភាព«បឹងលំកុង» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី<br>-រូបប្រអប់ដៃទ្រទឹក ជាតំណាងតំបន់ការពារទេសភាព«បឹងលំកុង» និងរូបសប្បុរបៃតងហ៊ុមព័ទ្ធ គឺមានភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ និងរូបជនជាតិដើមភាគតិច។<br>២.បឹងធម្មជាតិនេះ ជាដីភ្នំដែលមានរយៈកម្ពស់ត្រឹម ២០០០ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ និងមានដើមឈើខ្ពស់ៗជុំវិញដែលផ្ទៃទឹកបឹងថ្លាខៀវ។ ទិដ្ឋភាពបឹងលំកុង មានរុក្ខជាតិខៀវស្រងាត់ និងដើមឈើធំៗ សម្បូរដោយពពួកសត្វស្លាប និងល្មូន។ នៅក្នុងតំបន់បឹងលំកុងនេះ មានបឹងមួយតូចទៀតមានទំហំផ្ទៃដី ប្រមាណ១,៧៨ហិកតា (ភាសាជនជាតិដើមភាគតិចហៅថានងភឿ) បានបន្តភ្ជាប់ទៅនឹងបឹងលំកុង តាមរយៈកូនអូរតូចមួយ ដែលនៅរដូវវស្សាទឹកនៅបឹងលំកុងបានហូរចេញទៅបឹងតូចនេះមួយចំនួន។<br>៣.ព្រៃនៅជុំវិញបឹងលំកុង ជាប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះមានភាពបៃតង និងមានលក្ខណៈល្អប្រសើរដែលភាគច្រើនមានដូចជា ដើមខ្លុង រាំង ផ្ចឹក ឈ្លីក និងបេង ។ល។ និងសត្វមួយចំនួន ដូចជា ឈ្លូស ស្វា ជ្រូកព្រៃ សំពោច ទន្សាយ កំប្រុក ពស់ថ្លាន់ ពស់វែក ជាដើម និងប្រភេទសត្វដទៃទៀតមិនទាន់មានការស្រាវជ្រាវនៅឡើយ។<br>៤.មានវត្តមានមច្ឆជាតិមួយចំនួនដូចជាៈ ត្រីរ៉ស់ ត្រីឆ្តោរ ត្រីក្មាន់ ត្រីឆ្ពិន ត្រីអណ្តែងអណ្តើក និងកន្ធាយ និងប្រភេទមច្ឆជាតិផ្សេងទៀតដែលមិនទាន់មានការសិក្សា លម្អិតនៅឡើយ។<br>៥. រូបភាព ជនជាតិភាគតិចទំពួន និងចារាយរស់នៅជុំវិញ ដោយពឹងផ្អែកនឹងតំបន់ការពារទេសភាពបឹងលំកុង។<br>៦.តំបន់ការពារទេសភាពបឹងលំកុងមានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជន |

| | | |
|---|---|---|
| | | មូលដ្ឋានហើយ និងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| **ឃ.តំបន់ប្រើប្រាស់ច្រើនយ៉ាង** | | |
| ១. | **ពញាក្រែក** ភូមិសាស្ត្រ ខេត្តត្បូងឃ្មុំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាងពញាក្រែក និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តត្បូងឃ្មុំ<br>១.រូបកូនឈើ ៣ ដើម ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងពញាក្រែក។<br>២.តំបន់នេះមានសារៈសំខាន់ និងតម្លៃជាទីជម្រក និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ីសម្រាប់សង្គមជាតិគ្រប់ជំនាន់ និងមានសារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិសម្រាប់យូរអង្វែង។<br>៣.តំបន់ប្រើប្រាស់ច្រើនយ៉ាងពញាក្រែក មានសារៈសំខាន់ផងដែរផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ប្រើប្រាស់តម្រូវការរបស់សហគមន៍មូលដ្ឋាន ព្រមទាំងចូលរួមរក្សានូវលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និង ចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ២. | **ព្រែកទឹកសាបក្បាលឆាយ** ភូមិសាស្ត្រខេត្តព្រះសីហនុ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>១.រូបដៃទ្រកូនឈើ និងមានផ្ទៃដំណក់ផ្ទាំងទឹកដ៏ធំសម្បុរខៀវ ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ និងមានភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ។<br>២.រូបដំណក់ទឹកព័ណ៌ខៀវ និងដៃទ្រដំណក់ទឹក បង្ហាញពីការខិតខំប្រឹងប្រែងសហការរួមគ្នាពីគ្រប់ភាគីទាំងអស់ ដើម្បីថែរក្សា និងការពារសោភ័ណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ និងបរិវេណជុំវិញ ដែលជាឧត្តមប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់ ក្នុងការចូលរួមអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សង្គម និងជាពិសេស ជាទីជម្រាល និងផ្ទៃរងទឹកភ្លៀង នៃអាងស្តុកទឹកក្បាលឆាយសម្រាប់ផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ របស់ក្រុងព្រះសីហនុទាំងមូល។ តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ក៏មានសារៈសំខាន់ និងតម្លៃ សម្រាប់ប្រជាជនដើរកម្សាន្ត ការទស្សនា ការអប់រំ និងការស្រាវជ្រាវវិទ្យាសាស្ត្រ និងចូលរួមការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៣. | **«ភ្នំនាងកង្រី-ភ្នំទូកមាស»** ភូមិសាស្ត្រ ខេត្តកំពង់ឆ្នាំង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្រី-ភ្នំទូកមាស» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង<br>១.រូបពណ៌ខៀវ ជាភ្នំនាងកង្រី ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្រី-ភ្នំទូកមាស» នឹងព័ន្ធទៅដោយធនធានធម្មជាតិ និងជីវៈចម្រុះ មានភាពសម្បូរបែប |

| | | |
|---|---|---|
| | | ២.រូបពណ៌ខៀវប្រលែត និងរូបមច្ឆាជាតិ ជាតំណាងដែលទាមទារឱ្យមានការថែទាំទីជម្រក និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី សារព័នមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិសម្រាប់យូរអង្វែង។<br>៣.តំបន់ប្រើប្រាស់ច្រើនយ៉ាង «ភ្នំនាងកង្រី-ភ្នំទូកមាស» មានសារៈសំខាន់ និងតម្លៃជាប្រភពផ្តល់នូវប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់ ដោយមានការថែទាំទីជម្រក និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី សារព័ន្ធមជ្ឈដ្ឋានធម្មជាតិ សត្វព្រៃ រុក្ខជាតិសម្រាប់យូរអង្វែង និងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៤. | **«សសរស្តម្ភសត្វតោ»**<br>ភូមិសាស្ត្រ<br>ខេត្តក្រចេះ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាង «សសរស្តម្ភសត្វតោ» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តក្រចេះ<br>១.រូបសសរស្តម្ភសត្វតោ ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាង «សសរស្តម្ភសត្វតោ» នឹងព័ទ្ធជុំវិញដោយធនធានធម្មជាតិ និងជីវៈចម្រុះ។<br>២.តំបន់ប្រើប្រាស់ច្រើនយ៉ាង «សសរស្តម្ភសត្វតោ» មានសារៈសំខាន់ និងតម្លៃជាទីជម្រក និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់ និងផ្តល់សេវាកម្មធម្មជាតិ សម្រាប់ប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។<br>៣. ប្រើប្រាស់ច្រើនយ៉ាង «សសរស្តម្ភសត្វតោ» ចូលរួមចំណែករក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។<br>៤.ជាតំបន់ដែលមានសារៈសំខាន់ផងដែរផ្តល់ផលិតផល និងសេវាកម្មធម្មជាតិ សម្រាប់ប្រើប្រាស់តម្រូវការរបស់សហគមន៍មូលដ្ឋាន។ |
| ៥. | **«បឹងយក្ខឡោម»**<br>ភូមិសាស្ត្រ<br>ខេត្តរតនគិរី | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាង «បឹងយក្ខឡោម» និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តរតនគិរី<br>១.រូបបឹងយក្ខឡោម ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាង «បឹងយក្ខឡោម» នឹងព័ទ្ធព័ទ្ធជុំវិញទៅដោយភាពសម្បូរបែបធនធានព្រៃឈើ និងជីវៈចម្រុះ។<br>បឹងយក្ខឡោម គឺជាបឹងដែលមានជម្រៅ៧០ម៉ែត្របានកើតឡើងពីការផ្ទុះភ្នំភ្លើងដោយប៉ះរវាងការផ្ទុះម៉ាក់ម៉ា (magma) ចេញ និងទឹកក្រោមដី ស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី នៃប្រទេសកម្ពុជាយើង គឺមានសារៈសំខាន់ និងតម្លៃផ្នែកប្រភពវប្បធម៌ សេដ្ឋកិច្ច និងវិទ្យាសាស្ត្រ (របាយការណ៍ចុងក្រោយ ខែមករា ឆ្នាំ២០១៥ របស់ School of Gesciences, The University of Sydney, Australia)។ តំបន់ប្រើប្រាស់ច្រើនយ៉ាង« បឹងយក្ខឡោម« ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨ នៃរាជរដ្ឋាភិបាល ក្នុងគោលបំណងបង្កើនតួនាទីប្រព័ន្ធអេកូឡូស៊ី និងលើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាអ្នកពាក់ព័ន្ធ ក្នុង |

| | | |
|---|---|---|
| | | ការថែរក្សា ការពារ អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ជំនាន់។<br>២.រូបដៃទ្រ រូបពណ៌បៃតង និងពណ៌ខៀវប្រលែត ជាតំណាងដើម្បីរួមគ្នា ថែរក្សា និងការពារ នូវមរតកសម្បត្តិធម្មជាតិ របស់តំបន់ប្រើប្រាស់ច្រើនយ៉ាង «បឹងយក្ខឡោម» ដែលស្ថិតនៅក្នុងក្រុងបានលុង ខេត្តរតនគិរី សម្រាប់ជាផលប្រយោជន៍ដល់សង្គមជាតិគ្រប់ៗជំនាន់។<br>៣.រូបផ្ទះជនជាតិ គឺតំណាងមានជនជាតិដើមភាគតិច រស់នៅក្បែរតំបន់តំបន់ប្រើប្រាស់ច្រើនយ៉ាង«បឹងយក្ខឡោម» ដែលមានសារៈសំខាន់ និងតម្លៃផ្នែកវប្បធម៌របស់ជនជាតិដើមភាគតិច សម្រាប់ផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់របស់ខេត្តរតនគិរី តម្លៃសម្រាប់ប្រជាជនដើរកម្សាន្ត ការទស្សនា ការអប់រំ និងការស្រាវជ្រាវវិទ្យាសាស្ត្រ និងចូលរួមការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៦. | **ដងពែង**<br>ភូមិសាស្ត្រ<br>ខេត្តកោះកុង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង<br>១.រូបដើមស្មាច់ ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង និងរូបពណ៌ខៀវ ជាព្រៃកោងកាង។<br>២.រូបពណ៌ខៀវប្រលែត ជាតំណាងទឹកសមុទ្រ និងរូបពណ៌ខៀវជាតំណាងឆ្នេរខ្សាច់។<br>៣.តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងមានសារៈសំខាន់និងតម្លៃជាតំបន់ទីជម្រាល និងជាប្រភពស្តុកទឹក តម្លៃផ្នែកជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ធម្មជាតិ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកសិក្សាស្រាវជ្រាវ និងអប់រំ និងតម្លៃផ្នែកផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន និងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង មានមុខងារតភ្ជាប់ជាមួយនឹងប្រព័ន្ធអេកូឡូស៊ីឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិជួរភ្នំក្រវាញ។ |
| ៧. | **សំឡូត**<br>ភូមិសាស្ត្រ<br>ខេត្តប៉ៃលិន<br>និងខេត្ត<br>បាត់ដំបង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូតនិងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តប៉ៃលិន និងមន្ទីរបរិស្ថានខេត្តបាត់ដំបង<br>១.រូបសត្វខ្ទីង (Gaur: *Bos gaurus*) ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ ដែលមានដង់ស៊ីតេរស់នៅកម្រិតទាប និងត្រូវបានចុះក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទងាយរងគ្រោះថ្នាក់ជាសាកល និងស្ថិតនៅក្នុងឧបសម្ព័ន្ធទី I នៃអនុសញ្ញាស៊ាយតេស។<br>សត្វខ្ទីងមានមាឌធំ ខ្លួនខ្មៅ ឬក្រាស់ លាតសន្ធឹងរហូតដល់ស្មើពាក់កណ្តាលខ្នង។ ចំពោះកខ្លីបន្តិច រាងមាំដោយមានប្ញូនៅផ្នែកខាងក្រោម និងជើងទាំងបួនចាប់ពីជង្គង់ចុះ |

| | | |
|---|---|---|
| | | ក្រោមសប្បុរប្រផេះ។ នៅលើថ្ងាសមានរោមវែងសប្បុរប្រផេះ ឬសប្បុរលឿងស្រាល។ កូនរបស់វាមានសប្បុរត្នោតរហូតដល់វាមានអាយុពី ៤៥ខែទើបក្លាយជាសប្បុរខ្មៅ។ ខ្ទីងញីមានមាឌ និងស្នែតតូចជាងឈ្មោល ហើយពុំសូវមានបូក និងបួរដូចខ្ទីងឈ្មោលទេ។ ស្នែងខ្ទីងមានរាងសំប៉ែតជាងស្នែងទន្សោង ហើយដុះមកមានសប្បុរប្រផេះខៀវនៅផ្នែកគល់ ដុះចេញក្រៅរួចកោងឡើងទៅលើដូចទន្សោងដែរ។ ខ្ទីងមានទម្ងន់ពី ៥០០-១០០០គក្រ។ សត្វខ្ទីងឈ្មោលពេញវ័យមានកម្ពស់ ១.៨៥ម៉ែត្រ និងញី ១.៦០ម៉ែត្រ ហើយខ្ទីងឈ្មោលមានកម្ពស់ខ្ពស់បំផុតរហូតដល់ ២ម៉ែត្រ។ សត្វខ្ទីងអាចរស់នៅបានពីតំបន់ទំនាបរហូតដល់រយៈកម្ពស់ ២០០០ម នៅក្នុងព្រៃស្រោង ព្រៃល្បោះ វាលស្មៅ និងអាចរស់នៅរយៈកំពស់ខ្ពស់ជាងទន្សោង។ ជាធម្មតាខ្ទីងចេញរកស៊ី នៅពេលព្រលឹមនិងពេលល្ងាច ។ វាចូលចិត្តរស់នៅជាហ្វូង អាហាររបស់វាគឺ ល្បះខ្ទី ទំពាំង ស្មៅ និងវល្លិ៍ជាដើម។ ខ្ទីងញីអាចបង្កើតកូនបាន១បន្ទាប់ពីពពោះរយៈពេល៩ខែ។<br>២.ព័ណ៌ខៀវចាស់ និងពណ៌ខៀវខ្ចី ជាតំណាងភាពសំបូរបែប ធនធានធម្មជាតិ និងជីវៈចម្រុះ ដែលភូមិសាស្ត្រតំបន់នេះ សម្បូរសត្វខ្ទីង និងជាក្រុមប្រភេទថនិកសត្វមានដោយកម្រ។<br>៣.រូបពណ៌ខៀវប្រលែត តំណាងជាទីម្រាលប្រភពទឹក សម្រាប់ស្ទឹងសង្កែ ដែលហូរចូលបឹងទន្លេសាប។<br>៤.តំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត មានសារៈសំខាន់ និងតម្លៃជាតំបន់ទីជម្រាល និងផ្ទៃរងទឹកភ្លៀង តម្លៃជីវៈចម្រុះ តម្លៃផ្នែកទេសចរណ៍ តម្លៃផ្នែកធនធានវប្បធម៌ តម្លៃផ្នែកធនធានព្រៃឈើ និងតម្លៃផ្នែកសេដ្ឋកិច្ចពីកាបូនស្តុក តម្លៃផ្នែកការសិក្សាស្រាវជ្រាវ អប់រំ និងតម្លៃផ្តល់ការងារដល់ប្រជាជនមូលដ្ឋាន ព្រមទាំងរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។ |
| ៨. | **ទន្លេសាប**<br>ភូមិសាស្ត្រ<br>ខេត្តកំពង់ឆ្នាំង<br>កំពង់ធំ<br>ពោធិ៍សាត់<br>បាត់ដំបង និង<br>ខេត្តសៀមរាប | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ បាត់ដំបង និងមន្ទីរបរិស្ថានខេត្តសៀមរាប<br>១.រូបត្រីគល់រាំង (Giant Barb: Catlocarpio siamensis) ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងទន្លេសាប។ ត្រីគល់រាំងជាប្រភេទជិតផុតពូជ និងជាមច្ឆជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា។<br>២.រូបពណ៌ខៀវប្រលែត តំណាងលំហទឹកបឹងទន្លេសាប ដែលជាបឹងមានទឹកសាបធំជាងគេបំផុតនៅអាស៊ីអាគ្នេយ៍ ដោយមានរបបជលសាស្ត្រមានលក្ខណៈពិសេសដាច់ដោយឡែកដោយទទួលរបបទឹកជំនន់ពីទន្លេមេគង្គលើនៅរដូវវស្សា និងផ្តល់ទឹកដល់ទន្លេមេគង្គក្រោមនៅរដូវប្រាំង ដែលមានទំហំប្រែប្រួលពី២.៥០០គម² នៅរដូវប្រាំង ទៅ១២.០០០ |

| | | |
|---|---|---|
| | | គម$^{២}$នៅរដូវស្សា។ របបជលសាស្ត្របែបនេះបានផ្តល់នូវសារជាតុចិញ្ចឹមសម្រាប់គាំទ្រដល់ជីវៈចម្រុះ និងផ្តល់នូវល្បាប់ដែលមានជីជាតិ និងទឹកសម្រាប់គាំទ្រដល់វិស័យកសិកម្ម។<br>៣.រូបព្រៃលិចទឹកៈ គឺបង្ហាញពីភាពសម្បូរបែបធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដែលមានព្រៃលិចទឹក ជាប្រភេទព្រៃលិចទឹកទឹកសាបតាមរដូវ ដែលមានទំហំធំជាងគេបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍គ្រប់ដណ្តប់លើផ្ទៃដីប្រមាណជា៣៦០.០០០ហិកតា។<br>៤.រូបពណ៌បៃតងខ្ចីតំណាងវាលស្មៅ និងព្រៃលិចទឹកដែល បង្ហាញពីភាពសម្បូរបែបនៃធនធានធម្មជាតិ និងជីវៈចម្រុះ ក្នុងនោះប្រភេទមច្ឆជាតិ នៅតំបន់បឹងទន្លេសាប មានប្រមាណជា១៥០ប្រភេទ និងត្រូវបានគេចាត់ទុកថាជាបឹងដែលទ្រទ្រង់ទិន្នផលត្រីទឹកសាបខ្ពស់លើពិភពលោកដែលមានទិន្នផលត្រីប្រមាណជាង ៣០០.០០០តោនក្នុងមួយឆ្នាំ ហើយផលចាប់នេះស្មើ ៧០%នៃផលចាប់សរុបនៃធនធានត្រីទឹកសាប។ ត្រីបានផ្តល់នូវប្រូតេអ៊ីនប្រមាណជា៧០%ដល់ប្រជាជនកម្ពុជា និងជាប្រភពសេដ្ឋកិច្ចដ៏សំខាន់ដែលរួមចំណែកប្រមាណ១៦%នៃGDP សរុបរបស់ប្រទេស។<br>៥.រូបសត្វស្លាបៈ បង្ហាញពីសក្តានុពលតំបន់ដែលទ្រទ្រង់នូវប្រភេទសត្វស្លាប ប្រមាណជាជាង២០០ប្រភេទ រួមទាំងប្រភេទសត្វស្លាបទេសន្តរប្រវេសន៍ និងជាទីជម្រកបន្តពូជពងកូនធំជាងគេបំផុតនៅក្នុងតំបន់អាស៊ី អាគ្នេយ៍របស់សត្វស្លាបទឹក ដែលជាប្រភេទទទួលរងការគំរាមកំហែង និងជិតផុតពូជដែលមានតម្លៃជាអន្តរជាតិ (អកត្រីក្បាលប្រផេះ ស្មោញ ត្រយ៉ងខ្លួនស ទុងប្រផេះ រនាលពណ៌ រនាលស ត្រដក់តូច ត្រដក់ធំ ខ្សឹប ពពូលទឹក អង្កត់ខ្មៅជាដើម)។<br>រូបភាពទាំងអស់នៅក្នុងរូបសញ្ញាសម្គាល់បង្ហាញពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមបឹងទន្លេសាប ដែលមានតម្លៃមហាសាលដល់សេដ្ឋកិច្ចជាតិ ជាពិសេសសេដ្ឋកិច្ចសហគមន៍មូលដ្ឋានប្រមាណ១៧០ភូមិ (ប្រជាជន ៤,៥លាននាក់) ដែលរស់នៅក្នុង និងជុំវិញតំបន់បឹងទន្លេសាប។<br>រូបទាំងនេះ បានបង្ហាញពីសារៈសំខាន់នៃលក្ខណៈពិសេសដាច់ដោយឡែកនៃប្រព័ន្ធអេកូឡូស៊ី គុណភាព បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប។ ក្នុងន័យនេះ ក៏បង្ហាញពីសារៈសំខាន់ និងតម្លៃរបស់តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប គឺចូលរួមរក្សាលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែននៃអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ។ |
| ៩ | ទួលព័ន្ធតាឡី<br>បឹងស្នេហ៍ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរ តំបន់ប្រើប្រាស់ច្រើនយ៉ាងទួលព័ន្ធតាឡី-បឹងស្នេហ៍ និងផ្នែកខាងក្រោមមានរំលេចអក្សរ មន្ទីរបរិស្ថានខេត្តព្រៃវែង |

| | | |
|---|---|---|
| | ភូមិសាស្ត្រ<br>ខេត្តព្រៃវែង | ១. រូបសត្វចង្កៀលខ្យង ( Asian Openbill : *Anastomus oscitans*)៖ ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលព័ន្ធតាឡី-បឹងស្នេហ៍។ ប្រភេទនេះមានវត្តមានច្រើនលើសលប់ជាងប្រភេទផ្សេងៗទាំងអស់ដែលមានវត្តមាននៅក្នុងតំបន់ដែលបានកំពុងរស់នៅ និងបន្តពូជពេញមួយឆ្នាំក្នុងតំបន់ដីសើមបឹងស្នេហ៍នេះ។ ប្រភេទសត្វចង្កៀលខ្យងនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងតំបន់ក្នុងការជួយសម្អាតបរិស្ថាន ជួយកម្ចាត់កត្តាចង្រៃ ដែលជាប្រភេទពាតត្បាត ជាពិសេសពពួកសត្វខ្យងមាស។ តាមរយៈវត្តមាននៃការមករស់នៅ និងបន្តពូជរបស់ប្រភេទសត្វចង្កៀលខ្យង រួមជាមួយទេសភាពស្រស់ស្អាតនៃធម្មជាតិក្នុងតំបន់ដីសើមបឹងស្នេហ៍នេះ បានធ្វើឱ្យតំបន់នេះមានភាពល្បីល្បាញ ទទួលបានការចាប់អារម្មណ៍ និងទាក់ទាញជាខ្លាំងទាំងភ្ញៀវជាតិ និងអន្តរ-ជាតិ មកទស្សនា និងក្លាយជាទិសដៅទេសចរណ៍ធម្មជាតិដ៏សំខាន់មួយក្នុងតំបន់។<br>ចង្កៀលខ្យង មានប្រវែង ៦៨-៨១ស.ម មាឌធំ ចំពុះមានលក្ខណៈចំហរវាងគម្របទាំងពីរ ខ្លួនសប្បុរស ស្លាបហើរទី១ និងទី២និងកន្ទុយសប្បុរខ្មៅ។ រស់នៅតាមតំបន់ ព្រៃលិចទឹក វាលលិចទឹក និងវាលស្រែ។ជាទូទៅវាស៊ីខ្យងជាអាហារ និងរកស៊ីជាហ្វូង មានវត្តមានពេញមួយឆ្នាំ និងជាប្រភេទរងគ្រោះតិចតួច។ វាបន្តពូជចាប់ពីខែតុលាដល់ខែមេសា ដែលមានពងចំនួនពី២-៥។<br>២. រូបពណ៌ខៀវប្រលែត ជាតំណាងផ្ទៃទឹកនៃបឹងស្នេហ៍ ដែលជាបឹងទឹកសាបដ៏សំខាន់ និងរូបពណ៌បៃតងខ្ចី ជាតំណាងព្រៃលិចទឹក។<br>៣.តំបន់ប្រើប្រាស់ច្រើនយ៉ាង ទួលព័ន្ធតាឡី-បឹងស្នេហ៍មានសក្តានុពលខ្ពស់ដែលអាចស្តុកទឹកទុកបានរហូតប្រមាណជាង ៨៥លានម៉ែត្រគ្រីគុណ ជារៀងរាល់ឆ្នាំសម្រាប់ការប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្ម ជាពិសេសដំណាំស្រូវរបស់ប្រជាពលរដ្ឋសរុប ១៤ឃុំ ដែលអាចធ្វើស្រូវ២ដង ក្នុង១ឆ្នាំ និងជាប្រភពទឹកសម្រាប់ផលិតទឹកស្អាតផងដែរ។បឹងនេះជាបឹងប្រវត្តិសាស្ត្រទាក់ទងនឹងរឿងរ៉ាវ ស្នេហារវាងព្រះរាជាមួយអង្គ និងមេទ័ពស្រីម្នាក់នៅបឹងនេះ ទើបមានឈ្មោះថាជា «បឹងស្នេហ៍» និងមានភូមិមួយជាប់នឹងបឹងនេះឈ្មោះថា «ភូមិទ័ពស្តេច» រហូតដល់បច្ចុប្បន្ន។ បឹងនេះ ក៏ជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងបន្តពូជរបស់មច្ឆជាតិផងដែរ ព្រោះនៅក្នុងបឹងនេះមានអន្លង់ជម្រកត្រីធំៗរហូតដល់ទៅ ៩អន្លង់ ហើយធនធានមច្ឆជាតិនេះ បាននិងកំពុងទ្រទ្រង់ដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានជុំវិញតំបន់បឹងនេះ តាមរយៈការនេសាទជាលក្ខណៈគ្រួសារ។<br>៤. រូបស្ពាន៖ តំណាងឱ្យស្ពានមួយនៅក្នុងតំបន់នេះដែលសង់ឡើងសម្រាប់ជាស្ពានឆ្លងផង និងជាទ្វារទឹកផងសម្រាប់គ្រប់គ្រងទឹកបឹងនេះ ដើម្បីបម្រើឱ្យវិស័យកសិកម្ម ហើយស្ពាននេះជាស្ពានប្រវត្តិសាស្ត្រ ដែលត្រូវបានត្រាស់បង្គាប់ដោយសម្តេចព្រះបរមរតនកោដិ នៅទសវត្ស១៩៦០ ថ្វាយការសាងសង់ស្ពាន និងទំនប់កាត់បឹងនេះ ដើម្បីទប់ទឹកប្រើប្រាស់ក្នុងវិស័យកសិកម្ម និងជាផ្លូវគមនាគមន៍ សម្រាប់ប្រជាសហគមន៍រស់នៅជុំវិញតំបន់នេះ និងបានប្រសិទ្ធនាមទំនប់នេះថា «ទំនប់បឹងស្នេហ៍» ហើយស្ពាននេះក៏ត្រូវបានហៅតៗគ្នាថា «ស្ពានស្នេហ៍» រហូតដល់បច្ចុប្បន្ន។<br>រូបសញ្ញាសម្គាល់ទាំងនេះបានបង្ហាញពីប្រវត្តិសាស្ត្រ និងជំនឿ សក្តានុពល និងភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ ក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលព័ន្ធតាឡី- |

| | | |
|---|---|---|
| | | បឹងស្នេហ៍ ដែលធនធានទាំងនោះបានផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ៤សំខាន់ៗ ដែលមានសារៈសំខាន់ដល់សុខុមាលភាពមនុស្ស និងបរិស្ថានគឺ៖ ១.សេវាកម្មផ្គត់ផ្គង់ ២.សេវាកម្មគាំទ្រ ៣.សេវាកម្មនិយ័តកម្ម និង៤.សេវាកម្មវប្បធម៌ និងសិក្សាស្រាវជ្រាវ ហើយសេវាកម្មទាំងអស់នេះ បានកំពុងដើរតួនាទីយ៉ាងសំខាន់ ចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ នឹងចូលរួមចំណែកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះ មហន្តរាយធម្មជាតិ។ |
| ១០. | **បឹងកាដេរ**<br>ភូមិសាស្ត្រ<br>ខេត្តត្បូងឃ្មុំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរ តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេ និងផ្នែកខាងក្រោមមានរំលេចអក្សរ មន្ទីរបរិស្ថានខេត្តត្បូងឃ្មុំ<br>១.រូបផ្កាចារ និងដើមចារ ( *butea monosperma* )៖ ជាតំណាងតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេដែលប្រភេទនេះមានវត្តមានដុះបណ្តុំគ្នាច្រើននៅក្នុងតំបន់នេះ លើទំហំដីរហូតដល់១០០ហិកតា ហើយដើមឈើប្រភេទនេះចេញផ្កានៅរដូវប្រាំង ដែលចេញស្របគ្នាក្នុងពេលតែមួយ ដែលធ្វើឱ្យតំបន់កាដេនេះនៅរដូវប្រាំងមានភាពស្រស់ស្អាត។ តាមរយៈវត្តមានប្រភេទរុក្ខជាតិដើមចារ ដែលដុះបណ្តុំគ្នា និងមានផ្កាស្រស់ស្អាតបែបនេះ ធ្វើឱ្យតំបន់នេះមានសក្តានុពលខ្ពស់សម្រាប់អភិរក្សសេនេទិច និងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដោយមានហេដ្ឋារចនាសម្ព័ន្ធពេញលេញ និងក្រោយពីរាជរដ្ឋាភិបាល នឹងបានស្ថាបនារួចនូវមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ នៅពេលអនាគត។<br><br>ដើមចារ ( *butea monosperma* ) មានកំពស់ពី០៨ ទៅ១០ម៉ែត្រ ដុះភាគច្រើននៅតាមវាលទំនាបលិចទឹករយៈពេលខ្លី នៅតាមតំបន់ជាយៗនៃព្រៃលិចទឹក ឬក្បែរភូមិ។ ពូជរុក្ខជាតិប្រភេទនេះមាននៅតំបន់ក្តៅនៃទ្វីបអាស៊ី ហើយផ្ការបស់វាមានពណ៌ក្រហមភ្លាវ និងចេញផ្កាមុនស្លឹក។ ក្នុងប្រទេសខ្មែរយើងគេនិយមចាក់ផែនស្វាយលើស្លឹកចារទុកហាលថ្ងៃឱ្យស្ងួត ឬសខ្ចីៗរបស់វា អាចស្ងោរបរិភោគបាន ហើយដើមចារនេះក៏អាចប្រើប្រាស់សម្រាប់សង់ផ្ទះបាន។ សរសៃសំបកចារ ច្រើនគេយកទៅវិញធ្វើខ្សែពួរ និងធ្វើស្បែកជើងសង្រែក ហើយគេសង្កេតឃើញមានជ័រពណ៌ក្រហម ហូរចេញមកក្រៅ និងកកភ្លាមៗនៅពេលគេកាត់ដើមវា។ ជ័រវាគ្រូថ្នាំប្រើសម្រាប់ព្យាបាលដំបៅ ឬជំងឺរាគ ហើយគ្រាប់របស់វាប្រើជាថ្នាំបញ្ចុះ។<br><br>ជាកាកត់សម្គាល់ ដើមចារ និងផ្កាចារគឺរុក្ខជាតិមួយប្រភេទ ដែលត្រូវបានផ្សាភ្ជាប់ជាមួយការរស់នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមសហគមន៍ជនបទ ជាពិសេសបណ្តាប្រជាជនដែលរស់តាមតំបន់ទំនាបលិចទឹក រួមជាមួយវប្បធម៌ប្រពៃណីតាំងពីបុរាណមក ជាឧទាហរណ៍ មានបទចម្រៀងប្រពៃណីភ្លេងបុរាណ «សំពោងផ្កាចារ» ជាដើម។<br><br>២. រូបពណ៌បៃតងខ្ចី ជាតំណាងព្រៃលិចទឹក៖ គឺបង្ហាញពីភាពសម្បូរបែបនៃធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដែលមានព្រៃលិចទឹកដែលជាប្រភេទព្រៃលិចទឹកទឹកសាបតាមរដូវ ហើយព្រៃលិចទឹកនេះបានដើរតួនាទីសំខាន់ជាជម្រកត្រី សត្វព្រៃ សម្រាប់រស់នៅ និងបន្តពូជ។ ព្រៃលិចទឹកនេះបានផ្តល់ផល និងអនុផលព្រៃឈើដល់ប្រជាហគមន៍ដែលរស់នៅជុំវិញតំបន់នេះ។ |

| | | |
|---|---|---|
| | | ៣.រូបពណ៌ខៀវប្រលែត ជាលំហទឹក និងមានមច្ឆាជាតិ បង្ហាញពីរបបជលសាស្ត្រនៃតំបន់បឹងកាដេនេះ ដែលទទួលបានរបបទឹកជំនន់នៅរដូវវស្សាពីទន្លេមេគង្គហូរចូលតាមរយៈដៃទន្លេ (ព្រែកតាកុច ព្រែកដីក ព្រែកជ្រៃ ព្រែកសណ្តាន់ និងព្រែកកក់) ដែលមានបឹងសំខាន់ៗចំនួន៤ និងព្រែកចំនួន២ ដែលមានរបបទឹកអចិន្ត្រៃយ៍រដូវប្រាំង (បឹងកាដេរ បឹងជីឡែង បឹងស្រូល បឹងស្លែ ព្រែកសណ្តាន់ និងព្រែកកក់) ដែលមានលទ្ធភាពក្នុងការស្តុកទឹករាប់លានម៉ែត្រគូប សម្រាប់ការប្រើប្រាស់របស់ប្រជាជនដែលរស់នៅជុំវិញតំបន់នេះសម្រាប់ស្រោចស្រពផ្ទៃដីកសិកម្មរាប់ពាន់ហិកតា និងចូលរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មផ្សេងទៀត ដូចជាដាំថ្នាំជក់ ពោត សណ្តែក ។ល ។ ជាមួយគ្នានេះដែរ បឹងកាដេចូលរួមចំណែកសន្តិសុខនៃការផ្គត់ផ្គង់ទឹករយៈវែង និងមាននិរន្តភាពនៃធនធានទឹក ជាពិសេសទឹកក្រោមដី ក្នុងអាងទន្លេមេគង្គ ការរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី និងចូលរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ។<br><br>៤) សត្វស្លាបហើយៈ បង្ហាញពីសក្តានុពលតំបន់ដែលទ្រទ្រង់ដល់ការស្នាក់អាស្រ័យបន្តពូជ និងរស់នៅរបស់សត្វស្លាប រួមទាំងសត្វព្រៃផ្សេងៗទៀត រួមទាំងប្រភេទរស់នៅជាអចិន្ត្រៃយ៍ និងប្រភេទស្នាក់នៅបណ្តោះអាសន្ន រួមទាំងប្រភេទទេសន្តរប្រវេសន៍ ដែលក្នុងនោះរួមទាំងប្រភេទសត្វព្រៃដែលមានសារៈសំខាន់សម្រាប់ការអភិរក្សជាអន្តរជាតិផងដែរ។ ជាទូទៅតំបន់នេះមានសត្វស្លាបប្រភេទចង្រៀលខ្យងដែលមានវត្តមាននៅក្នុងតំបន់នេះ មានប្រយោជន៍ និងចំណេញដល់សេដ្ឋកិច្ចមូលដ្ឋាន និងក្នុងតំបន់ផ្សេងៗ ស៊ីសត្វខ្យងក្រហមជាអាហារ ដែលយាយីដំណាំស្រូវប្រជាពលរដ្ឋ នៅតំបន់ដីសើមបឹងកាដេ។ |
| **ខ.តំបន់រ៉ាមសារ** | | |
| ១. | **ស្ទឹងត្រែង**<br>ភូមិសាស្ត្រ<br>ខេត្តស្ទឹងត្រែង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់រ៉ាមសារស្ទឹងត្រែង និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង<br>១.រូបដើមឈើព្រៃលិចទឹកតាមរដូវមានឫសច្រើន ដុះចំកណ្តាលទន្លេ ជាតំណាងតំបន់រ៉ាមសារស្ទឹងត្រែងដោយមានសក្តានុពលធនធានធម្មជាតិ និងសោភ័ណ្ឌភាពនៃព្រៃលិចទឹកតាមដងទន្លេមេគង្គនៃខេត្តស្ទឹងត្រែង។<br>២.រូបសត្វផ្សោត គឺជាប្រភេទសត្វជិតផុតពូជលើពិភពលោក ដែលតំណាង ដោយមានភាពសម្បូរបែបនៃធនធានថនិកសត្វនៅក្នុងអាងទន្លេមេគង្គ និងជុំវិញតំបន់ជាប់នឹងប្រទេសឡាវ។ ប្រភេទត្រីជាច្រើនជាប្រភេទត្រីកម្រ និងជិតផុតពូជលើពិភពលោក គឺបង្ហាញពីវត្តមានធនធានមច្ឆជាតិនៅក្នុងតំបន់ដែលសម្បូរដោយអន្លង់ត្រីមេពូជ ដែលជម្រករស់នៅ និងបន្តពូជពងកូនត្រីគ្រប់ប្រភេទ រួមទាំងប្រភេទដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដូចជា ត្រីប៉ាវ៉ា ប៉ាស៊ីអ៊ីជាដើម។<br>៣.រូបសត្វស្លាប បង្ហាញពីការទ្រទ្រង់នៃតំបន់ដល់ការរស់នៅ និងបន្តពូជប្រភេទសត្វស្លាបគ្រប់ប្រភេទរួមទាំងប្រភេទសត្វទេសន្តរប្រវេសន៍ និងប្រភេទសត្វជិតផុតពូជ ដូចជាប្រភេទសត្វរំពេទន្លេជាដើម។ |

| | | |
|---|---|---|
| | | ៥.រូបអណ្តើក គឺតំណាងឱ្យភាពសម្បូរបែបនៃប្រភេទសត្វល្មូននៅតាមដងទន្លេ រួមទាំងប្រភេទល្មូនសំខាន់ៗ ដែលជាប្រភេទជិតផុតពូជលើពិភពលោកមានដូចជាអណ្តើកក្បាលកង្កែបជាដើម។<br>៦.រូបពណ៌ខៀវប្រលៃតទន្លេ ដោយមានអន្លង់ចំនួន ៩៣អន្លង់ ដែលមានទំហំតូចបំផុត ៣០ម៉ែត្រ x ៣០ម៉ែត្រ និងធំបំផុត ២៥០ម៉ែត្រ x ១៥០០ម៉ែត្រ និងមានជម្រៅជ្រៅៗ ដែលមានព្រៃលិចទឹកជាប្រភពមច្ឆជាតិដែលមាន ១៣០ប្រភេទ។តំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង សត្វស្លាបមានចំនួន ៩៧ប្រភេទ ឧរង្គសត្វមាន ៣ប្រភេទ និងប្រភេទថលជលិក ដែលបង្ហាញពីភាពសំបូរបែបនៃធនធានធម្មជាតិ និងជីវៈចម្រុះក្នុងតំបន់រ៉ាមសារស្ទឹងត្រែង។<br>៧.តំបន់រ៉ាមសារស្ទឹងត្រែង មានសារៈសំខាន់ និងតម្លៃរបស់តំបន់រ៉ាមសារខេត្តស្ទឹងត្រែង គឺចូលរួមចំណែកយ៉ាងធំធេងរក្សានូវលំនឹងបរិស្ថាន ការពារនិងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែននៃអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ។ |
| ២. | **កោះកាពិ**<br>ភូមិសាស្ត្រ<br>ខេត្តកោះកុង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់រ៉ាមសារកោះកាពិ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកោះកុង<br>១. រូបសត្វទីតលីតធំ ជាតំណាងតំបន់រ៉ាមសារកោះកាពិ និងជាប្រភេទសត្វជិតផុតពូជ និងជាប្រភេទសត្វស្លាបទេសន្តរប្រវេសន៍ ដែលបង្ហាញពីសក្តានុពលតំបន់ដែលទ្រទ្រង់ដល់ការរស់នៅរបស់ប្រភេទ ដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសប្រភេទទេសន្តរប្រវេសន៍នេះដែលជ្រើសរើសតំបន់នេះជាទីសំចត និងជាសញ្ញាណនៃការទ្រទ្រង់ដល់ជីវៈចម្រុះផ្សេងៗជាច្រើនទៀត។<br>២. រូបពណ៌បៃតងខ្ចី តំណាងព្រៃកោងកាង បង្ហាញពីទីជម្រកដ៏សំខាន់និងភាពសម្បូរបែបធនធានធម្មជាតិ ដែលនៅក្នុងតំបន់ព្រៃកោងកាងនេះក៏មានវត្តមានប្រភេទជីមមោក ដែលជាប្រភពស្តុកកាបូន ចូលរួមក្នុងការកាត់បន្ថយការបាត់បង់ និងរេចរិលព្រៃឈើ ដែលឆ្លើយតបនឹងបញ្ហាប្រឈមនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ។<br>៣.រូបពណ៌ខៀវប្រលៃត និងពណ៌ស តំណាងទឹកសមុទ្រ និងឆ្នេរ បង្ហាញពីភាពសម្បូរបែបនៃធនធានសមុទ្រ នៅក្នុងតំបន់ដែលជាប្រភពសេដ្ឋកិច្ចសម្រាប់ទ្រទ្រង់ដល់សហគមន៍មូលដ្ឋាន។ |

| | | |
|---|---|---|
| | | ៤.ក្នុងន័យនេះ ក៏បង្ហាញពីសារៈសំខាន់និងតម្លៃរបស់តំបន់រ៉ាមសារកោះកាពិ ខេត្តកោះកុង គឺចូលរួមចំណែកយ៉ាងធំធេងរក្សានូវលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ ឆ្នេរ និងសមុទ្រ និងរួមវំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែនជាមួយប្រទេសជិតខាង ក្នុងក្រប័ខណ្ឌតំបន់ និងសកលលោក ដែលប្រទេសកម្ពុជាជាសមាជិកនៃអនុសញ្ញាអន្តរជាតិដូចជាអនុសញ្ញារ៉ាមសារ អនុសញ្ញាក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាស្តីពីជីវៈចម្រុះ និងអនុសញ្ញាផ្សេងៗទៀតផងដែរ។ |
| ៣. | **បឹងទន្លេឆ្មារ** ភូមិសាស្ត្រ ខេត្តកំពង់ធំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ផ្នែកខាងលើមានរំលេចអក្សរតំបន់រ៉ាមសារបឹងទន្លេឆ្មារ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ធំ<br>១.រូបពណ៌ខៀវជាព្រៃលិចទឹក និងរូបត្រីដំរី ជាតំណាងតំបន់រ៉ាមសារបឹងទន្លេឆ្មារ និងភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ។<br>២.តំបន់រ៉ាមសារបឹងទន្លេឆ្មារ មានសក្តានុពលធនធានធម្មជាតិព្រៃលិចទឹក ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងបន្តពូជរបស់ត្រីក៏ដូចជាប្រភេទសត្វផ្សេងទៀតផងដែរ។ ព្រៃលិចទឹកជាប្រភេទធនធានដែលជួយស្តុកកាបូន រួមចំណែកដល់ការជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ។<br>៣.រូបត្រីដំរី មានប្រវែង៣០-សង់ទីម៉ែត្រ និងរូបពណ៌ខៀវប្រលែត តំណាងទឹក។ តំបន់បឹងទន្លេឆ្មា សម្បូរទៅដោយ ត្រីដំរី ដោយមានជម្រកនិងតំបន់សម្បូរប្រភេទត្រីដំរី ដែលជាប្រភេទត្រីមានសក្តានុពលសេដ្ឋកិច្ចខ្ពស់ សម្រាប់សេដ្ឋកិច្ចសហគមន៍មូលដ្ឋានដែលពឹងផ្អែកទាំងស្រុងលើធនធានធម្មជាតិ។ រូបត្រីដំរីនេះផងដែរក៏ជាតំណាងឱ្យភាពសម្បូរបែបនៃប្រភេទត្រីផ្សេងៗទៀតដែលកំពុងរស់នៅ ជំជាត់ និងបន្តពូជនៅតំបន់រ៉ាមសារបឹងទន្លេឆ្មារនេះ។<br>៤.រូបសត្វស្លាប បង្ហាញពីសក្តានុពលតំបន់ដែលទ្រទ្រង់ដល់ការស្នាក់អាស្រ័យ និងរស់នៅរបស់សត្វស្លាប។ ក្នុងន័យនេះ ក៏បង្ហាញពីសារៈសំខាន់និងតម្លៃរបស់តំបន់រ៉ាមសារបឹងទន្លេឆ្មា ខេត្តកំពង់ធំ គឺចូលរួមចំណែកយ៉ាងធំធេងរក្សានូវលំនឹងបរិស្ថាន ការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែននៃអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ និងសកលលោកដែលបង្ហាញអំពីការបំពេញកាតព្វកិច្ចរបស់ប្រទេសកម្ពុជាជាសមាជិកនៃអនុសញ្ញាអន្តរជាតិ ដូចជា អនុសញ្ញារ៉ាមសារ អនុសញ្ញាក្របខ័ណ្ឌ |

| | | |
|---|---|---|
| | | របស់អង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាស្តីពី ជីវៈចម្រុះ និងអនុសញ្ញាផ្សេងៗទៀតផងដែរ។ |
| ៤. | ព្រែកទាល់ ភូមិសាស្រ្ត ខេត្តបាត់ដំបង | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់រ៉ាមសារព្រែកទាល់ និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តបាត់ដំបង<br>១. រូបសត្វត្រដក់ធំ ( Greater Adjutant : *Leptoptilos dubius* ) ជាតំណាងតំបន់រ៉ាមសារព្រែកទាល់ និងជាប្រភេទជិតផុតពូជលើពិភពលោក និងភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ។<br>សត្វត្រដក់ធំ មានប្រវែង ១៤៥-១៥០ សង់ទីម៉ែត្រ ដែលមានបណ្តោយខ្លួនធំ ធ្មុតបណ្តោយកណ្តាលផ្ទាំងស្លាបលើសប្បុរប្រផេះ ស្មាមានពោមស និងមានថង់យាមមួយនៅក។ ទីជម្រករបស់សត្វត្រដក់ធំ រស់នៅព្រៃរនាម ដែលជាព្រៃលិចទឹកតាមរដូវ នៃតំបន់ដីសើម និងព្រៃល្បោះ។ ត្រដក់ធំ មានវត្តមានពេញមួយឆ្នាំ និងមានបន្ទាយពងកូនយ៉ាងធំនៅតំបន់ព្រែកទាល់បឹងទន្លេសាប។ ការបន្តពូជរបស់វា ចាប់ផ្តើមពីខែតុលា ដល់ខែមិថុនា ដែលមានពងចំនួន ២-៤។<br>២.តំបន់រ៉ាមសារព្រែកទាល់ ជាទីជម្រកពងកូនធំជាងគេទីពីរលើពិភពលោក សម្រាប់ប្រភេទនេះបន្ទាប់ពីប្រទេសឥណ្ឌា។ រូបត្រដក់ធំនេះ គឺបង្ហាញពីលក្ខណៈពិសេសដាច់ដោយឡែកនៃតំបន់ និងជាតំណាងឱ្យវត្តមានប្រភេទសត្វកម្រ និងភាពសំបូរបែបនៃប្រភេទសត្វស្លាបទឹកសំខាន់ៗផ្សេងទៀតដូចជាៈ ទុងប្រផេះ រនាលពណ៌ រនាលស ត្រដក់តូច ស្មោញ ត្រយងខ្លួនសរ ពពូលទឹក កុកពាក់អំបោះ អង្កត់ខ្មៅ អកត្រីក្បាលប្រផេះ ជាដើម ដែលមានតម្លៃជាអន្តរជាតិ តែងតែមកបន្តពូជពងកូនជារៀងរាល់ឆ្នាំ និងជាកន្លែងបន្តពូជធំជាងគេបំផុតរបស់សត្វស្លាបទឹកក្នុងតំបន់អាស៊ីអាគ្នេយ៍។<br>៣.រូបពណ៌ប្រផេះ តំណាងព្រៃលិចទឹក និងពណ៌ខៀវប្រលែត តំណាងឱ្យទឹក ដែលជាសក្តានុពលធនធានព្រៃលិចទឹក បឹង ស្ទឹង ព្រែក អូរ ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងបន្តពូជរបស់ត្រី ក៏ដូចជាប្រភេទសត្វផ្សេងទៀតផងដែរ។ ព្រៃលិចទឹក មានតួនាទីជានិយ័តករ និងជាធនធានស្តុកកាបូនយ៉ាងសំខាន់ផងដែរ ដែលរួមចំណែកដល់ការជួយកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។<br>៤.តំបន់រ៉ាមសារព្រែកទាល់ បាន និងកំពុងផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីយ៉ាងសំខាន់សម្រាប់វិស័យទេសចរណ៍ធម្មជាតិ តាមរយៈការទស្សនាបន្ទាយពងកូនសត្វស្លាប ព្រៃលិចទឹក ទំនៀមទំលាប់ប្រពៃណីនៃការរស់នៅដោយពឹងផ្អែកលើធម្មជាតិ និងការរស់នៅរបស់ប្រជាជនដោយពឹងផ្អែកលើធម្មជាតិ និងការរស់នៅលើភូមិបណ្តែតទឹក។<br>ក្នុងន័យនេះ ក៏បង្ហាញពីសារៈសំខាន់និងតម្លៃរបស់តំបន់រ៉ាមសារព្រែកទាល់ ខេត្តបាត់ដំបង គឺចូលរួមចំណែកយ៉ាងធំធេងរក្សាលំនឹងបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិ និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ |

| | | |
|---|---|---|
| | | ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងកិច្ចការពារ និងថែរក្សាធនធានធម្មជាតិ និងជីវៈចម្រុះឆ្លងដែន ស្របតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ សម្រាប់អភិវឌ្ឍដោយនិរន្តរភាព នៃអាងទន្លេមេគង្គក្រោម (ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ និងសកលលោក ដែលបង្ហាញអំពីការបំពេញកាតព្វកិច្ចរបស់ប្រទេសកម្ពុជាជាសមាជិកនៃអនុសញ្ញាអន្តរជាតិ ដូចជាអនុសញ្ញារ៉ាមសារ អនុសញ្ញាក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងអនុសញ្ញាស្តីពី ជីវៈចម្រុះ និងអនុសញ្ញាផ្សេងៗទៀតផងដែរ។ |
| ៥. | **ស្ទឹងសែន** ភូមិសាស្ត្រ ខេត្តកំពង់ធំ | នៅខាងក្នុងនៃរូបសញ្ញាសម្គាល់ ផ្នែកខាងលើមានរំលេចអក្សរតំបន់រ៉ាមសារស្ទឹងសែន និងផ្នែកខាងក្រោមមានរំលេចអក្សរមន្ទីរបរិស្ថានខេត្តកំពង់ធំ<br>១.រូបសត្វភេរពោមច្រមុះ (Hairy-nosed Otther: *Lutra sumatrana*)ជាតំណាងតំបន់រ៉ាមសារស្ទឹងសែន និងជាប្រភេទជិតផុតពូជលើពិភពលោក និងភាពសម្បូរបែបធនធានធម្មជាតិ និងជីវៈចម្រុះ។<br>សត្វភេរពោមច្រមុះ មានប្រវែងដងខ្លួន៥០-៨២ សង់ទីម៉ែត្រ ប្រវែងកន្ទុយ ៤៥-៥០ សង់ទីម៉ែត្រ និងមានទម្ងន់ពី៥-៦គីឡូក្រាម។ សត្វភេរពោមច្រមុះ មានទំហំតូចជាងភេរលោង និងភេក្បាលសំប៉ែត។ នៅលើខ្នងមានសប្បុរត្នោត ហើយនៅសងខាងពោះ និងទ្រូងមានសប្បុរព្រលែត។ ចំពោះ ចង្កា បបូរមាត់លើបំពង់ក មាន សប្បុរស។ សត្វភេពោមច្រមុះ មានពោមនៅនឹងច្រមុះ និងកន្ទុយរាងមូល។<br>សត្វភេរពោមច្រមុះ ចូលចិត្តរស់នៅតាមតំបន់ដីសើមវាលទំនាប ដូចជាព្រៃកោងកាង (Rhizophora mucronata) ព្រៃស្មាច់ (Melaleuca) ព្រៃវាលភក់ និងតំបន់ដីសើមលិចទឹក។ របាយរបស់វា មានវត្តមាននៅកម្ពុជា រួមមានខេត្តបាត់ដំបង តំបន់បឹងទន្លេធ្មា (ទន្លេភាគឦសានខេត្តកំពង់ធំ)។ ទោះបីជាវាមានវត្តមាននៅក្នុងព្រៃទាំងនេះក៏ដោយ ក៏នៅក្នុងប្រទេសម៉ាឡេស៊ី ប្រភេទនេះ ត្រូវបានកត់ត្រា ពីវត្តមានរបស់វានៅរយៈកម្ពស់រហូតដល់ ៥០០ម៉ែត្រ។ ប្រភេទនេះ ក៏មានវត្តមាននៅក្នុងភាគខាងត្បូងប្រទេសវៀតណាម ប្រទេសថៃ កោះស៊ូម៉ាត្រា និងកោះបរណេអូផងដែរ។<br>២.សត្វភេរពោមច្រមុះ បានកំពុងរស់នៅ និងបន្តពូជក្នុងតំបន់ ដែលជាតំណាងនៃភាពសម្បូរបែបនៃប្រភេទថនិកសត្វថ្នាក់តូចនៅក្នុងតំបន់ ជាពិសេសប្រភេទថនិកសត្វថ្នាក់តូចកម្រ។<br>៣.រូបសត្វស្លាបៈ បង្ហាញពីវត្តមាន និងសក្តានុពលនៃតំបន់រ៉ាមសារស្ទឹងត្រែង ដែលទ្រទ្រង់ដល់ការរស់នៅរកចំណី និងស្នាក់នៅរបស់ប្រភេទសត្វស្លាបទឹកសំខាន់ៗ ដែលមានតម្លៃជាអន្តរជាតិ រួមបញ្ចូលទាំងប្រភេទសត្វទេសសន្តរប្រវេសន៍។ |

| | | |
|---|---|---|
| | | ៤.រូបពណ៌ប្រផេះ ជាព្រៃលិចទឹក និងពណ៌ខៀវប្រលែត ជាលំហទឹកៈ តំណាងសក្តានុពលធនធានព្រៃលិចទឹក បឹង ស្ទឹង ព្រែក អូរ ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅ និងបន្តពូជរបស់ត្រី ក៏ដូចជាប្រភេទជីវៈចម្រុះផ្សេងទៀតផងដែរ។ ព្រៃលិចទឹកមានលក្ខណៈពិសេសដាច់ដោយឡែកពីតំបន់ផ្សេងទៀត ក្នុងតំបន់បឹងទន្លេសាបដែលមានចម្រុះប្រភេទនិងប្រភេទព្រៃឈើធំៗមានកំពស់រហូតដល់១៥-២០ម៉ែត្រ ហើយមានតួនាទីជានិយ័តករ និងជាធនធានស្តុកកាបូនយ៉ាងសំខាន់ផងដែរ ដែលរួមចំណែកដល់ការជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ ទាំងក្នុងប្រទេស និងក្នុងតំបន់។<br>រូបសត្វស្លាប ថនិកសត្វ ត្រី និងព្រៃលិចទឹកគឺបង្ហាញពីប្រព័ន្ធអេកូស៊ីនៃតំបន់ប្រកបដោយសុខមាលភាព ដែលជាប្រភពផ្តល់នូវសេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ទ្រទ្រង់ដល់សេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។ |